**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale Re Droit et des Sciences Economiques**

**Royal University of law and Economics**

# សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍ និងការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ល. ភ្វាស តិក**

**ល. ឆាយ ម៉េងឈុន**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale Re Droit et des Sciences Economiques**

**Royal University of law and Economics**

## សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍ និងការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ល. ភ្វាស តិក**

**ល. ឆាយ ម៉េងឈុន**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **ភ្វាស ភិក** និង **ឆាយ ម៉េងឈុន** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២០ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា២០១៦ ដល់ ឆ្នាំសិក្សា២០២០។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ លោកឪពុក អ្នកម្តាយ ជាទីគោរពស្រលាញ់នៃកូនដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្តីមេត្តាករុណា និងផ្តល់ក្តីស្រលាញ់តាំងពីតូចរហូតធំពេញវ័យ ហើយរូបលោកបានលះបង់គ្រប់បែបយ៉ាងទាំងកម្លាំងកាយ កម្លាំងចិត្ត និងថវិកាដើម្បីអោយរូបកូនបានសិក្សារៀនសូត្រ ព្រមទាំងខិតខំអប់រំ ផ្តល់ដំបូន្មានប្រៀនប្រដៅអោយរូបកូនដើរផ្លូវល្អ មិនអោយប្រព្រឹត្តអំពើណាដែលសង្គមស្អប់ខ្ពើម ដោយអោយកូនប្រតិបត្តិតែអំពើសុចរិតទៀងត្រង់ ព្រមទាំងបានជំរុញលើកទឹកចិត្តដល់រូបកូនក្នុងការសិក្សារៀនសូត្រ និងតម្រង់ទិសកូនអោយក្លាយជាពលរដ្ឋល្អក្នុងសង្គម។ ដោយការយកចិត្តទុកដាក់ គឺជាថ្ងៃដែលកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្របានជោគជ័យ ហើយមានចំណេះដឹងខ្លះសម្រាប់ធ្វើជាទន់ក្នុងការរស់នៅ។

ទន្ទឹមគ្នានេះដែរ យើងទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចន្ទ្រា** ដែលលោកជាអ្នកគ្រប់គ្រងនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយលោកបានផ្តល់កន្លែងសិក្សាដល់យើងខ្ញុំទាំងពីរបានសិក្សារហូតសម្រេចលទ្ធផលបង្កើតស្នាដៃនេះឡើង។

ជាងនេះទៅទៀត សូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យ ទេព សុខ** ដែលជាសាស្ត្រាចារ្យណែនាំយើងខ្ញុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការបង្ហាត់បង្ហាញអស់ពីកម្លាំងចិត្ត កម្លាំងកាយ និងណែនាំកែតម្រូវផ្តល់នូវចំណេះដឹងយ៉ាងច្រើន ក៏ដូចជាផ្តល់ជាអានុសាសន៍ និងប្រាប់ទិសដៅអោយយើងខ្ញុំក្នុងការបង្កើតកិច្ចការស្រាវជ្រាវបានជោគជ័យ។

ម្យ៉ាងទៀត យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណ និងដឹងគុណចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្ត និងផ្តល់ចំណេះដឹងយ៉ាងច្រើន និងពិតប្រាកដដល់យើងខ្ញុំទាំងពីរអោយឈានដល់ការបង្កើតស្នាដៃនេះឡើង។

មួយវិញទៀតសូមថ្លែងអំណរគុណដល់បងប្អូនសិស្សច្បងមិត្តភក្តិទាំងអស់ដែលបានជួយជ្រោមជ្រែងលើកទឹកចិត្ត និងការផ្តល់មតិយោបលល្អៗជាច្រើន និងការចែករំលែកបទពិសោធន៍ល្អៗ។

ចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរសូមដល់វត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោកថែរក្សាការពារ និងប្រសិទ្ធពរជ័យជូនដល់លោកទាំងអស់ ជួបតែក្តីសុខចម្រើន សុខភាពល្អ អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារៈកិច្ច និងជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំកន្លងមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងផ្នែកនីតិសាធារណៈរួចមក យើងខ្ញុំទាំងពីរបានទទួលចំណេះដឹងទូលំទូលាយលើមុខវិជ្ជាទាំងអស់នោះ ក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ មកដល់យើងខ្ញុំ។ ដោយការជ្រោមជ្រែង និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្តទាំងអស់នេះហើយ ទើបធ្វើអោយយើងខ្ញុំអាចឈានមកដល់ការចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ។ ការរៀបចំសរសេរសារណានេះឡើង ក្នុងគោលដៅដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២០ និងដើម្បីចូលរួមចំណែកនៅក្នុងសង្គម។ ការសរសេរសារណាត្រូវតម្រូវអោយយើងមាន សមត្ថភាព និងចំណេះដឹងខ្ពស់ក្នុងការចងក្រងវាឡើងមក ព្រោះថាការចងក្រងសារណាមួយឡើងមក ព្រោះថាយើងត្រូវជួបប្រទះ និងការលំបាកជាច្រើន ទើបយើងអាចទទួលបាននូវលទ្ធផលល្អ។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹងផ្នែកឯកជនដែលមានចំណងជើងថា "អាពាហ៍ពិពាហ៍ និងការលែងលះ"។ ការជ្រើសរើសប្រធានបទនេះឡើងមក គឺដើម្បីអោយបុគ្គលគ្រប់រូបយល់ដឹងកាន់តែច្បាស់អំពីបែបបទនៃការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈស្របទៅតាមច្បាប់ដែលបានកំណត់ មិនតែប៉ុណ្ណោះគឺអោយបុគ្គលគ្រប់រូបដែលមានបញ្ហាចំណងអាពាហ៍ពិពាហ៍មានភាពរកាំរកូស មានភាពមិនចុះសម្រុងជាមួយគ្រួសារ ហើយចង់ផ្តាច់ចំណងអាពាហ៍ពិពាហ៍នោះអោយជ្រាបច្បាស់ពីនីតិវិធីនៃការលែងលះ ការបែងចែកទ្រព្យសម្បត្តិ ការផ្តល់អាហារកាព្វកិច្ចជាដើម។ អាពាហ៍ពិពាហ៍ និងការលែងលះត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលប្រកាសអោយប្រើនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដោយអនុក្រឹត្យលេខ៥៦។ តែពេលបច្ចុប្បន្នច្បាប់នេះត្រូវបាននិរាករណ៍ចោលទៅហើយ ហើយបានជំនួសនូវក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ វិញ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងអាចជាជំនួយការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិត និងប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលចង់ស្វែងយល់បន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ និងការលែងលះដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ហើយនឹងទុកស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាបន្ថែមអោយកាន់តែច្បាស់អំពីនីតិវិធី ក្នុងការរៀបអាពាហ៍ពិពាហ៍ និងការលែងលះ ក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់ការចំណុចខ្វះខាតមួយចំនួនដូចជាពាក្យពេចន៍ខ្លឹមសារអត្ថន័យ ឬអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា ហើយក្រុមយើងខ្ញុំនិងទទួល

ស្វាគមន៍ជានិច្ចរាល់ការរិះគន់ក្នុងអត្ថន័យស្ថាបនាជាមួយ  និងគំនិតល្អៗរបស់មិត្តអ្នកអានទាំងអស់  ដើម្បីធ្វើការកែលំអរ និងធ្វើអោយល្អប្រសើរជាងមុន។

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម


**១. លំនាំបញ្ហា** ........ ១

**២. ចំណោទបញ្ហា** ........ ១

**៣. គោលបំណងនៃការស្រាវជ្រាវ** ........ ២

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ២

**៥. សារៈសំខាន់នៃការស្រាវជ្រាវ** ........ ២

**៦. វិធីសាស្ត្រស្រាវជ្រាវ** ........ ៣

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៣


## ជំពូកទី១

## សញ្ញាណគតិយុត្តនៃអាពាហ៍ពិពាហ៍


**១.១. កំជាប់ពាក្យ** ........ ៤

១.១.១. ធាតុផ្សំកំជាប់ពាក្យ ........ ៤

១.១.២. ការរំលាយកំជាប់ពាក្យ ........ ៤

ក. ការរំលាយកំជាប់ពាក្យដោយមានមូលហេតុត្រឹមត្រូវ ........ ៥

ខ. ការរំលាយកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ ........ ៥

**១.២. លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍** ........ ៦

១.២.១. លក្ខខណ្ឌអាយុ ........ ៦

១.២.២. លក្ខខណ្ឌទាក់ទងនឹងសមត្ថភាព ........ ៧

១.២.៣. លក្ខខណ្ឌទាក់ទងនឹងការព្រមព្រៀង ........ ៨

១.២.៤. លក្ខខណ្ឌឯកពន្ធភាព ........ ៩

១.២.៥. លក្ខខណ្ឌទាក់ទិននឹងទំនាក់ទំនងញាតិ ........ ៩

១.២.៦. លក្ខខណ្ឌទម្រង់ ........ ១១

ក. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ........ ១១

ខ. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និង ជនបរទេស នៅបរទេស ........ ១២

គ. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា ........ ១៣

# ជំពូកទី២

# វិការៈ និងអានុភាពនៃអាពាហ៍ពិពាហ៍

**២.១. វិការៈនៃអាពាហ៍ពិពាហ៍**......១៥
២.១.១. មោឃភាពនៃអាពាហ៍ពិពាហ៍ ......១៥
ក. ករណីនៃមោឃភាពអាពាហ៍ពិពាហ៍ ......១៥
ខ. អានុភាពនៃមោឃភាព......១៦
២.១.២. ការលុបចោលអាពាហ៍ពិពាហ៍......១៦
ក. ករណីនៃការលុបចោលអាពាហ៍ពិពាហ៍......១៦
ខ. ជនដែលមានសិទ្ធិលុបចោលអាពាហ៍ពិពាហ៍......១៧
គ. ការរំលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ ......១៨
ឃ. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ......២០
ឃ.១. អានុភាពនៃការលុបចោល ចំពោះកូន ......២០
ឃ.២. អានុភាពនៃការលុបចោល ចំពោះទ្រព្យសម្បត្តិ ......២១
**២.២. អានុភាពនៃអាពាហ៍ពិពាហ៍**......២៣
២.២.១. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះទំនាក់ទំនងផ្ទាល់ខ្លួន ......២៣
២.២.២. អានុភាពនៃអាពាហ៍ពិពាហ៍ ចំពោះទ្រព្យ......២៤
ក. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ......២៤
ខ. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ......២៥
ខ.១. ទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធ ......២៦
ខ.១.១. ប្រភេទនៃទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធ ......២៦
ខ.១.២. ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ......៣០
ខ.២. ទ្រព្យសម្បត្តិអកម្មរបស់សហព័ទ្ធ ......៣៣
ខ.២.១. កាតព្វកិច្ចដែលកើតឡើងនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍...... ៣២
ខ.២.២. កាតព្វកិច្ចដែលកើតឡើងមុនពេលមានចំណងអាពាហ៍ពិពាហ៍......៣៤
២.២.៣. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះកូន ......៣៥

## ជំពូកទី៣
## ការលែងលះនៃអាពាហ៍ពិពាហ៍

**៣.១. មូលហេតុនៃការលែងលះ** ..................... ៣៧
**៣.២. នីតិវិធីនៃការលែងលះ** ..................... ៣៩
៣.២.១. នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀងលែងលះ ..................... ៣៩
៣.៣.២. នីតិវិធីនៃការលែងលះក្នុងករណីមានពាក្យបណ្តឹងសុំលែងលះ ..................... ៣៩
ក. តុលាការមានសមត្ថកិច្ច ..................... ៣៩
ខ. បណ្តឹងលែងលះ ..................... ៤០
គ. ការផ្សះផ្សា ..................... ៤០
ឃ. នីតិវិធីត្រៀមសម្រាប់ធ្វើការទាញហេតុផលផ្ទាល់មាត់ ..................... ៤០
ង. សេចក្តីសម្រេចក្នុងរឿងលែងលះ ..................... ៤០
**៣.៣. អនុភាពនៃការលែងលះ** ..................... ៤១
៣.៣.១. អនុភាពនៃការលែងលះ ចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ ..................... ៤១
៣.៣.២. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ ..................... ៤២
៣.៣.៣. អនុភាពនៃការលែងលះចំពោះកូន ..................... ៤៣

## សេចក្តីសន្និដ្ឋាន និង អានុសាសន៍

**សេចក្តីសន្និដ្ឋាន** ..................... ៤៧
**អនុសាសន៍** ..................... ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

នៅក្នុងសកលលោកជាធម្មជាតិជាអ្នកបង្កើតអោយមានមនុស្សប្រុស និងមនុស្សស្រី ហើយមនុស្សប្រុស និងមនុស្សស្រីនេះទៀតសោត ពេលដែលចំរើនវ័យកម្លោះក្រមុំត្រូវមានតួនាទីបង្កើតគ្រួសារជាមួយគ្នា ដើម្បីបន្តពូជន៍ពង្សវង្សត្រកូលដោយបង្កើតអោយមានកូនចៅជំនាន់ក្រោយបន្តទៅទៀតក្នុងសង្គម។ ដើម្បីរួមរស់ និងបង្កើតគ្រួសារជាមួយគ្នាបាន បុរស និង នារីត្រូវតែមានការបង្កើតចំណងអាពាហ៍ពិពាហ៍ ជាមុនសិន ហើយចំណងអាពាហ៍ពិពាហ៍នោះអាចកើតឡើង លុះត្រាតែមានសេចក្តីស្រលាញ់ចំពោះគ្នាទៅវិញទៅមករវាងមនុស្សប្រុស និងមនុស្សស្រី ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសដែលមានអរិយធម៌សម្បូរបែបមិនទទួលការរស់នៅជាអនីតិសង្វាសឡើយ។ តាំងពីសម័យបុរាណមក ការរៀបចំការរៀបអាពាហ៍ពិពាហ៍ត្រូវបានប្រារព្ធធ្វើតាមបែបសាសនា ប្រពៃណី ទំនៀមទំលាប់ ដោយមិនបានចុះសំបុត្រអាពាហ៍អាពាហ៍តាមផ្លូវច្បាប់ទេ ប៉ុន្តែគេអាចសម្គាល់ថា មនុស្សប្រុស និងមនុស្សស្រីមានបំណងចង់រស់នៅជាមួយគ្នាជាប្តីប្រពន្ធជាមួយគ្នាដោយស្របច្បាប់បាន។ ចំណែកសម័យបច្ចុប្បន្នវិញ ដើម្បីទទួលបានសិទ្ធិជាប្តីប្រពន្ធជាមួយគ្នាស្របច្បាប់ គឺគេត្រូវការរៀបចំពិធីគឺតាមបែបសាសនា ប្រពៃណីទំនៀបទំលាប់ ហើយនិងចុះសបុត្រអាពាហ៍ពិពាហ៍ដោយបំពេញទៅតាមអ្វីដែលច្បាប់កំណត់ ទើបអាពាហ៍ពិពាហ៍នោះមានលក្ខណៈស្របច្បាប់។ ទន្ទឹមនឹងការរៀបចំអាពាហ៍ពិពាហ៍ ក៏មានគូស្វាមីភរិយាមួយចំនួននៅពេលដែលបានរួមរស់ជាមួយគ្នាអស់រយៈពេលច្រើនឆ្នាំហើយ ក៏មានបញ្ហាកើតឡើងដែរ រស់នៅមិនចុះសម្រុងនឹងគ្នាមានភាពរកាំរកូស និង ឈ្លោះប្រកែកគ្នា ហើយផិតក្បត់គ្នា ឬ អស់មនោសញ្ចេតនានឹងគ្នាជាដើម។ ហើយមានបញ្ហាទាំងអស់នេះជារៀងរាល់ថ្ងៃ ហើយគ្មានការដោះស្រាយនឹងគ្នាយូរៗទៅ ក៏បណ្តាលអោយ គូភាគីអស់មនោសញ្ចេតនានឹងគ្នា ហើយនឹងនាំអោយមានឈានដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ដែលហៅថា "ការលែងលះ"។ នៅពេលមានការលែងលះកើតឡើង ធ្វើអោយមានផលវិបាកជាច្រើនដល់គ្រួសារ ជាពិសេសគឺប៉ះពាលដល់អារម្មណ៍កូនៗរបស់ពួកគេ ដោយសារមានការចែកទ្រព្យសម្បត្តិ និងការបែកចែកកូន ជាដើម។ ម៉្យាងវិញទៀតការលែងលះគ្នា ត្រូវឆ្លងកាត់ដំណាក់កាលជាច្រើន ហើយអាចឈានដល់ដំណាក់កាលតុលាការទៀតផង ។

អាស្រ័យហេតុនេះហើយ ទើបក្រុមយើងខ្ញុំលើកយកប្រធានបទដែលទាក់ទងទៅនឹង "អាពាហ៍ពិពាហ៍ និងការលែងលះ" នេះយកមកបកស្រាយ។ ដោយសារប្រធានបទនេះអាចជួយកែប្រែរាល់ការអនុវត្តដែលមិនបានមួយចំនួន នឹងដើម្បីចែករំលែកអោយមហាជនទាំងអស់បានស្វែងយល់កាន់តែច្បាស់ថែមទៀត ។

## ២.ចំណោទបញ្ហា

ដើម្បីអោយអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅដោយស្របច្បាប់ តើត្រូវបំពេញនូវលក្ខខណ្ឌគតិយុត្តអ្វីខ្លះ? តើមានមូលហេតុអ្វីខ្លះ ? ដែលនាំអោយមានការលែងលះគ្នា ?

នៅពេលមានវិវាទអាពាហ៍ពិពាហ៍កើតឡើង តើស្ថាប័នណាខ្លះដែលមានសមត្ថកិច្ចដោះស្រាយ? តើនីតិវិធីក្នុងការដោះស្រាយប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ ដើម្បីអោយការលែងលះនោះមានអានុភាពគតិយុត្ត?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃប្រធានបទ គឺដើម្បីអោយការរៀបអាពាហ៍ពិពាហ៍ និងការលែងលះអាចប្រព្រឹត្តទៅរលូន និងស្របច្បាប់កំណត់ ហើយម៉្យាងវិញទៀតចង់អោយអាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីភារកិច្ចទាក់ទងទៅនិងផ្នែកនេះ អាចអនុវត្តការងារអោយបានម៉ត់ចត់នឹងយកចិត្តទុកដាក់ចំពោះការងារ ដើម្បីផ្តល់ភាពងាយស្រួលនឹងបង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋដែលមានបញ្ហាទាំងអស់នោះ ។

ការចូលរួមការអនុវត្តពីស្ថាប័នដែលពាក់ព័ន្ធនឹងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ដែលជារឿងដែលចាំបាច់បំផុត ដើម្បីអោយសង្គមមានការអភិវឌ្ឍន៏រីកចម្រើនទៅមុខខ្លាំង។ ដូចនេះ អាជ្ញាធរដែលមានភារកិច្ចទាក់ទងនឹងផ្នែកនេះមិនត្រូវធ្វេសប្រហែសចំពោះការងាររបស់ខ្លួនឡើយ ។

ការរួមគ្នាអនុវត្តច្បាប់អោយបានត្រឹមត្រូវទាំងអាជ្ញាធរ នឹងប្រជាពលរដ្ឋ គឺជាចំណែកមួយដ៏សំខាន់ ដើម្បីអោយប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាយើងមានភាពរឹងមាំ ហើយនឹងមានភាពរីកចំរើនទៅមុខយ៉ាងឆាប់រហ័ស។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទខាងលើនេះ មានដែនកំណត់ស្ថិតក្រោម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ នឹងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ។ ហើយប្រធានបទស្តីពី អាពាហ៍អាពាហ៍ និងការលែងលះ នេះមានវិសាលភាពគ្របដណ្តប់ទៅលើផ្នែកនៃ នីតិអាពាហ៍អាពាហ៍ និងគ្រួសារក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈប្រយោជន៍នៃប្រធានបទនេះ គឺដើម្បីអោយមហាជនក៏ដូចជាសិស្សានុសិស្ស និងនិស្សិតបញ្ញាវន្តទាំងអស់បានយល់ដឹងកាន់តែច្បាស់ ពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍មួយអោយមានលក្ខណៈស្របទៅតាមច្បាប់របស់ប្រទេសកម្ពុជាយើង ដើម្បីចៀសវាងការរៀបអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមគោលការណ៍ច្បាប់គំរូ ព្រោះអាចនាំអោយមានបញ្ហាទៅថ្ងៃខាងមុខ។ ម៉្យាងវិញទៀត ប្រជាពលរដ្ឋទាំងអស់ត្រូវយល់ដឹងអោយកាន់តែច្បាស់អំពីនីតិវិធីនៃការលែងលះផងដែរ។ ចៀសវាង នៅពេលមានវិវាទអាពាហ៍ពិពាហ៍កើតឡើង យើងមិនដឹងថារកស្ថាប័នណាមួយអោយជួយដោះស្រាយ ហើយយើងមិនដឹងពីបែបបទក្នុងការដោះស្រាយបញ្ហាជាដើម ។

ជាងនេះទៅទៀតការរៀបចំចងក្រងអំពីប្រធានបទនេះ ដើម្បីចូលរួមក្នុងចំណែកអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅព្រះរាជាណាចក្រកម្ពុជាអោយកាន់តែមានភាពរីកចម្រើនប្រសើរឡើង។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទខាងលើនេះ យើងខ្ញុំបានខិតខំស្រាវជ្រាវ ដើម្បីប្រមូលនូវឯកសារមួយចំនួន និងច្បាប់ពាក់ព័ន្ធនៃការស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណេតរួមទាំងចំណេះដឹងដែលទទួលបានពីលោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យ ដើម្បីធ្វើការចងក្រងបង្កើតស្នាដៃនេះឡើង ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ "អាពាហ៍ពិពាហ៍ និងការលែងលះ" យើងខ្ញុំបានធ្វើការបែកចែកជា ៣ ជំពូកមានដូចខាងក្រោមគឺ៖

ជំពូកទី១ សញ្ញាណគតិយុត្តនៃអាពាហ៍ពិពាហ៍

១.១. កំជាប់ពាក្យ

១.២. លក្ខខណ្ឌបង្កើតអាពាហ៍ពិពាហ៍

ជំពូកទី២ វិការៈ និងអានុភាពនៃអាពាហ៍ពិពាហ៍

២.១. វិការៈនៃអាពាហ៍ពិពាហ៍

២.២. អានុភាពនៃអាពាហ៍ពិពាហ៍

ជំពូកទី៣ ការលែងលះនៃអាពាហ៍ពិពាហ៍

៣.១. មូលហេតុនៃការលែងលះ

៣.២. នីតិវិធីនៃការលែងលះ

៣.៣. អានុភាពនៃការលែងលះ

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃអាពាហ៍ពិពាហ៍

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃអាពាហ៍ពិពាហ៍

នៅពេលខ្លះមុននឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍ បុរស និង នារី បានសម្រេចចិត្តភ្ជាប់ពាក្យជាមួយគ្នាសិន។ តាមការពិត ការធ្វើកំជាប់ពាក្យនិងនាំឱ្យមានអានុភាពគតិយុត្ត ដែលនឹងត្រូវលើកយកមកបង្ហាញដូចខាងក្រោមនេះ។

## ១.១. កំជាប់ពាក្យ

កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្តីសន្យារវាងបុរស និង នារី ថានិងរៀបអាពាហ៍ពិពាហ៍និងគ្នានៅពេលអនាគត និងដោយធ្វើពិធីកំជាប់ពាក្យ។[១]

### ១.១.១. ធាតុផ្សំកំជាប់ពាក្យ

ផ្អែកតាមនិយមន័យនៃកំជាប់ពាក្យដូចខាងលើ ឃើញថា ធាតុផ្សំនៃកំជាប់ពាក្យរួមមាន :

- ការព្រមព្រៀងរវាងបុរស និង នារី។
- ពិធីកំជាប់ពាក្យ : ពិធីកំជាប់ពាក្យត្រូវធ្វើតាមរបៀបយ៉ាងដូចម្តេចនោះ គឺអាស្រ័យទៅតាមប្រពៃណីទំនៀមទម្លាប់ និងការជ្រើសរើសរបស់គូភាគីតែប៉ុណ្ណោះ ។

ជាក់ស្តែង ក្រមរដ្ឋប្បវេណីមិនបានកំណត់ពីអាយុរបស់នាក់ធ្វើកំជាប់ពាក្យទេ។ នេះបានន័យថាអាយុប៉ុន្មានក៏អាចធ្វើកំជាប់ពាក្យដែរ **ឱ្យតែអាចផ្តល់ការព្រមព្រៀងបាន**។ ហេតុដូច្នេះ ប្រសិនបើជាអនីតិជន ត្រូវមានការយល់ព្រម ឬ ការអនុញ្ញាតពី ឪពុកម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ក្នុងន័យនេះ គឺគួរគប្បីកំណត់អាយុយ៉ាងហោចណាស់ ១៤ ឆ្នាំ ពីព្រោះថាជាអាយុដែលច្បាប់បានកំណត់ថា អាចទទួលខុសត្រូវរដ្ឋប្បវេណីបាន។[២]

### ១.១.២. ការរំលាយកំជាប់ពាក្យ

ជាការពិតណាស់ ប្រសិនបានកំជាប់ពាក្យមិនត្រូវបានរំលាយទេ ទំនាក់ទំនងរវាងបុរស និង នារីដែលបានភ្ជាប់ពាក្យជាមួយគ្នា នឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែផ្ទុយទៅវិញ កំជាប់ពាក្យអាចត្រូវរលាយ ដែលជាមូលហេតុមិនអាចឱ្យអាពាហ៍ពិពាហ៍ប្រព្រឹត្តទៅបានឡើយ។ ជារួមមក កំជាប់ពាក្យអាចត្រូវរលាយដោយមូលហេតុបីយ៉ាងគឺ :

- មរណភាពរបស់បុរស ឬ នារី ។
- ការព្រមព្រៀងរបស់គូភាគី ។
- ការផ្តាច់កំជាប់ពាក្យដោយភាគីម្ខាង ៖ ក្នុងករណីនេះគេត្រូវបែងចែកជាពីរសម្មតិកម្មគឺ ៖

---

[១] មាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[២] មាត្រា ៧៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ក. ការរំលាយកំជាប់ពាក្យដោយមានមូលហេតុត្រឹមត្រូវ**

ប្រសិនបើយ៉ាងដូច្នេះ ភាគីដែលបានលើកជំនូននៅពេលកំជាប់ អាចទាមទារឱ្យសងជំនូនវិញបាន។[៣]

**ជំនូន** សំដៅលើប្រទានកម្មដែលភាគីម្ខាងជូនដល់ភាគីម្ខាងទៀត ដោយសារតែកំជាប់ពាក្យ **ឧទាហរណ៍ដូចជា** ចិញ្ចៀនភ្ជាប់ពាក្យ ជាដើម។ ចំណែកឯប្រាក់ដែលភាគីម្ខាងផ្តល់ឱ្យភាគីម្ខាងទៀត ដើម្បីរៀបពិធីកំជាប់ពាក្យ មិនគួរចាត់ទុកជាជំនូននោះទេ ពីព្រោះថា ប្រាក់ទាំងនេះនិងត្រូវយកមកចាត់ចែង ដើម្បីធ្វើពិធីកំជាប់ពាក្យ ដើម្បីជាប្រយោជន៍ដល់ភាគីទាំងសងខាង ។

គួរធ្វើការកត់សម្គាល់ថា ភាគីដែលបានទទួលជំនូន ត្រូវសងជំនូននេះទៅភាគីម្ខាងទៀត។ ដូចនេះ ប្រសិនបើភាគីទាំងសងខាង បានទទួលជំនូនពីគ្នាទៅវិញទៅមក គឺត្រូវសងជំនូននេះឱ្យគ្នាទៅវិញទៅមកដែរ។

**ឧទាហរណ៍៖** បុរស **ក.** និង នារី **ខ.** បានព្រមព្រៀងភ្ជាប់ពាក្យជាមួយគ្នាដោយបានធ្វើពិធីកំជាប់ពាក្យ។ ក្រោយមកនារី **ខ.** បានដឹងថា បុរស **ក.** មានទំនាក់ទំនងស្នេហាជាមួយនឹងនារីផ្សេងទៀត។ ហេតុដូច្នេះហើយនារី **ខ.** បានសម្រេចចិត្តផ្តាច់ពាក្យវិញ (រំលាយកំជាប់ពាក្យ)។ មូលហេតុដែលនាំឱ្យនារី **ខ.** ផ្តាច់ពាក្យ គឺជាមូលហេតុត្រឹមត្រូវ ហេតុនេះ បុរស **ក.** គ្រាន់តែអាចទាមទារឱ្យនារី **ខ.** សងជំនូនមកខ្លួនវិញតែប៉ុណ្ណោះ ដោយមិនអាចទាមទារឱ្យនារី **ខ.** បង់ប្រាក់សំណងជម្ងឺចិត្តណាមួយនោះទេ។

**ខ. ការរំលាយកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ**

- ✓ ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យអាចទាមទារឱ្យសងជំនួសវិញបាន
- ✓ ភាគីម្ខាងទៀត (ភាគីដែលមិនបានរំលាយកំជាប់ពាក្យ) អាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការបដិសេធកំជាប់ពាក្យ។[៤]

**ឧទាហរណ៍** ៖ បុរស **ក.** និង នារី **ខ.** បានព្រមព្រៀងភ្ជាប់ពាក្យជាមួយគ្នាដោយបានធ្វើពិធីកំជាប់ពាក្យ។ ក្រោយមកនារី **ខ.** ក៏ស្រឡាញ់ពេញចិត្តនឹងបុរសម្នាក់ទៀត ហើយក៏សម្រេចចិត្តផ្តាច់ពាក្យពីបុរស **ក.** វិញ។ នៅក្នុងករណីនេះ នារី **ខ.** បានរំលាយកំជាប់ពាក្យ ដោយគ្មានមូលហេតុត្រឹមត្រូវ។ ហេតុដូច្នេះ បុរស **ក.** មានសិទ្ធទាមទារៈ

១. ឱ្យនារី ខ សងជំនូនដែលនារី ខ បានទទួល ដូចជាចិញ្ចៀនភ្ជាប់ពាក្យជាដើម ។

២. ឱ្យនារី ខ សងប្រាក់សំណងនៃការខូចខាត រួមមានដូចជាថ្លៃរៀបចំពិធីកំជាប់ពាក្យ ចំណាយផ្សេងៗដែលបានធ្វើ ដោយសារតែកំជាប់ពាក្យ ការបាត់បង់កិត្តិយស ។ល។

**សម្គាល់៖** នារី **ខ.** ក៏អាចទាមទារឱ្យបុរស **ក.** សងជំនូនមកខ្លួនបានដែរដូចជាចិញ្ចៀនភ្ជាប់ពាក្យជាដើម។

សូមបញ្ជាក់ថា បណ្តឹងទាមទារដូចខាងលើនេះ ត្រូវតែធ្វើក្នុងអំឡុងពេល **១ ឆ្នាំ** គិតចាប់ពីពេលរំលាយកំជាប់ពាក្យ។[៥]

---

[៣] មាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[៤] មាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[៥] មាត្រា ៩៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍៖** បុរស **ក.** និងនារី **ខ.** បានព្រមព្រៀងភ្ជាប់ពាក្យជាមួយគ្នាដោយបានធ្វើពិធីកំជាប់ពាក្យ។ ឧបមាថា ក្រោយមក នារី**ខ.** បានធ្វើការសម្រេចចិត្តធ្វើការរំលាយកំជាប់ពាក្យរវាងរូបនាង និង បុរស**ក.** នៅថ្ងៃទី ០២ ខែមករា ឆ្នាំ២០១២។ ក្នុងករណីដូចនេះ បុរស **ក.** ត្រូវតែធ្វើបណ្តឹងទាមទារ ដោយផ្អែកលើការរំលាយកំជាប់ពាក្យ មិនឱ្យហួសពីថ្ងៃពី ០២ ខែ មករា ឆ្នាំ ២០១៣។ បើមិនដូច្នោះទេ បណ្តឹងរបស់គាត់និងត្រូវហួសអាជ្ញាយុកាលបានសេចក្តីថា តុលាការនឹងមិនអាចសម្រេចទៅលើការទាមទាររបស់បុរស ក ពាក់ព័ន្ធនឹងការឱ្យសងជំនួន ឬ សំណងនៃការខូចខាតបាននោះឡើយ ។

## ១.២. លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយមានអានុភាពតាមផ្លូវច្បាប់ ក្រមរដ្ឋប្បវេណីបានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលត្រូវគោរព។ ជារួមមក មានលក្ខខណ្ឌចំនួន ៦ ដែលត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី។

### ១.២.១. លក្ខខណ្ឌអាយុ

ក្រមរដ្ឋប្បវេណីបានកំណត់នូវអាយុជាក់លាក់ ដែលអាចនឹងរៀបអាពាហ៍ពិពាហ៍បាន។[៦] ជាដំបូង ភាគីដែលបានដល់នីតិភាពហើយ អាចរៀបអាពាហ៍ពិពាហ៍បាន។ ភាគីបានដល់នីតិភាព នៅពេលគាត់បានដល់អាយុ ១៨ ឆ្នាំ ឬ ទទួលបាននូវអត្តាធីនភាព។ អនីតិជននិងទទួលបាននូវអត្តាធីនភាព នៅក្នុងករណីពីរយ៉ាងគឺ ៖

- តាមដីកាសម្រេចរបស់តុលាការ តាមពាក្យសុំរបស់អតីតិជនដែលបានដល់អាយុ ១៦ ឆ្នាំ ។
- តាមរយៈការរៀបអាពាហ៍ពិពាហ៍របស់នីតិជននោះ ។

**ឧទាហរណ៍៖** ធីតា មានអាយុ ១៦ ឆ្នាំ ហើយនាងអាចទ្រទ្រង់ជីវភាពរបស់ខ្លួនឯងបានដោយមិនចាំបាច់ពឹងពាក់ឪពុកម្តាយរបស់នាងឡើយ។ ក្នុងករណីនេះប្រសិនបើនាងចង់បានអត្តាធីនភាព នាងត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅដ្ឋានរបស់នាង ដើម្បីស្នើសុំអត្តាធីនភាពនេះ[៧] ក្រោយពីនាងទទួលបានអត្តាធីនភាពហើយ ប្រសិនបើនាងចង់រៀបអាពាហ៍ពិពាហ៍ គឺនាងមិនចាំបាច់ស្នើសុំការយល់ព្រមពីឪពុកម្តាយរបស់នាងឡើយ ។

**ឧទាហរណ៍៖** ណារី មានអាយុ ១៦ ឆ្នាំ ។ នាងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹង សំណាង ដោយមានការយល់ព្រមពីឪពុកម្តាយរបស់នាង។ ក្រោយពីបានចុះសំបុត្រអាពាហ៍ពិពាហ៍រួចហើយ ណារី ទទួលបាននូវអត្តាធីនភាពដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់ស្នើសុំដីការសម្រេចពីតុលាការឡើយ។ ឧបមាថា ៦ ខែក្រោយមក សំណាង ក៏បានស្លាប់បាត់បង់ជីវិតដោយសារគ្រោះថ្នាក់ចរាចរណ៍។ ក្នុងករណីនេះ ណារី នាងមានអាយុមិនដល់ ១៧ ឆ្នាំទេ ក៏ប៉ុន្តែ ប្រសិនបើនាងចង់រៀបអាពាហ៍ពិពាហ៍ទៀត នាងអាចធ្វើបាន ដោយមិនចាំបាច់ស្នើសុំការយល់ព្រមពីឪពុកម្តាយនាងទៀតទេ ។

ជាងនេះទៅទៀត ប្រសិនបើភាគីម្ខាងនៃអាពាហ៍ពិពាហ៍គឺជាអនីតិជនត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បានគឺ៖

---

[៦] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧មាត្រា ៩៤៨ នៃ

[៧] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

- អនីតិជននេះមានអាយុចាប់ពី ១៦ ឆ្នាំ ឡើងទៅ ចំពោះភាគីដែលជាអនីតិជន ត្រូវតែមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា (អ្នកមានអំណាចមេបាតែម្ខាងយល់ព្រមជាការគ្រប់គ្រាន់ហើយ) ឬអ្នកអាណា-ព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រម ដោយគ្មានមូលហេតុសមរម្យ **អនីតិជនអាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តី ជំនួសការយល់ព្រមនោះបាន។**[៤] ក្នុងករណីនេះតុលាការនៃលំនៅដ្ឋានរបស់អនីតិជន ជាតុលាការមានសមត្ថកិច្ច ហើយសម្រេចសេចក្តីដោយចេញជាដីកាសម្រេចដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។
- ភាគីម្ខាងទៀតបានដល់នីតិភាព (ដូចការពន្យល់ខាងលើ)។

**ឧទាហរណ៍៖** ចិន្តា មានអាយុ ១៦ ឆ្នាំ បានស្រឡាញ់ ភារម្យ ដែលមានអាយុ ១៩ ឆ្នាំ ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ក្នុងករណីនេះ ដើម្បីអាចរៀបការបានត្រូវតែមានការយល់ព្រមពីឪពុកម្តាយរបស់ចិន្តា។ ប្រសិនបើមានត្រឹមតែការយល់ព្រមពីឪពុក ឬ ម្តាយរបស់ចិន្តា តែម្ខាងក៏បានដែរ។ ក៏ប៉ុន្តែ ប្រសិនបើឪពុក និង ម្តាយរបស់ចិន្តា បានបដិសេធ ចិន្តា អាចមានជម្រើសបីយ៉ាងគឺ :

①. រង់ចាំឱ្យរូបនាងបានដល់អាយុ ១៨ ឆ្នាំ។

②. ស្នើសុំអត្តាធីនភាពពីតុលាការ។

③. ស្នើសុំឱ្យតុលាការសម្រេចសេចក្តីជំនួសការយល់ព្រមរបស់ឪពុកម្តាយនាង។

### ១.២.២. លក្ខខណ្ឌទាក់ទងនឹងសមត្ថភាព

ភាគីនៃអាពាហ៍ពិពាហ៍ត្រូវតែមានសមត្ថភាពបង្ហាញឆន្ទៈ។ ក៏ប៉ុន្តែជននៅក្រោមអាណាព្យាបាលទូទៅ (**ជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ដូចជាជនវិកលចរិតជាដើម**) អាចរៀបអាពាហ៍ពិពាហ៍បាននៅក្នុងករណីដែលជននោះអាចមានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាដែលចាំបាច់ដើម្បីរៀបអាពាហ៍-ពិពាហ៍។[៥] ក្នុងករណីបែបនេះ ក្រមរដ្ឋប្បវេណីមិនចាំបាច់តម្រូវឱ្យមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។

**ឧទាហរណ៍៖** ដារ៉ា អាយុ ២៨ ឆ្នាំ និង កញ្ញា អាយុ ២២ ឆ្នាំ មានគម្រោងរៀបការជាមួយគ្នា។ ក៏ប៉ុន្តែ មិនទាន់បានរៀបការផង ដារ៉ា ក៏ជួបប្រទះនិងគ្រោះថ្នាក់ចរាចរណ៍ បណ្តាលឱ្យមានការប៉ះទង្គិចដល់បញ្ញាស្មារតីមិនអាចដឹងខុសត្រូវបាន។ ហេតុដូច្នេះហើយទើបមានការប្រកាសដាក់ ដារ៉ា ឱ្យនៅក្រោមអាណាព្យាបាលទូទៅ តាមដីកា សម្រេចរបស់តុលាការ ដោយកំណត់ឱ្យបងប្រុសរបស់ ដារ៉ា ធ្វើជាអ្នកអាណាព្យាបាលទូទៅ របស់ ដារ៉ា។ ក្រោយមក ស្ថានភាពរបស់ ដារ៉ា បានល្អប្រសើរឡើងវិញបន្តិច ក៏ប៉ុន្តែមិនទាន់បានជាសះស្បើយទាំងស្រុងនៅ

[៤] មាត្រា ៩៥៣ កថាខណ្ឌទី២ និង ទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[៥] មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឡើយ។ ក្នុងករណីដែល ដារ៉ា អាចបង្ហាញឆន្ទៈ និងរៀបការជាមួយគ្នាបាន ដោយមិនចាំបាច់មានការយល់ព្រមពីបងប្រុសរបស់ដារ៉ាឡើយ។

ចំពោះជននៅក្រោមហិតូបត្ថម្ភ (**ជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់អំពីសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី**) អាចរៀបអាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់មានកាយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។[១០]

**ឧទាហរណ៍៖** សំភី មានអាយុ ៣០ ឆ្នាំ។ ក្រោយពីជួបប្រទះនូវគ្រោះថ្នាក់ចរាចរណ៍ដែលមានការប៉ះទង្គិចក្បាលរួចមក សំភី បានក្លាយជាមនុស្សដែលមិនសូវដឹងខុសត្រូវដូចពីមុនទេ ប៉ុន្តែវេជ្ជបណ្ឌិតជំនាញបានបញ្ជាក់ថា គាត់មិនមែនមិនដឹងខុសត្រូវទាំងស្រុងទេ គឺដឹងខុសត្រូវតិចតួចតែប៉ុណ្ណោះ។ ក្នុងករណីបែបនេះ គេអាចស្នើសុំឱ្យតុលាការសម្រេចដាក់ សំភី ស្ថិតនៅក្រោមហិតូបត្ថម្ភ តាមដីកាសម្រេចដោយជ្រើសតាំងនរណាម្នាក់ឱ្យធ្វើជាហិតូបត្ថម្ភកៈ(អ្នកគ្រប់គ្រង) របស់ សំភី។ ទោះបីជាក្នុងករណីយ៉ាងនេះក៏ដោយ សំភីអាចរៀបការបានដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។

### ១.២.៣. លក្ខខណ្ឌទាក់ទងនឹងការព្រមព្រៀង

ការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ ត្រូវតែជាការព្រមព្រៀងដោយសេរីពោលគឺមិនមានការបង្ខំ ការគំរាម ការឆបោក ឬ ការភាន់ច្រឡំលើមនុស្សឡើយ។

- **ការបង្ខំ** និង ការភាន់ច្រឡំលើមនុស្ស គឺជាមូលហេតុនៃមោឃភាពអាពាហ៍ពិពាហ៍។[១១]
- **ការគំរាម និង ការឆបោក** គឺជាមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍។[១២]

ក្រមរដ្ឋប្បវេណីមិនបានផ្តល់និយមន័យនៃពាក្យ “ការបង្ខំ” “ការគំរាម” “ការភាន់ច្រឡំលើមនុស្ស” និង “ការឆបោក” ឡើយ។ ប៉ុន្តែ គេអាចកំណត់បានថា **ការបង្ខំ** សំដៅលើករណីជនដែលត្រូវរៀបអាពាហ៍ពិពាហ៍ គ្មានសេរីភាពក្នុងការជ្រើសរើសទាល់តែសោះ ពោលគឺ ការបង្ខំបានធ្វើឱ្យសាមីខ្លួនគ្មានឆន្ទៈនឹងរៀបអាពាហ៍ពិពាហ៍តែម្តង។ ទន្ទឹមនឹងនេះតាមន័យនៃក្រមរដ្ឋប្បវេណី ការបង្ខំមានលក្ខណៈខ្លាំងក្លាយជាការគំរាមមានន័យថា ការបង្ខំមានលក្ខណៈដាច់ណាត់ជាងការគំរាម ត្រង់ថាការបង្ខំធ្វើឱ្យសាមីខ្លួនគ្មានឆន្ទៈជ្រើសរើស ក៏ប៉ុន្តែសម្រាប់ការគំរាមវិញសាមីខ្លួនជ្រើសរើសរៀបការព្រោះតែការភ័យខ្លាច។

**ចំណែកឯការភាន់ច្រឡំលើមនុស្សវិញ** សំដៅលើកណីនៃការភាន់ច្រឡំលើអត្តសញ្ញាណរបស់មនុស្ស។ល។

**ឧទាហរណ៍៖** ការភាន់ច្រឡំលើកូនភ្លោះជាដើម ។

**ការគំរាម** គឺជាមធ្យោបាយខុសច្បាប់តាមរយៈការជូនដំណឹងពីភាពអាក្រក់ទៅភាគីម្ខាងទៀត ក្នុងគោលដៅឱ្យជននោះមានការភ័យខ្លាច ហើយយល់ព្រមរៀបអាពាហ៍ពិពាហ៍។

---

[១០] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[១១] មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[១២] មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍៖** សុភាព ត្រូវបានម្ដាយរបស់នាងគំរាមថា នឹងកាត់កាល់នាងចោលប្រសិនបើនាងមិនយល់ព្រមរៀបការជាមួយភក្ដីទេនោះ។

**ការឆបោក** គឺជាការបោកប្រាស់ឱ្យជនណាម្នាក់ធ្លាក់ទៅក្នុងការភាន់ច្រឡំហើយយល់ព្រមរៀបការ។

ឧទាហរណ៍៖ ណារ៉ា បានយល់ព្រមរៀបការជាមួយនឹង សុភាព ដោយសារតែ សុភាព បានធ្វើឱ្យនាងជឿជាក់ថា គាត់គឺជាសេដ្ឋីម្នាក់ តាមរយៈពាក្យសម្ដី ការបង្ហាញពីភាពហ៊ឺហា មានអង្គរក្សមានអ្នកបម្រើជាច្រើនជាដើម។

**១.២.៤. លក្ខខណ្ឌឯកពន្ធភាព**

បុគ្គលដែលមានសហព័ន្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ[១៣] ការបំពានលក្ខខណ្ឌនេះគឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤ និងមាត្រា ៩ នៃច្បាប់ស្ដីពីឯកព័ន្ធភាព (ទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ១ ឆ្នាំ និង/ឬពិន័យជាប្រាក់ពី២សែនរៀល ទៅ ២លានរៀល អំពើដែលចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី មុនការរំលាយអាពាហ៍ពិពាហ៍ចាស់។[១៤]

**១.២.៥. លក្ខខណ្ឌទាក់ទិននឹងទំនាក់ទំនងញាតិ**

បុគ្គលដែលមានទំនាក់ទំនងញាតិមួយចំនួន ត្រូវបានហាមឃាត់មិនឱ្យធ្វើការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាឡើយ។

- ហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ បើទោះបីជាក្រោយពេលដែលទំនាក់ទំនងញាតិត្រូវបានបញ្ចប់ដោយការបញ្ចប់ញាតិ។ ជាមួយឪពុកម្ដាយបង្កើតដោយសារសុំកូនពេញលេញ ឬដោយសារការកាត់កាល់សុំកូនពេញលេញ ឬដោយសារការកាត់កាល់សុំកូនធម្មតា។[១៥]

**ឧទាហរណ៍៖** នៅពេលដែល ដានី មានអាយុ ៧ ឆ្នាំ ឪពុកម្ដាយបង្កើតរបស់ ដានី បានឱ្យ ដានី ទៅអ្នកដទៃចិញ្ចឹមតាមរយៈ **សុំកូនពេញលេញ**។ ក្នុងករណីបែបនេះ ទំនាក់ទំនងញាតិរវាង ដានី និងឪពុកម្ដាយបង្កើតត្រូវបញ្ចប់ តាមមាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណី។ ទោះជាយ៉ាងនេះក្ដី នៅពេលដែល ដានី ពេញវ័យ នាងមិនអាចរៀបការជាមួយនឹងឪពុកបង្កើតរបស់នាងបានឡើយ។

**ឧបមាថា** ក្រោយមក ទំនាក់ទំនងរវាង ដានី និងឪពុកម្ដាយចិញ្ចឹមរបស់នាងត្រូវបានកាត់ផ្ដាច់តាមរយៈការកាត់កាល់។ ដូចនេះ នាង និងឪពុកម្ដាយចិញ្ចឹមរបស់នាងលែងជាញាតិនឹងគ្នាទៀតហើយ។ ទោះជាយ៉ាងនេះក្ដី នាងមិនអាចរៀបការជាមួយនឹងអតីតឪពុកចិញ្ចឹមនាងបានឡើយ។

**ឧទាហរណ៍៖** នៅពេលដែល ចន្ថា មានអាយុ ២០ ឆ្នាំ នាងបានព្រមព្រៀងបង្កើត សុំកូនធម្មតា ជាមួយនឹង ដារ៉ា អាយុ ៤០ ឆ្នាំ។ ក្នុងករណីនេះ ចន្ថា មានទំនាក់ទំនងផ្លូវច្បាប់ជាមួយនឹងឪពុកម្ដាយបង្កើតរបស់នាងផង និងមានទំនាក់ទំនងផ្លូវច្បាប់ជាមួយនឹង ដារ៉ា ផងដែរ។ លុះក្រោយមក ក៏មានការកាត់កាល់ទំនាក់ទំនងសុំកូន

[១៣] មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[១៤] ច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ២០០៦ មាត្រា ៤ និង មាត្រា ៩

[១៥] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥១

ធម្មតារវាង ចន្ថា និង ដារ៉ា។ នេះមានន័យថា រវាង ចន្ថា និង ដារ៉ា លែងជាឪពុកចិញ្ចឹម និងកូនទៀតហើយ។ ទោះបីជាយ៉ាងនេះក្តី ចន្ថា មិនអាចរៀបការជាមួយនឹង ដារ៉ា បានជាដាច់ខាត។

- ហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិតក្នុងបីថ្នាក់ ទោះបីជាក្រោយពេលដែលទំនាក់ទំនងញាតិត្រូវបានបញ្ចប់ដោយការបញ្ចប់ញាតិជាមួយឪពុកម្តាយបង្កើតដោយសារសុំកូនពេញលេញ ឬដោយសារការកាត់កាល់សុំកូនពេញលេញ ឬដោយសារការកាត់កាល់សុំកូនធម្មតា។[១៦]

**ឧទាហរណ៍៖** បងប្អូនបង្កើត (សាខាញាតិថ្នាក់ទី ២) មាមីង និង ក្មួយ (សាខាញាតិថ្នាក់ញាតិទី ៣) គឺមិនអាចរៀបការជាមួយគ្នាបានទេ។

- ហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ (គ្រប់ថ្នាក់ទាំងអស់) ទោះបីជាទំនាក់ទំនងញាតិពន្ធ ត្រូវបានបញ្ចប់ ដោយការលែងលះដោយសារមរណភាពរបស់សហព័ទ្ធម្ខាង ឬដោយសារការកាត់កាល់សុំកូនពេញលេញក៏ដោយ។[១៧]

**ឧទាហរណ៍៖** សំខាន់ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹង កញ្ញា។ ប៉ុន្តែក្រោយមក សំខាន់ បានទទួលមរណភាព។ ទោះបីជាយ៉ាងនេះក្តី កញ្ញា នៅតែមិនអាចរៀបការជាមួយនឹងឪពុក សំខាន់ បានឡើយ ពីព្រោះថា កញ្ញា និង ឪពុករបស់សំខាន់ គឺជាឪពុកក្មេក និងកូនប្រសារ (ញាតិពន្ធនៃខ្សែផ្ទាល់ថ្នាក់ទី ១)។

**ឧទាហរណ៍៖** ធីតា គឺជាកូនសុំពេញលេញរបស់ ចិន្តា។ បន្ទាប់មក ធីតា បានរៀបការជាមួយនឹង បញ្ញា។ ក្រោយមកមួយរយៈ ទំនាក់ទំនងរវាង ធីតា និងម្តាយចិញ្ចឹមរបស់នាង (ចិន្តា) ត្រូវបានកាត់ផ្តាច់ដោយសារការកាត់កាល់ ហើយ ធីតា ក៏បានលែងលះជាមួយនឹង បញ្ញា ផងដែរ។ ក្នុងករណីនេះ ធីតា លែងជាកូនសុំរបស់ ចិន្តា ទៀតហើយ។ ទោះជាយ៉ាងនេះក្តី បញ្ញា មិនអាចរៀបការជាមួយនឹង ចិន្តា ដែលជាអតីតម្តាយក្មេកបានឡើយ។

- ហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ នៅក្នុង ៣ ថ្នាក់រាប់ទាំងថ្នាក់ទី ៣ ផង ទោះបីបានបញ្ចប់ញាតិពន្ធដោយសារការលែងលះក៏ដោយ។ ក៏ប៉ុន្តែ បើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់អាចរៀបការជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិនៅក្នុង ៣ ថ្នាក់បាន។[១៨]

**ឧទាហរណ៍៖** ធីតា បានរៀបការជាមួយនឹង សំខាន់។ ធីតា មានប្អូនស្រីបង្កើតម្នាក់ឈ្មោះ ណារី។ ក្រោយមក អ្នកទាំងពីរបានលែងលះគ្នា។ ហេតុនេះ ទំនាក់ទំនងសាខាញាតិពន្ធរវាង សំខាន់ និងណារី (សាខាញាតិពន្ធថ្នាក់ទី ២) បានរលត់ហើយ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ សំខាន់ មិនអាចរៀបការជាមួយនឹង ណារី បានដែរ។ ប៉ុន្តែ នៅក្នុងសម្មតិកម្មដដែលនេះ ប្រសិនបើ ធីតា បានស្លាប់បាត់បង់ជីវិតវិញ សំខាន់ អាចរៀបការជាមួយនឹង ណារីបាន។

[១៦] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥១

[១៧] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥២ កថាខណ្ឌទី ១

[១៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥២ កថាខណ្ឌទី២

**ឧទាហរណ៍៖** ធីតា បានរៀបការជាមួយនឹង សំខាន់។ ធីតា មានក្មួយស្រីម្នាក់ឈ្មោះ ដាវី (សំខាន់ និង ដាវី គឺជាសាខាញាតិពន្ធថ្នាក់ទី ៣ ៖ ពូសាច់ថ្លៃ និងក្មួយ)។ ប្រសិនបើ ធីតា លែងលះជាមួយ សំខាន់ នោះ សំខាន់ មិនអាចរៀបការជាមួយនឹង ដាវី បានទេ ក៏ប៉ុន្តែបើ ធីតា ស្លាប់បាត់បង់ជីវិតវិញ សំខាន់ អាចរៀបការជាមួយនឹង ដាវី បាន។

ការបំពានលក្ខខណ្ឌអាពាហ៍ពិពាហ៍ទាក់ទិននឹងទំនាក់ទំនងញាតិ គឺជាបទល្មើស ស្មន់ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ១ ខែ ទៅ ១ ឆ្នាំ និង/ពិន័យពី ២សែនរៀល ដល់ ១លានរៀល។[១៩] ប៉ុន្តែ អំពើរួមភេទរវាងញាតិលោហិត ឬញាតិពន្ធក្នុង ៣ (បី) ថ្នាក់ ទៅវិញ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ១ ខែ ទៅ ១ ឆ្នាំ និង/ឬ ពិន័យពី ១សែនរៀល ដល់ ២លានរៀល។[២០]

### ១.២.៦. លក្ខខណ្ឌទម្រង់

លក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរតាមបទប្បញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា គឺត្រូវអនុលោមតាមមាត្រា ៩៥៥ ដល់មាត្រា ៩៥៧ នៃក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩.១២.២០០០ ស្តីពីអត្រានុកូលដ្ឋាន។ ការដាក់ពាក្យសុំរៀប អាពាហ៍ពិពាហ៍ និង ការចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលកំណត់ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។[២១]

**ក. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ**

បែបបទនៃការរៀបអាពាហ៍ពិពាហ៍មានដូចតទៅ៖

- ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់នៃលំនៅឋានរបស់នារី។[២២]
- បិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រយៈពេល ១០ ថ្ងៃ នៅលំនៅឋានរបស់បុរស និងនារី ព្រមទាំងនៅឃុំសង្កាត់នៃលំនៅឋានៈរបស់បុរស និងនារី។[២៣] ក្នុងអំឡុងពេល ១០ ថ្ងៃនេះ ញាតិរបស់សាមីខ្លួន ឬ ជនដែលមានប្រយោជន៍ អាចប្តឹងជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍បាន។[២៤]
    - បណ្តឹងជំទាស់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានបញ្ជាក់ពីមូលហេតុនៃការប្តឹងជំទាស់ផង។
    - បណ្តឹងជំទាស់ ត្រូវដាក់ជូនសាលាឃុំសង្កាត់ខាងលំនៅឋានរបស់អនាគតភរិយា។
    - សាលាឃុំសង្កាត់ ត្រូវសម្រេចក្នុងរយៈពេល ០៣ ថ្ងៃ គិតពីថ្ងៃទទួលពាក្យបណ្តឹង។

---

[១៩] ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ មាត្រា ៧ និង មាត្រា ១០

[២០] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា ៣៥២

[២១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៥ កថាខណ្ឌទី២

[២២] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩.១២.២០០០ ស្តីពីអត្រានុកូលដ្ឋាន មាត្រា២៨

[២៣] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩.១២.២០០០ ស្តីពីអត្រានុកូលដ្ឋាន មាត្រា២៩

[២៤] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ១៥

- ប្រសិនបើអ្នកប្ដឹងជំទាស់ ឬ អនាគតគូស្វាមីភរិយាមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់សាលាឃុំ សង្កាត់ សំណុំរឿងត្រូវបញ្ជូនទៅតុលាការ ក្នុងរយៈពេល ០៧ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យបណ្ដឹងទាស់។[២៥]
- តុលាការត្រូវសម្រេចពីបណ្ដឹងជំទាស់ ក្នុងរយៈពេល ០៧ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃបានទទួលសំណុំរឿង។
- សេចក្ដីសម្រេចរបស់តុលាការ គឺជា សាលក្រម ដែលមិនអាចប្ដឹងតវ៉ាបានឡើយ។[២៦]

- ប្រសិនបើមិនមានបណ្ដឹងជំទាស់ ឬ បណ្ដឹងជំទាស់ត្រូវបានដោះស្រាយរួចរាល់ហើយ (**បណ្ដឹងជំទាស់ត្រូវបានបដិសេធចោល**) សាមីខ្លួននឹងចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់នារី។
- កិច្ចសន្យានេះត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ផ្ដិតមេដៃប្ដីប្រពន្ធ និង សាក្សីអាយុគ្រប់ការចំនួន ០២នាក់។[២៧]
- មន្ត្រីអត្រានុកូលដ្ឋាន ប្រគល់ឱ្យសាក្សីខ្លួននូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ០១សន្លឹក និងចេញសេចក្ដីចម្លង តាមការស្នើសុំរបស់ខ្លួន។[២៨]

**ខ. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និង ជនបរទេស នៅបរទេស**

ជាគោលការណ៍ ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅបរទេស ក៏ដូចជារវាងពលរដ្ឋខ្មែរ និង ជនបរទេស នៅឯបរទេស សាមីខ្លួនអាចមានជម្រើសដល់ទៅពីរយ៉ាងគឺ ៖

១. ប្រើប្រាស់នីតិវិធីដែលមានចែងនៅក្នុងច្បាប់នៃប្រទេសដែលសាមីខ្លួនស្នាក់នៅ។ នៅក្នុងករណីនេះ អាពាហ៍ពិពាហ៍នៅឯបរទេសនោះ ដែលបានធ្វើឡើងត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍នៃប្រទេសនោះ ត្រូវបានទទួលស្គាល់យកជាការនៅប្រទេសកម្ពុជា ប្រសិនបើមិនផ្ទុយនឹងច្បាប់របស់ប្រទេសកម្ពុជាទេ។ បន្ទាប់មកលិខិតអាពាហ៍ពិពាហ៍នេះត្រូវយកមកចុះនៅស្ថានទូត ឬ ស្ថានកុងស៊ុលរបស់កម្ពុជាប្រចាំនៅប្រទេសនោះ ឬ យកមកចុះបញ្ជីអាពាហ៍ពិពាហ៍នៅឃុំសង្កាត់នៅប្រទេសកម្ពុជា បើគូស្វាមីភរិយាមកតាំងទីលំនៅនៅកម្ពុជា។ ក្នុងករណីនេះ ស្ថានទូត ស្ថានអគ្គកុងស៊ុល ស្ថានកុងស៊ុល ឬមន្ត្រីអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ត្រូវយកលិខិតថតចម្លងជាផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅចេញពីសំបុត្រអាពាហ៍ពិពាហ៍ថ្មី ឱ្យជននោះយកទៅប្រើប្រាស។[២៩]

[២៥] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ១៧
[២៦] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ១៨
[២៧] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩.១២.២០០០ ស្ដីពីអត្រានុកូលដ្ឋាន មាត្រា៣០
[២៨] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩.១២.២០០០ ស្ដីពីអត្រានុកូលដ្ឋាន មាត្រា៣១
[២៩] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩.១២.២០០០ ស្ដីពីអត្រានុកូលដ្ឋាន មាត្រា៣២

២. ប្រើប្រាស់នីតិវិធីតាមច្បាប់កម្ពុជា ៖

- នីតិវិធីត្រូវធ្វើនៅចំពោះមុខ ឯអគ្គរាជទូត ភារធារី ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ។[៣០]
- ការជូនដំណឹងជាសាធារណៈ (**ការបិទប័ណ្ណប្រកាស**) ត្រូវធ្វើនៅបញ្ជររបស់ការទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ។[៣១]

**ឧទាហរណ៍** ៖ បញ្ញា និងរស្មី គឺជាពលរដ្ឋខ្មែរដែលរស់នៅប្រទេសបារាំង។ ប្រសិនបើអ្នកទាំងពីរមានបំណងរៀបការជាមួយគ្នា ពួកគេមានជម្រើសពីរយ៉ាងគឺ ៖

- រៀបចំបែបបទដើម្បីចុះសំបុត្រអាពាហ៍ពិពាហ៍នៅស្ថានទូតរបស់ប្រទេសកម្ពុជា ប្រចាំនៅប្រទេសបារាំង។

- រៀបចំបែបបទដើម្បីចុះសំបុត្រអាពាហ៍ពិពាហ៍នៅប្រទេសបារាំង តាមច្បាប់របស់ប្រទេសបារាំង។ បន្ទាប់មក ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងមកចុះសៀវភៅអាពាហ៍ពិពាហ៍ នៅស្ថានទូតរបស់ប្រទេសបារាំង ឬបើអ្នកទាំងពីរមករស់នៅប្រទេសកម្ពុជា ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ នៃសាលាឃុំសង្កាត់ដែលពួកគេរស់នៅ។

**គ. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា**

ចំពោះទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចែកចេញជាពីរដំណាក់កាល ៖ ដំណាក់កាលរដ្ឋបាល និង ដំណាក់កាលចុះបញ្ជីអាពាហ៍ពិពាហ៍។

- **ដំណាក់កាលរដ្ឋបាល ៖**

សាមីខ្លួនជនបរទេសត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយភ្ជាប់ជាមួយនូវឯកសារដែលត្រូវដាក់ទៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសនោះប្រចាំនៅប្រទេសកម្ពុជា ដើម្បីឱ្យមានការបញ្ជាក់ពីនីត្យានុកូលភាពនៃឯកសារទាំងនោះ។[៣២] ដំណើរការនៃនីតិវិធីជាបន្តបន្ទាប់មានដូចតទៅ៖

  - ស្ថានទូត ឬស្ថានតំណាងនៃប្រទេសនោះប្រចាំនៅកម្ពុជា បញ្ជូនសំណុំឯកសារទាំងនោះ ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
  - ក្រសួងការបរទេស ពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ ហើយជូនដំណឹងទៅសាមីខ្លួនជនបរទេស ក្នុងរយៈពេលយ៉ាងយូរ ៥ ថ្ងៃការងារ។[៣៣] ព្រមទាំងជូនដំណឹងទៅស្ថានទូត ឬស្ថានតំណាងវិញផងដែរ។
  - ក្រសួងការបរទេស បញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃ។

---

[៣០] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៧ កថាខណ្ឌទី១

[៣១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៧ កថាខណ្ឌទី២

[៣២] អនុក្រឹត្យលេខៈ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ មាត្រា ៦

[៣៣] អនុក្រឹត្យលេខៈ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ មាត្រា ៧

- ក្រសួងមហាផ្ទៃ ត្រូវចុះបញ្ជីសំណុំឯកសារ និងជូនដំណឹងទៅសាមីខ្លួនជនបរទេស ក្នុងរយៈពេល៥ ថ្ងៃការងារ។
- ក្រសួងមហាផ្ទៃជូនដំណឹងពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់នៃ លំនៅឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ។

- **ដំណាក់កាលនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ ៖**
  - សាមីខ្លួនជនបរទេសត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់នៃ លំនៅឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ។
  - ស្របពេលនឹងគ្នានេះ សាមីខ្លួនពលរដ្ឋខ្មែរក៏ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំសង្កាត់ខាងលំនៅឋានរបស់ខ្លួនដែរ ដោយភ្ជាប់ជាមួយនូវឯកសារផ្សេងៗ។[៣៤]
  - មន្ត្រីអត្រានុកូលដ្ឋាននៃនៃឃុំសង្កាត់នៃលំនៅឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ ត្រូវពិនិត្យ និងសម្រេច លើពាក្យស្នើសុំរបស់សាមីខ្លួនទាំងពីរនាក់ក្នុងរយៈពេល ០៣ ថ្ងៃការងារ ។[៣៥]
  - បើពិនិត្យឃើញថា ត្រឹមត្រូវហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ០៥ច្បាប់ ដោយមានបិទរូបថតរបស់សាមីខ្លួនទាំងពីរនាក់នៅផ្នែកខាងលើខាងស្តាំ។
    - ✓ ប័ណ្ណមួយ ត្រូវរក្សាទុកនៅសាលាឃុំសង្កាត់។
    - ✓ ប័ណ្ណដែលនៅសល់ ត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ នៅ ៖
      - ➢ ស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រ កម្ពុជា។
      - ➢ លំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។
      - ➢ សាលាឃុំសង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។
      - ➢ លំនៅឋាន ឬទីកន្លែងស្នាក់នៅរបស់សាមីខ្លួនជនបរទេស ប្រសិនបើមាន។[៣៦]
  - រយៈពេល ១០ ថ្ងៃនេះ គឺជារយៈពេលទុកសម្រាប់ឱ្យមានការប្តឹងជំទាស់ដូចករណីនៃនីតិវិធីនៃការរៀប អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែរ។
  - នីតិវិធីជាបន្តទៀត គឺដូចជានីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែរ បន្ទាប់ពីបានចុះបញ្ជី អាពាហ៍ពិពាហ៍រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើរបាយការណ៍ជាបន្ទាន់ផ្ញើមកក្រសួងមហាផ្ទៃ តាម រយៈក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត។[៣៧]

---

[៣៤] អនុក្រឹត្យលេខ: ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ មាត្រា ៩ កថាខណ្ឌទី២

[៣៥] អនុក្រឹត្យលេខ: ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ មាត្រា ១០ កថាខណ្ឌទី១

[៣៦] អនុក្រឹត្យលេខ: ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ មាត្រា ១០ កថាខណ្ឌទី៣

[៣៧] សេចក្តីណែនាំលេខ ០០១ សណន ចុះថ្ងៃទី១២ ខែ មករា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តអនុក្រឹត្យ ស្តីពីការកំណត់បែបបទ និងនីតិវិធី នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

# ជំពូកទី២

# វិការៈ និងអានុភាពនៃអាពាហ៍ពិពាហ៍

# ជំពូកទី២

## វិការៈ និងអានុភាពនៃអាពាហ៍ពិពាហ៍

| មោឃភាពនៃអាពាហ៍ពិពាហ៍ | ការលុបចោលអាពាហ៍ពិពាហ៍ |
|---|---|
| -ភាពផ្ទុយច្បាប់ ៖ មានកម្រិតខ្ពស់ដែលធ្វើអាពាហ៍ពិពាហ៍**ពុំមានអានុភាពទាល់តែសោះចាប់តាំងពីពេលបង្កើតមក។** | -ភាពផ្ទុយច្បាប់ ៖ មានកម្រិតទាបជាងករណីនៃមោឃភាព ដូចនេះ អាពាហ៍ពិពាហ៍ត្រូវមានអានុភាព រហូតដល់ពេលលុបចោល។ |
| ករណីនៃមោឃភាព ៖ មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី។ | ករណីនៃការលុបចោល ( **មាត្រា ៩៦០ ដល់មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី** ) ៖<br>• មូលហេតុដែលមានលក្ខណៈជាប្រយោជន៍សាធារណៈ<br>• មូលហេតុដែលមានលក្ខណៈជាប្រយោជន៍ឯកជន។ |

### ២.១. វិការៈនៃអាពាហ៍ពិពាហ៍

#### ២.១.១. មោឃភាពនៃអាពាហ៍ពិពាហ៍

**ក. ករណីនៃមោឃភាពអាពាហ៍ពិពាហ៍**

មោឃភាពនៃអាពាហ៍ពិពាហ៍ នៅក្នុងករណីដូចខាងក្រោម ៖

- **គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍** ដែលកើតឡើងដោយសារការបង្ខំ ការភាន់ច្រឡំលើមនុស្ស ឬដោយសារមូលហេតុផ្សេងទៀត។[៣៨]

  **ឧទាហរណ៍ ៖** ការរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ដើម្បីទទួលបានសញ្ជាតិបរទេសណាមួយ ជាដើម។
- **វិការៈធ្ងន់ធ្ងរផ្នែកទម្រង់នៃអាពាហ៍ពិពាហ៍**[៣៩] ៖
  - ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។
  - មិនមានការជូនដំណឹងជាសាធារណៈ (ពុំមានការបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍)។
  - មិនមានការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍។
  - មិនមានការចុះបញ្ជីអាពាហ៍ពិពាហ៍។

[៣៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៨ ចំណុច ក
[៣៩] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៥៨ ចំណុច ខ

**ខ. អានុភាពនៃមោឃភាព**

ប្រសិនបើអាពាហ៍ពិពាហ៍មោឃភាព អាពាហ៍ពិពាហ៍មិនមានអានុភាពទាល់តែសោះ ចាប់តាំងពីពេលបង្កើតអាពាហ៍ពិពាហ៍មក។ ដូចនេះ បណ្ដឹងនៅតុលាការ គឺគ្រាន់តែជាការ ទាមទារឱ្យបញ្ជាក់ពីមោឃភាពអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ មិនមែនជា**បណ្ដឹងទាមទារមោឃភាពអាពាហ៍ពិពាហ៍** ឡើយ។ **បណ្ដឹងទាមទារ ឱ្យបញ្ជាក់ពីមោឃភាពនៃអាពាហ៍ពិពាហ៍** ត្រូវធ្វើឡើងដោយអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុង **ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល** ដោយតុលាការសម្រេចចេញជា **សាលក្រម**។ សម្រាប់បណ្ដឹងប្រភេទនេះ ក្រមរដ្ឋប្បវេណីមិនបានកម្រិតពីបុគ្គលដែលអាចប្ដឹងបាន និងអំឡុងពេលអាជ្ញាយុកាលឡើយ។ ដូចនេះ អាចមានការបកស្រាយថា គ្រប់ជនដែលមានប្រយោជន៍សុទ្ធតែអាចប្ដឹងបានទាំងអស់ដោយពុំមានកម្រិតអំឡុងពេលអាជ្ញាយុកាលឡើយ។

## ២.១.២. ការលុបចោលអាពាហ៍ពិពាហ៍

**ក. ករណីនៃការលុបចោលអាពាហ៍ពិពាហ៍**

ជាទូទៅ មានមូលហេតុចំនួនពីរយ៉ាងដែលអាចនាំអោយមានការលុបចោលអាពាហ៍ពិពាហ៍ ពោលគឺ ៖

- មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាប្រយោជន៍សាធារណៈរួមមាន ៖
  - អាពាហ៍ពិពាហ៍របស់ជនមិនទាន់គ្រប់អាយុ។
  - ទ្វេពន្ធភាព។
  - អាពាហ៍ពិពាហ៍រវាងញាតិដែលច្បាប់ហាមឃាត់រៀបអាពាហ៍ពិពាហ៍។
  - អាពាហ៍ពិពាហ៍ធ្វើឡើងក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី នារីមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនអំឡុងពេល ១២០ ថ្ងៃពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ (**ការលែងលះ ឬមរណភាពរបស់សហព័ទ្ធម្ខាង**) ឬលុបចោល។[៤០]

**ឧទាហរណ៍** ៖ កញ្ញា បានលែងលះពីប្ដីរបស់នាង (**អាពាហ៍ពិពាហ៍ត្រូវបានរំលាយដោយសារការលែងលះ**) ដោយសាលក្រមបានចូលជាស្ថាពរនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១២។ ដូចនេះ មិនអាចរៀបការជាថ្មីទៀតបានឡើយ រហូតដល់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០១២។ ប្រសិនបើនាងរៀបការនៅក្នុងអំឡុងពេលនេះអាពាហ៍ពិពាហ៍របស់នាងអាចត្រូវគេប្ដឹងឱ្យលុបចោលបាន។

ក៏ប៉ុន្តែ លក្ខខណ្ឌដូចខាងលើមិនចាំបាច់ត្រូវគោរពទេ ពោលគឺ នារីអាចរៀបការក្នុងអំឡុងពេលខាងលើបាន ដោយមិនមានបញ្ហាអ្វីទាំងអស់ ប្រសិនបើត្រូវនឹងលក្ខខណ្ឌដូចខាងក្រោម ៖

- នារីមានផ្ទៃពោះ មុនពេលអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ឬលុបចោល ហើយបានសម្រាលកូន។

[៤០] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៥០ កថាខណ្ឌទី១

- មានការបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត។[៤១]

**ឧទាហរណ៍ ៖** នៅក្នុងសម្មតិកម្មខាងលើ ប្រសិនបើ កញ្ញា ទៅរកវេជ្ជបណ្ឌិតហើយវេជ្ជបណ្ឌិតបញ្ជាក់ថា នាងមិនមានផ្ទៃពោះទេ ពេលនោះ កញ្ញា អាចរៀបការបាន នៅមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១២។

- មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាប្រយោជន៍ឯកជន រួមមាន ៖
  - ការគំរាម។
  - ឆបោក។[៤២]

**ខ. ជនដែលមានសិទ្ធិលុបចោលអាពាហ៍ពិពាហ៍**

ជនដែលមានសិទ្ធិទាមទារលុបចោលអាពាហ៍ពិពាហ៍ តាម**បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍** គឺ៖

- សម្រាប់មូលហេតុដែលមានលក្ខណៈជាប្រយោជន៍សាធារណៈ[៤៣]៖
  - ភាគីនីមួយៗ

**ឧទាហរណ៍ ៖** សុភាព អាយុ ១៨ ឆ្នាំ បានរៀបការជាមួយនឹង ធីតា អាយុ ១៧ ឆ្នាំដោយឪពុកម្តាយមិនបានផ្តល់ការយល់ព្រមចំពោះអាពាហ៍ពិពាហ៍នេះឡើយ។ ក្នុងករណីបែបនេះ សុភាព ឬ ធីតា គឺជាភាគីដែលអាចប្តឹងទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍បាន ស្របតាមអត្ថន័យនៃមាត្រាខាងលើ។

  - ញាតិសន្តានរបស់ភាគីនីមួយៗ (ច្បាប់មិនបានកំណត់ថា ត្រូវតែជាញាតិសន្តានកម្រិតណានោះទេ ដូចនេះ ឱ្យតែជាញាតិរបស់ភាគីនីមួយៗ គឺអាចប្តឹងបានទាំងអស់)។

**ឧទាហរណ៍ ៖** ក្នុងសម្មតិកម្មខាងលើ ឪពុកម្តាយរបស់ ធីតា គឺជាញាតិសន្តានរបស់ ធីតា ក៏ អាចប្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ។

  - តំណាងអយ្យការ។

**ឧទាហរណ៍ ៖** តំណាងអយ្យការបានទទួលដំណឹងថា សំខាន់ បានរៀបការជាមួយ ដារី ក្នុងខណៈដែលគាត់មិនទាន់បានផ្តាច់ចំណងអាពាហ៍ពិពាហ៍ពីប្រពន្ធគាត់ឈ្មោះ ណារី នៅឡើយ។ ក្នុងករណីនេះ តំណាងអយ្យការអាចដាក់ពាក្យបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍រវាង សំខាន់ និង ដារី បាន។

ចំពោះករណីនៃការលុបចោលអាពាហ៍ពិពាហ៍ដោយសារ ទ្វេពន្ធភាព ឬដោយសារការមិនគោរពអំឡុងពេលហាមឃាត់រៀបអាពាហ៍ពិពាហ៍ សហព័ទ្ធរបស់ភាគី ឬសហព័ទ្ធមុន ក៏អាចទាមទារលុបចោលអាពាហ៍ពិពាហ៍បានដែរ។

[៤១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៥០ កថាខណ្ឌទី២

[៤២] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៣

[៤៣] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦០

**ឧទាហរណ៍** ៖ សំខាន់ បានរៀបការជាមួយ ដារី ក្នុងខណៈដែលគាត់មិនទាន់បានផ្តាច់ចំណង អាពាហ៍ពិពាហ៍ពីប្រពន្ធគាត់ឈ្មោះ ណារី នៅឡើយ។ ក្នុងករណីនេះ ណារី ( សហព័ទ្ធរបស់ សំខាន់ ) ក៏អាចដាក់ ពាក្យបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍រវាង សំខាន់ និង ដារី បានដែរ។

**ឧទាហរណ៍** ៖ ដារ៉ា បានលែងលះពី ចិន្តា ។ ស្រាប់តែមួយខែក្រោយពេលសាលក្រមដែលសម្រេចពីការ លែងលះបានចូលជាស្ថាពរ ដារ៉ា បានដឹងថា ចិន្តា បានរៀបការជាមួយនឹង សុភាព។ ក្នុងករណីនេះ ដារ៉ា ( សហព័ទ្ធមុនរបស់ ចិន្តា ) អាចប្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍រវាង ចិន្តា និងសុភាព បាន។

- សម្រាប់មូលហេតុដែលមានលក្ខណៈជាប្រយោជន៍ឯកជន[៤៤] មានតែបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬដោយការគំរាម ទើបអាចទាមទារលុបចោលអាពាហ៍ពិពាហ៍បាន។

**ឧទាហរណ៍** ៖ ធារ៉ា ត្រូវបានគេគំរាមនាងឱ្យរៀបការជាមួយនឹង ភក្តី។ ក្នុងករណីនេះ មានតែ ធារ៉ា ប៉ុណ្ណោះដែលអាចប្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍រវាងនាង និង ភក្តី បាន។ ភក្តី ញាតិរបស់ ធារ៉ា ក៏ដូចជា តំណាងអយ្យការ មិនអាចប្តឹងបានឡើយ។

សូមបញ្ជាក់ជូនផងដែរថា ការដោះស្រាយលើបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ ត្រូវតែ អនុលោមតាម **ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** ពោលគឺតុលាការធ្វើការសម្រេចក្តី ដោយចេញជា សាលក្រម។

**គ. ការរំលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍**

ខុសប្លែកពីមោឃភាពអាពាហ៍ពិពាហ៍ សម្រាប់ការលុបចោលអាពាហ៍ពិពាហ៍ ក្រមរដ្ឋប្បវេណីបាន កំណត់នូវករណីដែលនាំឱ្យសិទ្ធិប្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ ត្រូវរលត់ ៖

- ប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយនោះ អាពាហ៍ពិពាហ៍នេះមិនអាចត្រូវលុបចោលបានទេ ប៉ុន្តែជនដែលមិនទាន់គ្រប់អាយុការអាចទាមទារលុប ចោលអាពាហ៍ពិពាហ៍ក្នុងអំឡុងពេល ៣ ខែ គិតចាប់ពីពេលជននោះបានគ្រប់អាយុ។ ជននេះមិនអាច ប្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍បានទេ ប្រសិបបើបានធ្វើសច្ចានុមតិ (គឺជាសកម្មភាពដែលបុគ្គល មានសិទ្ធិលុបចោល បង្ហាញជាស្ថាពរថា ខ្លួនមិនអនុវត្តសិទ្ធិលុបចោលទេ)។[៤៥]

**ឧទាហរណ៍** ៖ ចន្ថា មានអាយុ ១៧ ឆ្នាំ បានរៀបការជាមួយ ណារ៉ា អាយុ ២០ ឆ្នាំ ដោយមិនមានការ យល់ព្រមពីឪពុក ឬ ម្តាយរបស់ ចន្ថា ឡើយ។ ដូចនេះ ប្រសិនបើ ចន្ថា មិនទាន់ដល់គ្រប់អាយុ ១៨ ឆ្នាំ ទេ អ្នក ដែលមានសិទ្ធិទាមទារលុបចោលអាពាហ៍ពិពាហ៍រួមមាន ៖ ចន្ថា ណារ៉ា ឪពុកម្តាយរបស់ ចន្ថា ឬ ឪពុកម្តាយ របស់ ណារ៉ា និង តំណាងអយ្យការ លែងមានសិទ្ធិប្តឹងទៀតហើយ។ សម្រាប់ ចន្ថា នាងនៅតែមានសិទ្ធិប្តឹងលុប ចោលអាពាហ៍ពិពាហ៍បាន ក្នុងអំឡុងពេល ៣ ខែ គិតពីពេលដែលនាងបានដល់អាយុ ១៨ ឆ្នាំ។

---

[៤៤] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៣

[៤៥] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦១

**ឧទាហរណ៍ ៖** ក្នុងសម្មតិកម្មខាងលើដដែល ឧបមាថា នៅពេលដែល ចន្ថា បានដល់អាយុ ១៨ ឆ្នាំ ភ្លាម នាងក៏បានបង្ហាញឆន្ទៈ (លាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់) ថានាងនឹងមិនអនុវត្តសិទ្ធិទាមទារលុបចោល អាពាហ៍ពិពាហ៍រវាងនាង និង ណារ៉ា ទេ ពេលនោះគឺមានន័យថា ចន្ថា បានផ្តល់នូវសច្ចានុមតិ។ ដូចនេះ ចន្ថា នឹងបាត់បង់សិទ្ធិទាមទារលុបចោលអាពាហ៍ពិពាហ៍តែម្តង ទោះបីជាអំឡុងពេល ៣ ខែ មិនទាន់បានកន្លងផុតគិតចាប់ពីពេលដែលនាងបានដល់អាយុ ១៨ ឆ្នាំ ក៏ដោយ។ និយាយម្យ៉ាងវិញទៀតថា ប្រសិនបើនាងផ្តល់សច្ចានុមតិហើយ នាងមិនអាចផ្លាស់ប្តូរចិត្ត បែរជាដាក់ពាក្យបណ្តឹងវិញនោះបានទេ។

- ប្រសិនបើអាពាហ៍ពិពាហ៍ បានធ្វើឡើងដោយមិនបានគោរពតាមអំឡុងពេលហាមឃាត់រៀបអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែ រយៈពេល ១២០ ថ្ងៃ បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ឬ ប្រសិនបើនារីមានផ្ទៃពោះក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីសិទ្ធិទាមទារលុបចោលអាពាហ៍ពិពាហ៍នេះនឹងត្រូវរលត់។[៤៦]

**ឧទាហរណ៍ ៖** រស្មី បានលែងលះពីប្តីរបស់នាង ដោយសាលក្រមបានចូលជាស្ថាពរនៅថ្ងៃទី ០១.០២.២០១២។ លុះដល់ថ្ងៃទី ០៣.០៣.២០១២ រស្មី បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាថ្មីជាមួយនឹង បញ្ញា។ នេះបានន័យថា រស្មី មិនបានគោរពអំឡុងពេល១២០ ថ្ងៃ ដែលច្បាប់បានហាមឃាត់ឡើយ។ លុះដល់ថ្ងៃទី ០១.០៦.២០១២ គឺពុំមាននរណាម្នាក់អាចប្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍រវាង រស្មី និង បញ្ញា ឡើយ ពីព្រោះថា ទោះបីជា រស្មី បានរៀបការដោយបំពានអំឡុងពេលហាមឃាត់ក្តី ក៏ប៉ុន្តែ រហូតមកដល់ថ្ងៃទី ០១.០៦.២០១២ នេះ គឺ រយៈពេល ១២០ ថ្ងៃ បានកន្លងផុតទៅហើយ។

ដូចគ្នាដែរ ប្រសិនបើមកដល់ថ្ងៃទី ០៣.០៥.២០១២ ស្រាប់តែ រស្មី មានផ្ទៃពោះជាមួយនឹង បញ្ញា អាពាហ៍ពិពាហ៍រវាង រស្មី និង បញ្ញា គឺមិនអាចមាននរណាទាមទារឱ្យលុបចោលបានឡើយ។

- ប្រសិនបើអាពាហ៍ពិពាហ៍បានធ្វើឡើងដោយការឆបោក ឬ ការគំរាម សិទ្ធិទាមទារលុបចោលអាពាហ៍ពិពាហ៍ ត្រូវរលត់ ប្រសិនបើអំឡុងពេល ៣ ខែ បានកន្លងផុត គិតពីពេលបានរួចខ្លួនពីការគំរាម ឬ គិតពីពេលបានរកឃើញការឆបោក។[៤៧]

**ឧទាហរណ៍ ៖** ណារី បានរៀបការជាមួយនឹង សំភី ដោយសារតែការគំរាមរបស់ម្តាយនាង។ ក្រោយពីបានរៀបការជាមួយ ណារី បានទៅរស់នៅជាមួយនឹង សំភី នៅផ្ទះមួយផ្សេង នេះបានន័យថា នាងបានរួចផុតពីការគំរាមហើយ។ ដូចនេះ ប្រសិនបើ ណារី មិនបានប្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ក្នុងអំឡុងពេល ៣ ខែ ណារី នឹងលែងមានសិទ្ធិប្តឹងទៀតហើយ។

**ឧទាហរណ៍ ៖** ណារី បានរៀបការជាមួយនឹង សំភី ដោយសារតែការឆបោករបស់ សំភី។ ក្រោយពីបានរៀបការរួច ណារី បានទៅរស់នៅជាមួយនឹង សំភី ហើយរយៈពេល ៦ ខែ កន្លងផុតទៅ ទើប ណារី ដឹងថា នាងត្រូវ

---

[៤៦] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦២

[៤៧] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៣ កថាខណ្ឌទី២

សំភី បោកប្រាស់។ ក្រោយពីបានដឹងយ៉ាងដូច្នេះហើយ ណារី នាងមិនបានប្ដឹងទាមទារលុបចោលអាពាហ៍ពិពាហ៍នេះទេ ក្នុងរយៈពេល ៣ ខែ គិតចាប់ពីពេលដឹងនោះមក។ ក្នុងករណីបែបនេះ នាងលែងមានសិទ្ធិប្ដឹងទៀតហើយ។

ទន្ទឹមនឹងនេះដែរ ប្រសិនបើបន្ទាប់ពីបានដឹងថា រូបនាងត្រូវ សំភី ឆបោកឱ្យរៀបការជាមួយយ៉ាងដូច្នេះក៏ដោយតែ ណារី បានបង្ហាញឆន្ទៈថា នាងមិនអនុវត្តសិទ្ធិលុបចោលទេ ពោលគឺនាងបានផ្ដល់សច្ចានុមតិ។ ក្នុងលក្ខខណ្ឌបែបនេះ ណារី លែងមានសិទ្ធិប្ដឹងជាថ្មីម្ដងទៀតហើយ។

**ឃ. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍**

តាមការពិត ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពប្រតិសកម្មទេ[៤៨] ពោលគឺការលុបចោលអាពាហ៍ពិពាហ៍ មានអានុភាពរំលាយអាពាហ៍ពិពាហ៍ឆ្ពោះទៅអនាគត គិតចាប់ពីពេលដែលសេចក្ដីសម្រេចលុបចោលអាពាហ៍ពិពាហ៍បានចូលជាស្ថាពរ។

**ឧទាហរណ៍ ៖** បញ្ញា និង ដារី បានរៀបការជាមួយគ្នាត្រឹមត្រូវតាមច្បាប់នៅ ថ្ងៃទី០២.០១.២០១២ ដោយសារតែការគំរាមពីសំណាក់ឪពុកម្ដាយរបស់ ដារី។ នៅថ្ងៃទី២០.០៩.២០១២ សាលក្រមដែលសម្រេចលុបចោលអាពាហ៍ពិពាហ៍រវាង បញ្ញា និង ដារី បានចូលជាស្ថាពរ។ ក្នុងន័យនេះ ចាប់ពីថ្ងៃទី២០.០៩.២០១២ តទៅ បញ្ញា និង ដារី មិនមែនជាសហព័ទ្ធនឹងគ្នាទៀតទេ ក៏ប៉ុន្តែ ចាប់ពីថ្ងៃទី០២.០១.២០១២ ដល់ថ្ងៃទី១៩.០៩.២០១២ អ្នកទាំងពីរគឺជាសហព័ទ្ធនឹងគ្នា តាមច្បាប់។

មិនត្រឹមតែប៉ុណ្ណោះ ក្រមរដ្ឋប្បវេណីក៏បានចែងនូវបទប្បញ្ញត្តិពិសេសសម្រាប់ការលុបចោលអាពាហ៍ពិពាហ៍ចំពោះកូន និង ចំពោះទ្រព្យសម្បត្តិរបស់គូភាគីផងដែរ។

**ឃ.១. អានុភាពនៃការលុបចោល ចំពោះកូន**

កូនដែលកើតពីភាគីនៃអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ត្រូវសន្មតថាមានគភ៌ក្នុងពេលមានបំណងអាពាហ៍ពិពាហ៍ (ជាកូនរបស់បុរសជាប្ដីនៃម្ដាយ) ប្រសិនបើកូននោះបានកើតក្នុងអំឡុងពេល ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេល ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍។[៤៩]

**ឧទាហរណ៍ ៖ បញ្ញា** និង **ដារី** បានរៀបការជាមួយគ្នាត្រឹមត្រូវតាមច្បាប់ នៅថ្ងៃទី០២.០១.២០១២ ដោយសារតែការគំរាមពីសំណាក់ឪពុកម្ដាយរបស់ ដារី។ នៅថ្ងៃទី២០.០៩.២០១២ សាលក្រមដែលសម្រេចលុបចោលអាពាហ៍ពិពាហ៍រវាង បញ្ញា និងដារី បានចូលជាស្ថាពរ។ បន្ទាប់មក នៅថ្ងៃទី០៣.១១.២០១២ ដារី បានប្រសូត្រកូនប្រុសម្នាក់ឈ្មោះ ដារណ្ណ។ នៅក្នុងសម្មតិកម្មនេះ ដារណ្ណបានកើតនៅក្នុងអំឡុងពេលដែលច្បាប់កំណត់ថា ត្រូវសន្មតជាកូនរបស់ បញ្ញា (កើតក្នុងអំឡុងពេល ៣០០ ថ្ងៃ ក្រោយថ្ងៃលុបចោលអាពាហ៍ពិពាហ៍)។ ដូច្នេះ ប្រសិនបើ បញ្ញា យល់ថា ដារណ្ណ មិនមែនជាកូនរបស់គាត់ទេ បញ្ញា ត្រូវតែ**ប្ដឹងបដិសេធបិតុភាព**។ ដូចគ្នានេះ

[៤៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៤ កថាខណ្ឌទី១

[៤៩] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨៨ កថាខណ្ឌទី២

ដែរ ប្រសិនបើ ដាវី យល់ថា ដាវណ្ណ មិនមែនជាកូនរបស់ បញ្ញា ទេ នាងត្រូវប្ដឹងបដិសេធបិតុភាព។ ផ្ទុយមកវិញ បើពុំមានការបដិសេធបិតុភាពទេ ដាវណ្ណ ត្រូវសន្មតថាជាកូនរបស់ បញ្ញា ជាដរាប។

**ឃ.២. អានុភាពនៃការលុបចោល ចំពោះទ្រព្យសម្បត្តិ**

នៅក្នុងករណីដែលអាពាហ៍ពិពាហ៍មួយត្រូវបានប្រកាសលុបចោលការ បែងចែកទ្រព្យសម្បត្តិ ត្រូវធ្វើដូចក្នុងករណីលែងលះដែរ។[៥០] ជាគោលការណ៍ ទ្រព្យសម្បត្តិត្រូវបែងចែកតាមការព្រមព្រៀង ប្រសិនបើពុំមានការព្រមព្រៀងទេ ទ្រព្យសម្បត្តិរួមត្រូវបែងចែកស្មើគ្នារវាងសហព័ទ្ធ ហើយសហព័ទ្ធម្នាក់ៗទទួលបាននូវទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួន។[៥១]

**ឧទាហរណ៍** ៖ ក្នុងសម្មតិកម្មខាងលើរវាង បញ្ញា និង ដាវី ឧបមាថា មុនពេលមានការលុបចោលអាពាហ៍ពិពាហ៍ បញ្ញា បានទិញរថយន្តមួយគ្រឿងតម្លៃ ៥,០០០ដុល្លារ។ រថយន្តនេះ គឺជាទ្រព្យរួម។ ដូចនេះ នៅពេលមានការលុបចោលអាពាហ៍ពិពាហ៍ បញ្ញា និងដាវី ត្រូវមានសិទ្ធិលើរថយន្តខាងលើម្នាក់ពាក់កណ្ដាល។

បន្ថែមពីលើនេះទៅទៀត ភាគីដែលមិនបានដឹងពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍ ត្រឹមកម្រិតផលប្រយោជន៍ដែលបានទទួល។[៥២] ជាសរុបមក ទ្រព្យសម្បត្តិដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍ រួមមានដូចជា ៖

- ទ្រព្យសម្បត្តិដែលត្រូវបានធ្វើប្រទានកម្ម នៅពេលរៀបអាពាហ៍ពិពាហ៍ ឬក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

**ឧទាហរណ៍** ៖ ដាវី ត្រូវបាន បញ្ញា គំរាមឱ្យរៀបការជាមួយគាត់។ ក្នុងករណីនេះ ដាវី គឺជាភាគីដែលមិនបានដឹងពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍។ ឧបមាថា នៅពេលរៀបអាពាហ៍ពិពាហ៍ បញ្ញា បានផ្ដល់នូវខ្សែកមួយខ្សែតម្លៃ ៣,០០០ដុល្លារ ឱ្យ ដាវី។ ដូចគ្នាដែរ ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួចហើយ បញ្ញា បានទិញខ្សែដៃតម្លៃ ១,០០០ដុល្លារ ឱ្យ ដាវី។ ទ្រព្យសម្បត្តិទាំងនេះ គឺជាទ្រព្យសម្បត្តិដែល ដាវី បានទទួលដោយការរៀបអាពាហ៍ពិពាហ៍។ ហេតុដូច្នេះ ដាវី ត្រូវសងទ្រព្យសម្បត្តិទាំងនេះ ឱ្យទៅ បញ្ញា វិញ នៅពេលមានការសម្រេចលុបចោលអាពាហ៍ពិពាហ៍។

- ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម (មរតក) ឬ អច្ច័យទាន (ទ្រព្យសម្បត្តិទទួលបានតាមរយៈមតកសាសន៍ ៖ បណ្ដាំមរតក) ឬ ផលប្រយោជន៍ពីការធានារ៉ាប់រងជីវិត។ល។

**ឧទាហរណ៍** ៖ មុនពេលមានការលុបចោលអាពាហ៍ពិពាហ៍រវាង បញ្ញា និង ដាវី នោះ បញ្ញា បានស្លាប់បាត់បង់ជីវិត។ ក្នុងនាមជាភរិយារបស់ បញ្ញា នាង ដាវី មានសិទ្ធិទទួលមរតកពី បញ្ញា ចំនួន ២០០០ដុល្លារ។ ទោះជាយ៉ាងនេះក្ដី ដាវី នៅតែមានបំណងលុបចោលអាពាហ៍ពិពាហ៍ (ក្នុងករណីបែបនេះ តាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវយកតំណាងអយ្យការធ្វើជាចុងចម្លើយនៅក្នុងបណ្ដឹងទាមទារលុបចោល

[៥០] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៤ កថាខណ្ឌទី៥

[៥១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨០ កថាខណ្ឌទី២ ចំណុច ក និង ចំណុច ខ

[៥២] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៤ កថាខណ្ឌទី២

អាពាហ៍ពិពាហ៍)។ ហេតុដូចនេះ ប្រសិនបើមានការសម្រេចលុបចោលអាពាហ៍ពិពាហ៍មែន ដាវី ត្រូវតែសង ២,០០០ដុល្លារ ឱ្យ បញ្ញា វិញ ក៏ប៉ុន្តែ បញ្ញា បានស្លាប់បាត់បង់ជីវិតទៅហើយ ដូច្នេះ ប្រាក់ចំនួន ២,០០០ដុល្លារ ត្រូវធ្លាក់ទៅលើសន្តតិជនរបស់ បញ្ញា។

**ឧទាហរណ៍** ៖ ចំពោះមុខសម្បតិកម្មខាងលើនេះ ឧបមាថា បញ្ញា បានទិញការធានារ៉ាប់រងជីវិត ដោយកំណត់ឱ្យ ដាវី ជាអ្នកទទួលផលប្រយោជន៍ពីការធានារ៉ាប់រងជីវិត។ ដូចនេះ ក្រោយពី បញ្ញា ស្លាប់បាត់បង់ជីវិត ដាវី មានសិទ្ធិទទួលផលប្រយោជន៍នៃការធានារ៉ាប់រងជីវិតរបស់ បញ្ញា ចំនួន ១០ម៉ឺនដុល្លារ។ ក៏ប៉ុន្តែ ប្រសិនបើមានការលុបចោលអាពាហ៍ពិពាហ៍ ដាវី ត្រូវសងប្រាក់ ១០ម៉ឺនដុល្លារនេះឱ្យសន្តតិជនរបស់ បញ្ញា វិញ។

ចំណែកឯភាគីដែលបានដឹងពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍វិញ គឺត្រូវសងផលប្រយោជន៍ទាំងអស់ដែលទទួលបានដោយការអាពាហ៍ពិពាហ៍។ ប្រសិនបើភាគីម្ខាងទៀតសុចរិត ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ។[៥៣] ផលប្រយោជន៍ដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍ រួមមាន ៖

- ទ្រព្យសម្បត្តិដែលត្រូវបានធ្វើប្រទានកម្ម នៅពេលរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិដែលទទួលាបានតាមរយៈសន្តតិកម្ម (មរតក) ឬ អច្ច័យទាន (ទ្រព្យសម្បត្តិទទួលបានតាមរយៈមតកសាសន៍ ៖ បណ្តាំមរតក) ឬក៏ជាផលប្រយោជន៍ពីការធានារ៉ាប់រងជីវិត។ល។
- រួមទាំង ថ្លៃស្នាក់នៅ ថ្លៃចំណាយលើម្ហូបអាហារ កំសាន្ត ជាដើម។

**ឧទាហរណ៍** ៖ បញ្ញា បានគំរាម ដាវី ឱ្យនាងរៀបការជាមួយនឹងខ្លួន។ ក្រោយពេលរៀបការរួច បញ្ញា បានមកស្នាក់នៅជាមួយនឹងក្រុមគ្រួសាររបស់ ដាវី ដោយ បញ្ញា កំពុងតែបន្តការរៀនសូត្រ នៅមិនទាន់មានការងារធ្វើនៅឡើយ។ នៅក្នុងករណីបែបនេះ បញ្ញា គឺជាភាគីនៃអាពាហ៍ពិពាហ៍ដែលបានដឹងពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ នៅពេលរៀបការ ពោលគឺ បញ្ញា ជាអ្នកគំរាម ហេតុនេះ បញ្ញា ប្រាកដជាដឹងថា ការគំរាមគឺជាមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ហេតុដូច្នេះ បញ្ញា ត្រូវសងឱ្យ ដាវី វិញ នូវផលប្រយោជន៍ទាំងអស់ដែល បញ្ញា បានទទួលដោយការរៀបអាពាហ៍ពិពាហ៍ គឺរួមបញ្ចូលទាំងថ្លៃស្នាក់នៅ និងម្ហូបអាហារផងដែរ។ ចំពោះតម្លៃពិតប្រាកដ គឺអាស្រ័យទៅលើភស្តុតាងដែលមាន។

ម៉្យាងវិញទៀត ក្នុងករណីខាងលើនេះ ដាវី គឺជាជនសុចរិត ពីព្រោះថា នាងជាជនរងគ្រោះ។ ដូច្នេះ នាងអាចទាមទារនូវសំណងនៃការខូចខាតពី បញ្ញា ផងដែរដូចជាថ្លៃរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ដែលនាងបានចំណាយ រួមបញ្ចូលទាំងការខូចខាតផ្លូវចិត្ត ជាដើម។

## ២.២. អានុភាពនៃអាពាហ៍ពិពាហ៍

កាលណាអាពាហ៍ពិពាហ៍បានបំពេញនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ ដែលមិនអាចមោឃៈភាព ឬលុបចោលបាន នោះនាំឱ្យអាពាហ៍ពិពាហ៍មានសុពលភាពគតិយុត្ត។ កាលណាអាពាហ៍ពិពាហ៍ចូលជាសុពល

[៥៣] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៤ កថាខណ្ឌទី៣

ភាព នាំឱ្យអាពាហ៍ពិពាហ៍នោះមានអានុភាពផ្សេងៗដូចជា អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួន អានុភាពចំពោះទ្រព្យ និងអានុភាពចំពោះកូនផងដែរ ដែលគេហៅថា "អានុភាពនៃអាពាហ៍ពិពាហ៍"។

តាមច្បាប់ ក្រោយពីអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងហើយ គូភាគីនៃអាពាហ៍ពិពាហ៍នឹងក្លាយទៅជាសហព័ទ្ធ។ ដូច្នេះ ឋានៈជាសហព័ទ្ធនេះបានផ្តល់នូវសិទ្ធិ និងករណីយកិច្ចមួយចំនួន ទាំងក្នុងទិដ្ឋភាពទំនាក់ទំនងផ្ទាល់ខ្លួន និងទាំងក្នុងទិដ្ឋភាពទាក់ទងនឹងទ្រព្យសម្បត្តិ ព្រមទាំងទិដ្ឋភាពដែលទាក់ទងនឹងកូនៗ។

**២.២.១. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះទំនាក់ទំនងផ្ទាល់ខ្លួន**

សិទ្ធិផ្សេងៗក្នុងនាមជាសហព័ទ្ធរួមមាន ៖

- ប្តី ប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍បាន។[៥៤]

**ឧទាហរណ៍** ៖ ព្រំ បញ្ញា បានរៀបការជាមួយនឹងនារីម្នាក់ឈ្មោះ ផាន់ បូផា។ ក្នុងករណីនេះ ផាន់ បូផា អាចប្រើនាមត្រកូលរបស់ប្តីនាងបាន ដោយប្តូរទៅជា ព្រំ បូផា វិញក៏បានដែរ។

- ប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ព្រមទាំងមានសិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គមរៀងៗខ្លួន។[៥៥]
- ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវចាត់ទុកថាបានដល់នីតិភាព ដោយអាពាហ៍ពិពាហ៍នោះ។[៥៦] ចំណុចនេះមានអត្ថន័យថា អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ នឹងទទួលបាននូវអត្តាធីនភាព (**ភាពរួចផុតពីអំណាចមេបា ឬអ្នកអាណាព្យាបាល**) ដោយស្វ័យប្រវត្តិ បានសេចក្តីថា ដោយមិនចាំបាច់ស្នើសុំឱ្យតុលាការចេញដីកាសម្រេចផ្តល់អត្តាធីនភាពឡើយ។

ស្របពេលជាមួយគ្នានេះ ក្នុងនាមជាសហព័ទ្ធ គឺមានករណីយកិច្ចផ្សេងៗដែលកំណត់ដោយច្បាប់[៥៧] ៖

- ករណីយកិច្ចត្រូវរួមរស់ជីវភាពជាមួយគ្នា។
- ករណីយកិច្ចត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក។

**២.២.២. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះទ្រព្យសម្បត្តិ**

ចំពោះសហព័ទ្ធ ប្រព័ន្ធទ្រព្យសម្បត្តិមាន ៖

- ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ៖ ក្នុងករណីដែលសហព័ទ្ធបានព្រមព្រៀងគ្នាធ្វើ **កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**។

---

[៥៤] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៥
[៥៥] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៧
[៥៦] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៨
[៥៧] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៦

- ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ៖ ក្នុងករណីដែលសហព័ទ្ធមិនបានធ្វើ **កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**។

**ក. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា**

ដើម្បីអាចជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា សហព័ទ្ធត្រូវធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ កិច្ចសន្យាត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍។[៥៨] ជាពិសេសទៅទៀត កិច្ចសន្យានេះត្រូវតែចុះបញ្ជី ដើម្បីអាចយកមក**តតាំង**នឹងតតិយជនបាន។ ការចុះបញ្ជីនេះត្រូវធ្វើឡើងនៅក្រសួងយុត្តិធម៌[៥៩] តាមពាក្យស្នើសុំចុះបញ្ជីរបស់ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងរៀបការជាមួយគ្នា[៦០]។

ពាក្យ "**លក្ខខណ្ឌតតាំង**" សំដៅទៅលើលក្ខខណ្ឌដែលត្រូវបំពេញ ដើម្បីឱ្យមានអានុភាពទៅលើតតិយជនក្រៅពីគូភាគី។ កង្វះលក្ខខណ្ឌតតាំងនាំឱ្យតតិយជន អាចជំទាស់ចំពោះអនុភាពនៃកិច្ចសន្យាចំពោះរូបគាត់។

**ឧទាហរណ៍** ៖ សំភី និង រ៉ាវី បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានខ្លឹមសារយ៉ាងច្បាស់ថា ទ្រព្យសម្បត្តិទាំងអស់ដែលរកបានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ដោយសហព័ទ្ធម្នាក់ៗ គឺជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្នាក់ៗ។ ក៏ប៉ុន្តែ អ្នកទាំងពីរមិនបានយកកិច្ចសន្យានេះទៅចុះបញ្ជីទេ។ ដូចនេះ កិច្ចសន្យានេះមិនមានអានុភាពចំពោះតតិយជនឡើយ។ ឧបមាថា ក្រោយពីរៀបការរួច រ៉ាវី បានខ្ចីប្រាក់ ធីតា ចំនួន ២០០០ ដុល្លារ ដើម្បីយកទៅដោះស្រាយបំណុលរបស់ម្តាយនាង ដោយមិនឱ្យ សំភី ដឹងឡើយ។ ក្រោយមក ធីតា បានទាមទារឱ្យមានការរឹបអូសរថយន្តមួយគ្រឿងដែល សំភី បានទិញនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយនឹង រ៉ាវី។ ក្នុងករណីបែបនេះ សំភី ប្រាកដជាលើកសំអាងពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរវាងគាត់ និង រ៉ាវី ដើម្បីបញ្ជាក់ថា រថយន្តមួយគ្រឿងនេះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់គាត់ មិនមែនជាទ្រព្យសម្បត្តិរួមរវាងគាត់ និង រ៉ាវីទេ។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ដោយហេតុថា កិច្ចសន្យាទ្រព្យសម្បត្តិមិនត្រូវបានយកទៅចុះបញ្ជីនៅក្រសួងយុត្តិធម៌ នាំឱ្យ កិច្ចសន្យានេះមិនអាចយកទៅតតាំងជាមួយនឹង ធីតា បានទេ ពោលគឺ រថយន្តនេះនឹងត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួមរវាង សំភី និង រ៉ាវី ហើយចំណែកដែលជាកម្មសិទ្ធិរបស់ រ៉ាវី (ថ្លៃពាក់កណ្តាលនៃរថយន្ត) អាចនឹងត្រូវបានរឹបអូស ដើម្បីលក់យកប្រាក់មកសងបំណុលរបស់ ធីតា បាន។

ជាក់ស្តែង កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធអាចមានខ្លឹមសារ ទៅតាមការព្រមព្រៀងរវាងគូភាគី។

**ឧទាហរណ៍៖**

- ទ្រព្យសម្បត្តិដែលគូភាគីមានមុនពេលរៀបការ ក៏ដូចជាទ្រព្យសម្បត្តិដែលទទួលបានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ទោះដោយមូលហេតុអ្វីក៏ដោយត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។

[៥៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៩ កថាខណ្ឌទី១

[៥៩] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា២៦

[៦០] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា២៨

- ទ្រព្យសម្បត្តិដែលគូភាគីមានមុនពេលរៀបការ ក៏ដូចជាទ្រព្យសម្បត្តិដែលគូភាគីរកបានពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធរៀងៗខ្លួន។

ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី ខ្លឹមសារនេះមិនត្រូវផ្ទុយបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច (កាតព្វកិច្ចផ្គត់ផ្គង់អាហារដល់ញាតិដែលកំណត់ដោយច្បាប់) ឬភាគបម្រុងឡើយ។[៦១]

**ឧទាហរណ៍៖** សុខ ជាតា មានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឪពុកជរារបស់គាត់នូវទឹកប្រាក់ចំនួន ១០០$ ក្នុងមួយខែ។ ក្រោយពីការរៀបការរួច សុខ ជាតា បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយនឹង ដានី ដែលមានខ្លឹមសារថា៖ រាល់ចំណាយទឹកប្រាក់ចាប់ពី ៥០ ដុល្លារឡើងទៅ ត្រូវមានការព្រមព្រៀងពីប្តីប្រពន្ធ ឬហៅថាសហព័ទ្ធសងខាង។ ខ្លឹមសារបែបនេះ គឺប៉ះពាល់ដល់សិទ្ធិរបស់ឪពុក សុខ ជាតា។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រង់ចំណុចនេះមិនត្រូវមានអនុភាពហាមឃាត សុខ ជាតា មិនអោយបង់ប្រាក់ ១០០$ អោយឪពុកគាត់នោះឡើយ។

**ឧទាហរណ៍៖** សំខាន់ បានធ្វើកិច្ចសន្យាប្តីប្រពន្ធជាមួយនឹងភរិយារបស់គាត់ឈ្មោះ ចិន្តា ដែលមានខ្លឹមសារដូចតទៅ៖ នៅពេលដែលមានសហព័ទ្ធណាម្នាក់ស្លាប់បាត់បង់ជីវិតមុន សហព័ទ្ធដែលនៅរស់មានសិទ្ធិទទួលមានទ្រព្យសម្បត្តិទាំងអស់របស់សហព័ទ្ធដែលបានបាត់បង់ជីវិត។ ឧបមាថា សំខាន់ មានកូន ២នាក់ មុនពេលដែលគាត់មករៀបការជាមួយនឹង ចិន្តា ហើយឥឡូវនេះ សំខាន់ បានស្លាប់បាត់បង់ជីវិត។ បើសិនជាត្រូវអនុវត្តតាមកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទ្រព្យសម្បត្តិទាំងអស់របស់ សំខាន់ ត្រូវផ្ទេរទៅអោយ ចិន្តា នៅពេលនោះ កូនទាំងពីរនាក់របស់ សំខាន់ មិនអាចទទួលបានអ្វីទាំងអស់។ ចំណុចនេះ គឺផ្ទុយនឹងបទប្បញ្ញត្តិនៃក្រម រដ្ឋប្បវេណីទាក់ទងនិងភាគបម្រុង។ ដូចនេះ ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធខាងលើ គឺមិនអាចធ្វើឱ្យប៉ះពាល់សិទ្ធិទាមទារភាគបម្រុងនៃកូនទាំងពីររបស់ សំខាន់ បានឡើយ។ និយាយម៉្យាងវិញទៀតថា ទោះបីមានកិច្ចសន្យាបែបនេះក៏ដោយ ក៏សំខាន់ ក៏អាចទាមទារអោយគោរពសិទ្ធិលើភាគបម្រុងរបស់ពួកគេបានជាដដែលពោលគឺទ្រព្យសម្បត្តិមួយភាគដែលជាមរតករបស់ សំខាន់ និងត្រូវប្រគល់អោយទៅកូនរបស់ សំខាន់ តាមការទាមទារ។

**ខ.ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់**

ក្នុងករណីដែលសហព័ទ្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អោយបានច្បាស់លាស់នោះទេ យើងត្រូវសិក្សាលើការកំណត់ទ្រព្យសម្បត្តិសកម្ម និងទ្រព្យសម្បត្តិអកម្មរបស់សហព័ន្ធ។

**ខ.១. ទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធ**

ទ្រព្យសម្បត្តិរបស់សហព័ទ្ធមានពីរប្រភេទ៖ ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។

[៦១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៦៩ កថាខណ្ឌទី១

### ខ.១.១. ប្រភេទនៃទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធ

➢ **ទ្រព្យសម្បត្តិដោយឡែក**

ទ្រព្យសម្បត្តិដែលច្បាប់បានចាត់ទុកថា ជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធដែលក្នុងនោះរួមមាន៖[៦២]

- **ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលពេលរៀបអាពាហ៍ពិពាហ៍។**

**ឧទាហរណ៍៖** សំខាន់ បានទិញរថយន្តមួយគ្រឿងនៅថ្ងៃទី ៥ ខែមីនា ឆ្នាំ២០១២។ បន្ទាប់មកដល់ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១២ សំខាន់ បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយនិង ណារី។ ដូចនេះ រថយន្តខាងលើ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ សំខាន់។

ចំពោះទ្រព្យសម្បត្តិដែលមានលក្ខណៈពិសេស ដូចជា មូលនិធិពាណិជ្ជកម្ម (ឧទាហរណ៍ដូចជា អាជីវកម្មភោជនីយដ្ឋាន អាជីវកម្មសណ្ឋាគារ គឺត្រូវពិនិត្យមើលទៅលើកាលបរិច្ឆេទនៃការបង្កើតមូលនិធិពាណិជ្ជកម្ម ពោលគឺពិនិត្យកាលបរិច្ឆេទនៃការបើកហាងទទួលអថិតិជន។

**ឧទាហរណ៍៖** នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ សំខាន់ បានរៀបចំបើកភោជនីយដ្ឋានមួយកន្លែង (មូលនិធិពាណិជ្ជកម្ម)។ លុះដល់ថ្ងៃទី០២ ខែ០៤ ឆ្នាំ២០១២ សំខាន់ បានជួលដីមួយកន្លែង ដើម្បីបើកភោជនីយដ្ឋាន ជួលបុគ្គលិកបម្រើការងារទិញ សម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងភោជនីយដ្ឋាន។ មកដល់ថ្ងៃទី០១ ខែ០៦ ឆ្នាំ២០១២ សំខាន់ ក៏បានសំម្ពោធបើកភោជនីយដ្ឋាន បម្រើដល់អតិថិជន។ នៅថ្ងៃទី០៥ ខែ០៦ ឆ្នាំ២០១២ សំខាន់ បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយនិង ណារី។ ភោជនីយដ្ឋាននេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី០១ ខែ០៦ ឆ្នាំ២០១២ ពោលគឺមុនពេល សំខាន់ រៀបការជាមួយ ណារី។ ដូចនេះ ភោជនីយដ្ឋាននោះជាទ្រព្យសម្បត្តិដោយឡែករបស់សំខាន់។ រីឯផលចំណេញដែលបានមកពីអាជីវកម្មភោជនីយដ្ឋាន ចាប់ពីថ្ងៃទី០៥ ខែ០៦ ឆ្នាំ ២០១២ រហូតដល់ថ្ងៃរំលាយអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួម។

- **ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។**
    - **ប្រទានកម្ម** គឺជាកិច្ចសន្យាមួយដែលត្រូវមានអនុភាព ដោយភាគីម្ខាង (ទាយក) បង្ហាញឆន្ទៈផ្តល់ទៅអោយភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀត (បដិគ្គាហក) យល់ព្រមទទួល។[៦៣]

**ឧទាហរណ៍៖** ក្រោយពីរៀបការជាមួយនិង ណារី បានជាប្រហែលជាមួយខែ ម្តាយមីង (ហៅថា ទាយក) របស់ សំខាន់ បានប្រគល់ផ្ទះមួយល្វែងអោយ សំខាន់ (ហៅថា បដិគ្គាហក)។ ក្នុងករណីបែបនេះ ទោះបីជាប្រទានកម្មបានធ្វើអំឡុងពេលដែល សំខាន់ មានចំណងអាពាហ៍ពិពាហ៍ជានិង ណារី ក៏ផ្ទះមួយលែងនេះត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក។

---

[៦២] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧២

[៦៣] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៥៦៩

សូមធ្វើការកត់សម្គាល់ថា ប្រសិនបើទាយកធ្វើប្រទានកម្មអោយសហព័ទ្ធទាំងសងខាង ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។ យ៉ាងណាមិញ ប្រសិនបើទាយកមិនបានបង្ហាញឆន្ទៈច្បាស់លាស់វិញ គេត្រូវពិនិត្យទៅលើស្ថានភាពជាក់ស្តែងនៃការធ្វើប្រទានកម្មនោះ។

**ឧទាហរណ៍ ៖** នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍រវាង សំខាន់ និង ណារី ម្តាយមីងរបស់ សំខាន់ បានចងដៃនូវរថយន្តមួយគ្រឿង។ ក្នុងស្ថានភាពបែបនេះ គួរចាត់ទុកថា រថយន្តនោះ គឺជាទ្រព្យសម្បត្តិរួម ពីព្រោះថា ការចងដៃគឺសម្រាប់អ្នកទាំងពីរនាក់ មិនមែនសម្រាប់តែកូនក្រមុំ ឬកូនកម្លោះនោះទេ។

- **សន្តតិកម្ម** គឺជារបៀបនៃការផ្ទេរមរតកតាមការកំណត់របស់ច្បាប់ពីមតកជន (អ្នកស្លាប់)មកអោយសន្តតិជន។

**ឧទាហរណ៍៖** ក្រោយពីរៀបការជាមួយនឹង ណារី បានប្រហែលជាមួយខែ ឪពុក (មតកជន) របស់ សំខាន់ បានស្លាប់បាត់បង់ជីវិត។ ក្នុងករណីបែបនេះ គឺមានតែសំខាន់ ប៉ុណ្ណោះដែលជា**សន្តតិជន (អ្នកមានសិទ្ធិទទួលសន្តតិកម្ម ឬមរតក**)ចំណែកឯ ណារី មិនមែនជាសន្តតិជនទេ តាមច្បាប់ស្តីពីសន្តតិកម្ម។ ឧបមាថា ក្នុងនាមសន្តតិជន សំខាន់ ទទួលបានមរតកពីឪពុកនូវដីមួយកន្លែង និងប្រាក់ចំនួន ២០ម៉ឺនដុល្លារនេះជាទ្រព្យសម្បត្តិដោយឡែករបស់ សំខាន់ ទោះបីជាគាត់ទទួលបាន នៅក្នុងពេលដែលគាត់មានចំណងអាពាហ៍ពិពាហ៍ជាមួយនិង ណារី ក៏ដោយ។

- **អច្ច័យទាន** គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅអោយមនុស្សម្នាក់ ឬច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគនោះ (**អច្ច័យទានសកល**) ឬក៏ជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ទៅមនុស្សម្នាក់ ឬច្រើននាក់ (**អច្ច័យទានមានកំណត់**)។

**ឧទាហរណ៍ ៖** បន្ទាប់ពីបានរៀបការជាមួយនិង ណារី បានមួយឆ្នាំគន្លងផុតទៅ ឪពុកមារបស់ សំខាន់ បានស្លាប់បាត់បង់ជីវិត ហើយគាត់បានបន្សល់ទុកនូវបណ្តាំ (មតកសាសន៍) មួយច្បាប់ដែលមានខ្លឹមសារប្រគល់រថយន្តមួយគ្រឿង ម៉ាកតូយូតាអោយ សំខាន់។ ក្នុងករណីនេះរថយន្តមួយគ្រឿងនេះ គឺជាអច្ច័យទានមានកំណត់ដែល ឪពុកមា (ម្ចាស់បណ្តាំ) បានប្រគល់ទៅអោយ សំខាន់ ហៅថា អច្ច័យលាភី)។ ទោះបីជា សំខាន់ ទទួលបានរថយន្តនេះនៅក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍ជាមួយនិង ណារី ក៏ដោយ ក៏រថយន្តនោះ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក សំខាន់ ដែរ។

- **ទ្រព្យសម្បត្តិដែលជាតម្លៃតប ទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិខាងលើនេះ (ទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទានក្នុងអំឡុងពេល ណារី និង សំខាន់ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍)។**

**ឧទាហរណ៍៖** មុនពេលរៀបអាពាហ៍ពិពាហ៍ សំខាន់ មានរថយន្តមួយគ្រឿង រថយន្តគឺជាទ្រព្យ។ រថយន្តនេះ គឺជាសម្បត្តិដោយឡែករបស់ សំខាន់។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយនិង ណារី រួចហើយ សំខាន់

បានលក់រថយន្តនោះក្នុងតម្លៃ ៥,០០០ដុល្លារ។ ប្រាក់ ៥,០០០ដុល្លារគឺជាតម្លៃតបនៃទ្រព្យសម្បត្តិដោយឡែក។ ដូចនេះ ប្រាក់ ៥,០០០ ដុល្លារ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ សំខាន់។

ទន្ទឹមនឹងនេះ សូមធ្វើការកត់សម្គាល់ថា៖ ចំពោះទ្រព្យសម្បត្តិដោយឡែក ជាប្រាក់ គឺងាយស្រួលនឹងច្របូកច្របល់ជាមួយនឹងទ្រព្យសម្បត្តិរួមណាស់។ ហេតុនេះ ប្រសិនបើមានភស្តុតាងថា ប្រាក់នោះជាទ្រព្យសម្បត្តិដោយឡែកទេ ភាគច្រើននឹងត្រូវចាត់ទុកថា ទ្រព្យសម្បត្តិរួម ជាពិសេស នៅពេលដែលយកប្រាក់ដែលជាទ្រព្យសម្បត្តិដោយឡែកទៅទិញវត្ថុអ្វីមួយ នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ គឺពិបាកនឹងរកភស្តុតាងថាប្រាក់ដែលយកទៅប្រគល់អោយអ្នកលក់ គឺជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងឡើយ។

**ឧទាហរណ៍៖** ក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ សំខាន់ យកប្រាក់ ៥,០០០ ដុលារ ដែលបានមកពីការលក់រថយន្ត ទៅទិញដីមួយកន្លែងក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ដីមួយកន្លែងនោះគឺគួរថាចាត់ទុកជាទ្រព្យសម្បត្តិដោយឡែកដែរ ប្រសិនបើមានភស្តុតាងច្បាស់លាស់ថា ប្រាក់ដែលយកទៅបង់អោយអ្នកលក់ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ សំខាន់។ បើមិនអញ្ចឹងទេ ដីមួយកន្លែងនោះត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួម។ ដោយឡែកពាក់ព័ន្ធនឹងការកំណត់ពីទ្រព្យសម្បត្តិដោយឡែក មានបញ្ហាមួយចំនួនដែលគួរពិចារណា៖

- **សម្លៀកបំពាក់ ឬគ្រឿងអលង្ការដែលបានទិញ ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ (ជាទូទៅ គឺយកប្រាក់រួមទៅទិញ) តើគួរចាត់ទុកជាទ្រព្យសម្បត្តិរួម ឬចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក ពីព្រោះថា ទ្រព្យទាំងនោះ គឺសម្រាប់បម្រើផលប្រយោជន៍បុគ្គលរបស់សហព័ទ្ធរៀងៗខ្លួន។** បើតាមអត្ថន័យនៃក្រមរដ្ឋប្បវេណី គួរចាត់ទុកថា ជាទ្រព្យសម្បត្តិរួម ពីព្រោះថា ពុំមានមាត្រាណាមួយដែលប្បញ្ញត្តិពីករណីលើកលែងឡើយ។ ទោះបីជាយ៉ាងណា យុទ្ធសាស្ត្ររបស់តុលាការអាចកំណត់ផ្សេង ដោយយោងទៅតាមលក្ខណៈនៃវត្ថុនោះ។
- **ករណីដែលយកទ្រព្យរួម ទៅបញ្ចូលជាមួយនិងទ្រព្យដោយឡែកគឺត្រូវយកមាត្រា ១៨៦ និង មាត្រា ១៩៨នៃក្រមរដ្ឋប្បវេណីទៅអនុវត្ត។**

**ឧទាហណ៍ ៖** នៅមុនពេលរៀបការ កញ្ញា មានដីមួយកន្លែង។ ក្រោយពីបានរៀបការជាមួយនិង សំភី រួចអ្នកទាំងពីរក៏បានខិតខំធ្វើការសន្សំប្រាក់បានមួយចំនួន ហើយក៏បានសម្រេចចិត្តសាងសង់ផ្ទះមួយល្វែងលើដីនោះអស់ប្រាក់ចំនួន២០,០០០ដុល្លារ។ ក្នុងករណីនេះ ដោយហេតុថា ដីជាកម្មសិទ្ធដោយឡែករបស់ កញ្ញា ហេតុនេះទាំងដីទាំងផ្ទះនឹងក្លាយជាកម្មសិទ្ធិរបស់ កញ្ញា ដែរ(មាត្រា ១៨៦)។ ក៏ប៉ុន្តែ ដោយផ្អែកលើបទប្បញ្ញត្តិនៃសេចក្តីចម្រើនឥតហេតុនៅពេលលែងលះសំភី អាចទាមទារអោយ កញ្ញា សងប្រាក់អោយខ្លួនចំនួន ១០,០០០ដុល្លារ (ពាក់កណ្តាលនៃថ្លៃសំណង់ដី)។

- **ចំពោះសិទ្ធិដែលមានលក្ខណៈផ្ទាល់ខ្លួនសម្រាប់សហព័ទ្ធ ឧទាហរណ៍ដូចជាសិទ្ធិទទួលបាននៅអាហារកាតព្វកិច្ច ជាដើម គឺត្រូវបានចាត់ទុកថាជាសិទ្ធផ្តាច់មុខរបស់សហព័ទ្ធម្នាក់ៗ ដោយពុំអាចធ្វើការបែងចែកជាមួយនឹងសហព័ទ្ធម្ខាងទៀតឡើយ។**

**ឧទាហរណ៍ ៖** ដារ៉ា មានសិទ្ធិទទួលបាននៅអាហារកាតព្វកិច្ច ពីឪពុករបស់គាត់នៅទឹកប្រាក់ចំនួន២០០ ដុល្លារ ក្នុងមួយខែ។ ប្រាក់២០០ដុល្លារនេះ គួរត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិរួម កាលបើប្រាក់ទាំងនេះទទួលបានក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែប្រសិនបើមានការលែងលះរវាង ដារ៉ា និង ភរិយា សិទ្ធិទទួលបាននៅអាហារកាតព្វកិច្ច មិនអាចធ្វើការបែងចែកជាមួយភរិយារបស់គាត់បានឡើយ ពីព្រោះថា សិទ្ធិនេះមានលក្ខណៈផ្ទាល់ខ្លួន និយាយម្យ៉ាងវិញទៀតថា សិទ្ធិនេះនៅតែជាសិទ្ធិផ្តាច់មុខរបស់ ដារ៉ា ដដែល។

➢ **ទ្រព្យសម្បត្តិរួម**

**ទ្រព្យសម្បត្តិរួម** គឺជាទ្រព្យសម្បត្តិដែលប្តី ប្រពន្ធទាំងសងខាង ឬ ប្តីប្រពន្ធតែម្ខាង ទទួលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[៦៤] ដូច្នេះ ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធមានដូចជា ៖

- ចំណូលបានមកពីការងាររបស់សហព័ទ្ធម្នាក់ៗ ដូចជាប្រាក់បៀវត្ស។ល។
- ផល (អត្ថប្រយោជន៍ ដែលកើតពីអ្វីមួយ ឧទាហរណ៍ ៖ប្រាក់ឈ្នួលអាគារ) នៃទ្រព្យសម្បត្តិដោយឡែក។

**ឧទាហរណ៍ ៖** សំខាន់ មានផ្ទះមួយល្វែងដែលជាទ្រព្យសម្បត្តិដោយឡែករបស់គាត់ ហើយគាត់បានជួលផ្ទះនេះឱ្យគេបានប្រាក់ឈ្នួល ២.០០០ដុល្លារ ក្នុងមួយខែ។លុះដល់ថ្ងៃទី ០១.០២.២០១២ សំខាន់ បានរៀបការជាមួយនឹង ណារី។ ប្រាក់ឈ្នួល២.០០០ ដុល្លារ ក្នុងមួយខែ ដែលទទួលបានចាប់ពីថ្ងៃទី០១.០២.២០១២ រហូតដល់ពេលរំលាយអាពាហ៍ពិពាហ៍ គឺជាផលនៃទ្រព្យសម្បត្តិដោយឡែកដែលក្រមរដ្ឋប្បវេណីចាត់ទុកថាជាទ្រព្យសម្បត្តិរួម។

**ឧទាហរណ៍ ៖** សំខាន់ មានភាគហ៊ុន ចំនួន ៥ភាគរយ នៅក្នុងក្រុមហ៊ុនមួយនៅមុនពេលរៀបអាពាហ៍ពិពាហ៍។ នេះគឺជាទ្រព្យសម្បត្តិដោយឡែករបស់ សំខាន់។ ភាគហ៊ុននេះបានផ្តល់នូវ ភាគលាភ(ប្រាក់ចំណេញ) ប្រមាណជា១០.០០០ដុល្លារ ក្នុងមួយឆ្នាំ។ ហេតុដូច្នេះបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍រួចភាគលាភចំនួន ១០.០០០ដុល្លារ ក្នុងមួយឆ្នាំ ដែលទទួលបានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ក៏ត្រូវបានគេចាត់ទុកថាជាទ្រព្យសម្បត្តិរួមដែរ។

ចំពោះកម្មសិទ្ធបញ្ញា ដូចជាសិទ្ធអ្នកនិពន្ធជាដើម គឺត្រូវធ្វើការបែងចែករវាង សិទ្ធិសីលធម៌(សិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធ) និងសិទ្ធិបេតិកភណ្ឌ(សិទ្ធធ្វើអាជីវកម្មលើស្នាដៃដើម្បីទទួលបានប្រាក់កម្រៃ)។ ដូច្នេះ ប្រាក់កម្រៃដែលបានមកពីការធ្វើអាជីវកម្មលើស្នាដៃដែលទទួលបានក្នុងអំឡុងពេលមានចំណអាពាហ៍ពិពាហ៍ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។

**ឧទាហរណ៍ ៖** សំខាន់ បាននិពន្ធសៀវភៅរឿងមួយក្បាលនៅឆ្នាំ ២០១១។គាត់ទទួលបានប្រាក់កម្រៃពីការលក់សៀវភៅនេះប្រមាណជា២០០០ដុល្លារ ក្នុងមួយឆ្នាំ។ នៅដើមឆ្នាំ ២០១២ សំខាន់ បានរៀបការជាមួយនឹង ណារី។ ប្រាក់កម្រៃ ២,០០០ដុល្លារ ដែលទទួលបានចាប់ពីឆ្នាំ ២០១២ រហូតដល់ពេលរំលាយអាពាហ៍ពិពាហ៍

[៦៤] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៣

(ឧទាហរណ៍ ៖ លែងលះ)គឺជាទ្រព្យសម្បត្តិរួម។ ក៏ប៉ុន្តែ ក្នុងករណីមានការលែងលះស្នាដៃនិពន្ធនេះត្រូវបានទៅលើអ្នកនិពន្ធផ្ទាល់គឺ សំខាន់។

**ខ.១.២. ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ**

- **ការគ្រប់គ្រងទ្រព្យសម្បត្តិរួម**

សម្រាប់ទ្រព្យសម្បត្តិរួម សហព័ទ្ធម្នាក់ៗមានសិទ្ធិប្រើប្រាស់ទ្រព្យរួម ក្នុងទំហំចាំបាច់ ដោយផ្អែកលើការចាំបាច់ ដោយផ្អែកលើការចាំបាច់នៃជីវភាព និងគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា។[៦៥] ពោលគឺចាំបាច់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ដូចជាការប្រើប្រាស់រថយន្តទៅធ្វើជូនកូនទៅសាលារៀន។ល។

ពាក្យ **គ្រប់គ្រង** ជាពាក្យដែលមានន័យមិនសូវច្បាស់លាស់ ហើយក្រមរដ្ឋប្បវេណីក៏មិនបានផ្តល់និយមន័យជាក់លាក់ចំពោះពាក្យនេះដែរ។ ដូច្នេះ ការជួសជុលទ្រព្យសម្បត្តិរួមការជួលទ្រព្យសម្បត្តិរួម ក៏គួរតែត្រូវចាត់ទុកថាជាសកម្មភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរួមដូច្នេះដែរ។[៦៦]

**ឧទាហរណ៍៖** កញ្ញា មានបំណងយកដីមួយកន្លែងដែលជាទ្រព្យសម្បត្តិរួមទៅជួលអោយអ្នកដទៃ ក៏ប៉ុន្តែប្តីរបស់នាងមិនព្រម។ ក្នុងករណីបែបនេះ កញ្ញា អាចទាមទារទៅតុលាការអោយសម្រេចពីបញ្ហានេះបាន។

**ឧទាហរណ៍៖** ភក្តី បានទិញផ្ទះមួយល្វែងក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយនិង ធីតា ដោយចុះបញ្ជីដាក់ឈ្មោះ ភក្តី តែម្នាក់ឯង ពីព្រោះគិតថា នឹងងាយស្រួលសម្រាប់ការលក់ដូរ ដោយមិនចាំបាច់ត្រូវមានវត្តមាន របស់ ធីតា នៅថ្ងៃក្រោយ ហើយ ធីតា បានយល់ព្រមដូច្នេះដែរ។ ក្រោយមកធីតាមានបំណងចង់ចុះបញ្ជីកម្មសិទ្ធិដាក់ឈ្មោះនាងជាបន្ថែមទៀត។ ប្រសិនបើ ភក្តី មិនយល់ព្រម ទេ ធីតា អាចទាមទារទៅតុលាការ អោយសម្រេចពីបញ្ហានេះបាន។

លើសពីនេះទៀត ចំពោះការចាត់ចែងទ្រព្យសម្បត្តិរួម តម្រូវឱ្យមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង។ ក៏ប៉ុន្តែ បើមានស្ថានភាពមិនអាចជៀសវាងបាន ដើម្បីថែរក្សាជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីថែរក្សាជីវភាពរស់នៅ ប្តី ឬប្រពន្ធ អាចលក់ ឬធ្វើការចាត់ចែង ដោយទទួលបានការអនុញ្ញាតពីតុលាការ។[៦៧]

**ឧទាហរណ៍ ៖** ដារ៉ា និង ធីតា ជាសហព័ទ្ធនឹងគ្នា ក៏ប៉ុន្តែបានរស់នៅបែកលំនៅឋានពីគ្នា ដោយមិនធ្វើការលែងលះគ្នាទេ។ ក្រោយមក ដោយសារតែកង្វះខាតក្នុងជីវភាព ជាពិសេសគឺកង្វះខាតប្រាក់សម្រាប់ព្យាបាលជំងឺកូន ធីតា មានបំណងលក់ដីមួយកន្លែងដែលជាទ្រព្យសម្បត្តិរួម តែដារ៉ា មិនយល់ព្រម។ ក្នុងករណីនេះ ធីតា អាចទាមទារអោយតុលាការ សម្រេចបាន។

[៦៥] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៤ កថាខណ្ឌទី១ និងកថាខណ្ឌទី២

[៦៦] សាស្ត្រាចារ្យ ចាំង ស៊ីណាត "នីតិគ្រួសារ" ឆ្នាំ២០១៣ ទំព័រទី១៤៨

[៦៧] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៦ កថាខណ្ឌទី១ និង កថាខណ្ឌទី២

នៅក្នុងករណីដែល ប្តី ឬប្រពន្ធ ណាម្ខាងបានធ្វើការចាត់ចែងទ្រព្យសម្បត្តិរួមដោយមិនមានការយល់ព្រម ពីសហព័ទ្ធម្ខាងទៀត ឬ ពុំមានការអនុញ្ញាតពីតុលាការទេ ភាគី ម្ខាងទៀតអាចទាមទារទៅតុលាការលុបចោលការ ចាត់ចែងនោះ ៖

- បើជាអចលនវត្ថុ សម្រាប់ការអាស្រ័យនៅរបស់គ្រួសារ ៖ ត្រូវប្តឹងក្នុងអំឡុងពេល២ឆ្នាំ គិតចាប់ពីដឹងពី ការចាត់ចែងនោះ។
- បើជាទ្រព្យសម្បត្តិផ្សេងទៀត (អចលនវត្ថុ ឬចលនវត្ថុ) ៖ ត្រូវប្តឹងក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីដឹងពី ការចាត់ចែងនោះ។

**ឧទាហរណ៍** ៖ ដារ៉ា និង ធីតាជាសហព័ទ្ធនឹងគ្នា ក៏ប៉ុន្តែ បានរស់នៅបែកគ្នាដោយមិនបានលែងលះ ឡើយ ហើយ ធីតា និងកូនបន្តរស់នៅលើផ្ទះដែលជាទ្រព្រសម្បត្តិរួមរបស់សហព័ទ្ធ។ ក្រោយមកធីតា បានលក់ផ្ទះ នេះទៅអោយតតិយជន។ ជាក់ស្តែង ផ្ទះដែលជាកម្មវត្ថុនៃការលក់នេះ គឺជាអចលនវត្ថុសម្រាប់អាស្រ័យនៅរបស់ គ្រួសារ។ ដូចនេះ ដារ៉ា មានអំឡុងនៃការប្តឹង ទាមទារលុបចោលរហូតដល់ទៅ ២ឆ្នាំ គិតចាប់ពីពេលដែល ដារ៉ា បានដឹងពីការលក់នេះ។

**ឧទាហរណ៍** ៖ ដារ៉ា និងធីតា ជាសហព័ទ្ធនឹងគ្នា ក៏ប៉ុន្តែបានរស់នៅបែកបាក់គ្នាដោយមិនបានលែងលះ ឡើយ ដោយនៅពេលចាកចេញពីផ្ទះទៅ ដារ៉ា បានយករថយន្តមួយគ្រឿងទៅតាម។ ក្រោយមក ដារ៉ា បានយក រថយន្តនេះទៅលក់ឱ្យ សុភាព ដោយមិនមានការយល់ព្រមពីធីតាឡើយ។ ក្នុងករណីនេះធីតា មានអំឡុងពេល មួយឆ្នាំ ដើម្បីទាមទារការលុបចោលការលក់ខាងលើនេះ។

ពាក់ព័ន្ធនឹងចលនវត្ថុ ថ្វីត្បិតតែក្រមរដ្ឋប្បវេណីអនុញ្ញាតអោយឱ្យប្តឹងលុបចោលការចាត់ចែងដែលមិន មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬ ពុំមានការអនុញ្ញាតិពីតុលាការ ក៏ដោយ ក៏ប៉ុន្តែ តតិយជនដែលទទួល បាននៅអនុប្បទានចលនវត្ថុ ដោយសុចរិត និងគ្មានកំហុស អាចលើកសំអាងពីមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណី បានដើម្បីរក្សាសិទ្ធិរបស់ខ្លួនលើចលនវត្ថុនោះ។

**ឧទាហរណ៍** ៖ ក្រោយពីភក្តី បានចាកចេញពីផ្ទះទៅ ចិន្តា ដែលជាប្រពន្ធរបស់ ភក្តី បានយកទូរទស្សន៍ ដែលជាទ្រព្យសម្បត្តិរួមទៅលក់ឱ្យ សំភី យកប្រាក់ ដើម្បីចាយវាយផ្គត់ផ្គង់ជីវភាពគ្រួសារ។ ប្រសិនបើ ភក្តី ប្តឹង ទាមទារលុបចោលការលក់ទូរទស្សន៍ នេះ សំភី អាចលើកសំអាង មាត្រា ១៩៣នៃក្រមរដ្ឋប្បវេណី (លទ្ធកម្ម ដោយសុចរិត) ដើម្បីកុំអោយបាត់បង់កម្មសិទ្ធរបស់គាត់ សំភី ត្រូវបញ្ជាក់ថាគាត់បានទិញទូរទស្សន៍ពី ចិន្តា ដោយត្រឹមត្រូវ ហើយគាត់ក៏បានទទួលការកាន់កាប់ទូរទស្សន៍រួចហើយដែរ ព្រមទាំងពុំមានភស្តុតាងបញ្ជាក់ថា គាត់ទុច្ចរិត និងមានកំហុស (**គ្មានភស្តុតាង បញ្ជាក់ថា សំភី បានដឹងថា ទូរទស្សន៍នេះជាទ្រព្យរួមនោះឡើយ**)។ ដើម្បី អាចទទួលបានជោគជ័យនៅក្នុងបណ្តឹងនេះ ភក្តី ត្រូវរកភស្តុតាង មកបញ្ជាក់ថា សំភី បានដឹងថា ទូរទស្សន៍ នេះជាទ្រព្យរួមរបស់ប្តី ប្រពន្ធ គាត់ហើយ តែនៅតែទិញទូរទស្សន៍នេះទៀត។ ប្រសិនបើមានភស្តុតាង យ៉ាងដូច្នេះ មែន សំភី មិនអាចសំអាងលើមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីបានឡើយ ពោលគឺ សំភី ត្រូវប្រគល់ទូរទស្សន៍

ឱ្យទៅ ភក្តី និង ចិន្តា។ ក្នុងស្ថានភាពបែបនេះ សំភី អាចប្តឹង ចិន្តា ទាមទារសំណងនៃការខូចខាតដោយ ផ្អែកលើកិច្ចសន្យារវាងគាត់ និង ចិន្តា។

➢ **ការគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក**

ជាគោលការណ៍ សហព័ទ្ធដែលជាម្ចាស់ទ្រព្យមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដោយសេរី។ ក៏ប៉ុន្តែ មានចំណុចដែលខុសពីអត្ថន័យខាងលើផងដែរ ដូចជា ៖

**១.ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើប្រាស់សម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន។**

**២.ក្នុងករណីប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះទោះបីសហព័ទ្ធ ម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះដែរ។**[៦៨]

ចំណុចទាំងនេះ បានបង្កើតនូវសិទ្ធអាស្រ័យនៅសម្រាប់សហព័ទ្ធ នៅលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត កាលបើអចលនវត្ថុនោះត្រូវបានប្រើប្រាស់សម្រាប់ជាការអាស្រ័យនៅរបស់ គ្រួសារ។ សិទ្ធិនេះអាចអះអាងបានចំពោះគ្រប់បុគ្គលទាំងអស់ ទោះបីជាមានការផ្ទេរកម្មសិទ្ធលើអចលនវត្ថុទៅអោយតតិយជនក៏ដោយ។

**ឧទាហរណ៍ ៖** ក្រោយពីបានរៀបការរួចហើយចិន្តា បានមករស់នៅជាមួយនិង ដារិត ជាប្តីរបស់នាង នៅលើផ្ទះដែលជាកម្មសិទ្ធរបស់ ដារិត។ ក្នុងករណីនេះ មានន័យថា ផ្ទះខាងលើត្រូវបានប្រើប្រាស់ដើម្បី ជាការអាស្រ័យ នៅរបស់គ្រួសារ។ ជាងនេះទៅទៀត រយះពេល ៣ឆ្នាំ នៃការរួមរស់ជាមួយគ្នា អ្នកទាំងពីរមានកូនបីនាក់។ លុះបានបន្តិចក្រោយមក អ្នកទាំងពីរមានទំនាស់នឹងគ្នា។ នៅទីបំផុត ដារីត បានសម្រេចចិត្តលក់ផ្ទះខាងលើឱ្យឈ្មោះ មុនី។ ការចាត់ចែងលក់ដូរខាងលើនេះអាចធ្វើបានដោយត្រឹមត្រូវតាមច្បាប់ ពីព្រោះ ថាផ្ទះនេះជាទ្រព្យសម្បត្តិដោយឡែករបស់ ដារីត។ ប៉ុន្តែ ដរាបណាមិនទាន់បានលែងលះគ្នា ចិន្តា នៅតែជាសហព័ទ្ធរបស់ ដារីត ហើយនាងមានសិទ្ធិអាស្រ័យនៅផ្ទះនោះ ស្របតាមអត្ថន័យនៃមាត្រា ៩៧៧ នៃ ក្រមរដ្ឋប្បវេណី ពោលគឺសិទ្ធិរបស់ ចិន្តា អាចយកទៅអះអាងចំពោះ មុនី បាន។ និយាយមួយបែបទៀតថា ក្រោយពីបានទិញផ្ទះ ខាងលើរួចហើយ មុនី មិនអាចបណ្តេញ ចិន្តា និង កូនរបស់នាងឱ្យចេញពីផ្ទះ ដោយសំអាងថា នាងមានកម្មសិទ្ធិលើផ្ទះនោះបានឡើយ ពីព្រោះថាបទប្បញ្ញត្តិនៃមាត្រា ៩៧៧ បានផ្តល់សិទ្ធិអាស្រ័យនៅឱ្យ ចិន្តា និង កូនៗរបស់នាង ទោះបីជា ដើរីត បានលក់ផ្ទះទៅអោយអ្នកដ៏ទៃហើយក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ សិទ្ធិរបស់ ចិន្តា ដូចខាងលើនិងត្រូវរលត់នៅពេលដែល ចិន្តា លែងជាសហព័ទ្ធរបស់ដើរីត។

[៦៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៧ កថាខណ្ឌទី១ និង កថាខណ្ឌទី២

**ខ.២. ទ្រព្យសម្បត្តិអកម្មរបស់សហព័ទ្ធ**

ក្រៅពីទ្រព្យសម្បត្តិសកម្ម សហព័ទ្ធក៏អាចមានទ្រព្យសម្បត្តិអកម្មដែលជាកាតព្វកិច្ច ឬបំណុលផងដែរ ដោយកាតព្វកិច្ច ឬ បំណុលខ្លះបានកើតឡើង នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ទៅទៀត។

**ខ.២.១. កាតព្វកិច្ចដែលកើតឡើងនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍**

ជាធម្មតាកាតព្វកិច្ច ឬបំណុលដែលកើតមានឡើងនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍អាចជា៖

- **កាតព្វកិច្ចដែលសហព័ទ្ធទទួលខុសត្រូវដោយសាមគ្គីភាព** (*កាតព្វកិច្ចដោយសាមគ្គីភាព* គឺជាកាតព្វកិច្ចដែលម្ចាស់បំណុល អាចទាមទារឱ្យកូនបំណុលណាម្នាក់អនុវត្តកាតព្វកិច្ច ទាំងអស់ ឬមួយភាគ ឬឱ្យកូនបំណុលទាំងអស់អនុវត្តទាំងអស់ ឬមួយភាគ ដោយព្រមគ្នា ឬដោយបន្តបន្ទាប់)[៦៩] រួមមាន៖
  - ➢ សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូនជាអាទិ៍។ **ឧទាហរណ៍** ៖ ប្រាក់ជំពាក់ថ្លៃម្ហូបអាហារប្រចាំថ្ងៃ របស់ប្ដីប្រពន្ធ។
  - ➢ កាតព្វកិច្ច និងករណីយកិច្ចផ្សេងទៀត ដែលប្ដីប្រពន្ធ ទាំងសងខាងតាមលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច ឬ ករណីកិច្ចផ្សេងៗទៀតដែលប្ដីប្រពន្ធបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរពីប្ដី ឬប្រពន្ធម្ខាងទៀត នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ **ឧទាហរណ៍** ៖ ប្ដីបានខ្ចីប្រាក់ចំនួន ៥០០ ដុល្លារ ពីអ្នកជិតខាង ដើម្បីយកទៅព្យាបាល ឪពុករបស់គាត់ ដោយប្រពន្ធបានយល់ព្រមអោយខ្ចី តាមលិខិតជាលាយលក្ខណ៍អក្សរ។
  - ➢ សោយហ៊ុយដើម្បីគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរួម។ **ឧទាហរណ៍** ៖ នារីជាភរិយាបានហៅជាងអោយមកជុសជុលផ្ទះដែលជាទ្រព្យសម្បត្តិរួមអស់ប្រាក់៥០០០ដុល្លារ។

ដូច្នេះ សម្រាប់កាតព្វកិច្ចដែលមានលក្ខណៈជាកាតព្វកិច្ចដោយសាមគ្គីភាពដូចបានរៀបរាប់ខាងលើនេះ ម្ចាស់បំណុលអាចទាមទារពីប្ដី ឬប្រពន្ធតែម្ខាងក៏បាន ឬទាមទារពីសហព័ទ្ធទាំងសងខាងក៏បានដែរ អាស្រ័យ ទៅតាមការជ្រើសរើសរបស់ម្ចាស់បំណុល។

**ឧទាហរណ៍** ៖ នារីជាប្រពន្ធបានជំពាក់ថ្លៃម្ហូបអាហារសម្រាប់បរិភោគនៅក្នុងក្រុមគ្រួសារចំនួន ១០០០ ដុល្លារ។ បំណុលនេះ គឺជាកាតព្វកិច្ចដោយសាមគ្គីភាព ពោលគឺម្ចាស់បំណុលអាចទាមទារប្រាក់នេះតែពីនារីជាប្រពន្ធក៏បាន ឬទាមទារតែពីបុរសជាប្ដីក៏បាន ឬទាមទារពីអ្នកទាំងពីរក៏បាន។ ម្ចាស់បំណុលអាចទាមទារអោយអនុវត្តលើទ្រព្យសម្បត្តិរួមក៏បាន ឬនៅលើទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្នាក់ក៏បានដែរ។ សូម្បីតែក្នុងករណីដែលប្ដីប្រពន្ធបានលែងលះគ្នាហើយក៏ដោយ ក៏ម្ចាស់បំណុលមានសិទ្ធិធ្វើជម្រើសដូចខាងលើបានដែរ។

[៦៩] សាស្ត្រាចារ្យ ចាំង ស៊ីណាត "នីតិគ្រួសារ" ឆ្នាំ២០១៣ ទំព័រទី១៥៤

និយាយជារួម នៅពេលដែលប្តីប្រពន្ធ បានលែងលះគ្នា នោះម្ចាស់បំណុលនឹងជ្រើសរើសប្តឹងពីអ្នកណាដែលមានលទ្ធភាពសងបំណុលបានច្រើនជាងគេ។

- **កាតព្វកិច្ចផ្សេងទៀតដែលកើតមានឡើង ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍** គឺរួមមានដូចជា៖
  - ការខ្ចីប្រាក់ដោយសហព័ទ្ធម្ខាង ដោយសហព័ទ្ធម្ខាងសហព័ទ្ធម្ខាងទៀតពុំបានយល់ព្រម ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនរបស់សហព័ទ្ធនោះ។ **ឧទាហរណ៍ ៖** ប្តីខ្ចីប្រាក់អ្នកដ៏ទៃ យកទៅលេងល្បែងស៊ីសង។
  - កាតព្វកិច្ច ដែលកើតឡើងដោយសារអំពើរបស់ខ្លួន របស់សហព័ទ្ធម្ខាង។ **ឧទាហរណ៍៖** នៅពេលកំពុងបើកបររថយន្តចាកចេញពីភោគជនីយដ្ឋានជាមួយនឹងមិត្តភក្តិ បុរសជាប្តីបានបង្កអោយមានគ្រោះថ្នាក់ចរាចរណ៍ ហើយត្រូចសងការខូចខាតទៅអោយជនរងគ្រោះនៅទឹកប្រាក់ចំនួន ៨លានរៀល។
  - កាតព្វកិច្ច ដែលកើតឡើងពីការទទួលខុសត្រូវ របស់សហព័ទ្ធម្ខាង ក្នុងនាមជាអ្នកព្យាបាលសម្រាប់អនីតិជន។ **ឧទាហរណ៍ ៖** បុរសជាប្តីត្រូវបានជ្រើសតាំងជាអ្នកអាណាព្យាបាលសម្រាប់ អនីតិជនឱ្យក្មួយរបស់គាត់ដែលមានអាយុ១៥ឆ្នាំ ហើយគាត់ត្រូវទទួលខុសត្រូវសងការខូចខាតដែលបង្កដោយសារតែក្មួយរបស់គាត់ចំនួន ២លានរៀល។
  - កាតព្វកិច្ចដែលកើតឡើងដោយសារតែការគ្រប់គ្រងថែរក្សារទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ។ **ឧទាហរណ៍៖**នារីជាប្រពន្ធបានជំពាក់ប្រាក់ថ្លៃជុសជុលផ្ទះចំនួន១០០០ ដុល្លារ ដោយផ្ទះនោះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់នាង។

**ខ.២.២. កាតព្វកិច្ចដែលកើតឡើងមុនពេលមានចំណងអាពាហ៍ពិពាហ៍**

ក្នុងករណីខ្លះ មុនពេលនឹងរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធណាម្ខាងបានជាប់កាតព្វកិច្ចចំពោះម្ចាស់បំណុលរួចជាស្រេចទៅហើយ។ ឧទាហរណ៍៖ កញ្ញា បានជំពាក់ប្រាក់ ដារ៉ា ចំនួន២០,០០០ដុល្លារ ដោយកំណត់សងនៅដើមខែតុលា ឆ្នាំ២០១២។ នៅខែកញ្ញា ឆ្នាំ ២០១២ កញ្ញា បានរៀបការជាមួយនឹង សំភី។

ក្នុងសម្មតិកម្មបែបនេះបំណុលដែល កញ្ញា បានជំពាក់ ដារ៉ា គឺជាបំណុលដែលកើតមានមុនពេល ដែលកញ្ញា រៀបការជាមួយនិងសំភី។ ដូច្នេះគឺមានតែ កញ្ញា ប៉ុណ្ណោះដែលមានការឲ្យតព្វកិច្ចចំពោះ ដារ៉ា។ ប៉ុន្តែ បញ្ហាដែលចោទឡើងថា តើម្ចាស់បំណុលអាចទាមទារអោយអនុវត្តលើទ្រព្យសម្បត្តិរួមបានដែររឺទេ? ចម្លើយនៅហ្នឹងសំនួរនេះ គឺមិនមានកំណត់ជាក់លាក់ នៅក្នុងនៃក្រមរដ្ឋប្បវេណីនោះទេ ពោលគឺអាស្រ័យទៅតាមការបកស្រាយដូចករណីខាងលើដែរ។

ចំពោះករណីនេះ គប្បីអោយអនុវត្តលើទ្រព្យសម្បត្តិរួម ពីព្រោះថា ប្រាក់ចំណូលដែលកើតពីកម្លាំងញើសឈាមរបស់ កញ្ញា ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកថាទ្រព្យសម្បត្តិរួមដែរ។ ហេតុនេះគឺពិត

ជាការពុំសូវសមរម្យទេ ប្រសិនបើមិនអនុញ្ញាតឱ្យម្ចាស់បំណុលស្នើសុំឱ្យមានការរឹបអូសទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ដែលជាកូនបំណុល ដើម្បីយកមកទូទាត់សងបំណុលរបស់គាត់។

**ឧទាហរណ៍៖** ក្នុងសម្មតិកម្មខាងលើនេះ ឧបមាថា កញ្ញា និង សំភី មានទ្រព្យសម្បត្តិរួមដូចតទៅ៖ម៉ូតូមួយគ្រឿងដែលអ្នកទាំងពីរទើបតែទិញ និងប្រាក់ក្នុងគណនីធនាគាសម្រាប់ដាក់ប្រាក់ខែរបស់កញ្ញា និង សំភី។ កញ្ញា មានគ្រឿងអលង្ការមួយចំនួនដែលជាទ្រព្យសម្បត្តិដោយឡែករបស់នាង ហើយសំភីមានរថយន្តមួយគ្រឿងដែលទ្រព្យសម្បត្តិដោយឡែករបស់គាត់។ ដូច្នេះ បើផ្អែកតាមការបកស្រាយខាងលើនេះ ដារ៉ា ដែលជាម្ចាស់បំណុល អាចទាមទារឱ្យអនុវត្ត លើ(រឹបអូស) ទ្រព្យសម្បត្តិរួម(ម៉ូតូ និង ប្រាក់ក្នុងគណនី)ព្រមទាំងលើទ្រព្យសម្បត្តិដោយឡែករបស់ កញ្ញា។

### ២.២.៣. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះកូន

ឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវប្រើប្រាស់ អំណាចមេបា ដោយសហការគ្នា។[៧០]

**អំណាចមេបា** គឺជា សិទ្ធិ និង ករណីកិច្ចដែលត្រូវថែរក្សារូបកាយកូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិកូននោះ។[៧១] **ឧទាហរណ៍៖** ឪពុកម្តាយមានសិទ្ធិ និងករណីកិច្ចក្នុងការអប់រំកូន។ ដូច្នេះ ឪពុកម្តាយត្រូវសហការគ្នាក្នុងការជ្រើសរើសសាលារៀនឱ្យកូនរបស់គាត់ដែលជាអនីតិជន។

នៅក្នុងករណីដែលមានជម្លោះរវាងឪពុកម្តាយ ក្នុងការអនុវត្តអំណាចមេបាលើកូនជាអនីតិជន ជម្លោះនេះមិនមែនជាកម្មវត្ថុនៃការសម្រេចសេចក្តីដោយតុលាការបាននោះទេ ពោលគឺឪពុកម្តាយត្រូវជ្រើសរើសនៅវិធីណាមួយដែលល្អបំផុតសម្រាប់កូនដោយធ្វើការពិចារណាឱ្យបានម៉ត់ចត់។

**ឧទាហរណ៍៖** ប្រសិនបើឪពុកម្តាយមានជម្លោះពីរឿងជ្រើសរើសសាលារៀនឱ្យកូន គឺតុលាការមិនអាចសម្រេចពីបញ្ហានេះបានទេ។ មួយវិញទៀត បើឪពុក ឬម្តាយណាម្ខាងមិនអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬម្តាយម្ខាងទៀតត្រូវប្រើអំណាចមេបានោះ។[៧២] ករណីដែលឪពុក ឬម្តាយណាម្ខាងមិនអាចប្រើប្រាស់អំណាចមេបាបានដូចជា ៖ ឪពុក ឬម្តាយមានវិបល្លាសស្មារតីឬ បាត់ខ្លួន ឬ មិនអាចទាក់ទងបាន ឬត្រូវបានដកហូតអំណាចមេបា ( ឧទាហរណ៍ ៖ ឪពុកដែលធ្វើបាបកូន អាចត្រូវតុលាការសម្រេចដកហូតអំណាចមេបាបាន ) ជាដើម។

---

[៧០] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៦

[៧១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៤

[៧២] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៦ វាយក្យខណ្ឌទី២

# ជំពូកទី៣

# ការលែងលះនៃអាពាហ៍ពិពាហ៍

# ជំពូកទី៣

# ការលែងលះនៃអាពាហ៍ពិពាហ៍

ការលែងលះ គឺជាមូលហេតុនៃការផ្តាច់ចំណងអាពាហ៍ពិពាហ៍។ ក៏មិនខុសពីការរៀបអាពាហ៍ពិពាហ៍ដែរ ការលែងលះនិងធ្វើអោយមានការផ្លាស់ប្តូរឋានៈរបស់បុគ្គលពាក់ព័ន្ធនៅក្នុងសង្គម។ ក្នុងន័យនេះ ច្បាប់បាន បញ្ញត្តិយ៉ាងជាក់លាក់នូវមូលហេតុនៃការលែងលះ និងនីតិវិធីនៃការលែងលះព្រមទាំងអនុភាពផ្លូវច្បាប់ដែលកើត ឡើង ដោយសារការលែងលះទៀតផង។

## ៣.១. មូលហេតុនៃការលែងលះ

ជាដំបូង ការលែងលះរបស់សហព័ទ្ធដោយការព្រមព្រៀង ក្នុងករណីនេះ តុលាការសម្រេចអោយមានការ លែងលះគ្នា ប្រសិនបើតុលាការយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនង អាពាហ៍ពិពាហ៍។[៧៣]

ប្រសិនបើភាគីមិនមានការព្រមព្រៀងលែងលះនោះទេ ការលែងលះអាចធ្វើទៅបាន លុះត្រាតែមាន មូលហេតុត្រឹមត្រូវច្បាស់លាស់ដូចខាងក្រោម[៧៤] ៖

- បានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ។

  **ឧទាហរណ៍៖** បុរសជាប្តីបានលួចចិញ្ចឹមស្រីកំណាន់ចិត្ត។

- បានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ការបោះបង់ចោល គឺការមិនរួមរស់ជីវភាព ជាមួយគ្នា មិនសហការ មិនសង្គ្រោះគ្នាទៅវិញទៅមក ហើយដែលគេអាចទទួលស្គាល់ថា ភាគីមិនមាន ឆន្ទៈបន្តជីវភាពរស់នៅជាប្តីប្រពន្ធតទៀតឡើយ។

**ឧទាហរណ៍៖** ក្រោយពីបានរៀបការរួចហើយ បុរសជាប្តីបានចុះចោលលំនៅឋានទៅរស់ជាមួយនឹងឪពុក ម្តាយរបស់គាត់វិញ ដោយមិនមានមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ នារីជាប្រពន្ធអាចដាក់ពាក្យបណ្តឹងលែងលះ បាន។

- បើមិនដឹងច្បាស់ថា សហព័ទ្ធស្លាប់ រឺ រស់ អស់រយៈពេលជាង ១ ឆ្នាំ។

**ឧទាហរណ៍៖** ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចហើយ សុភាព បានចាកចេញពីប្រទេសកម្ពុជា ទៅធ្វើ ការនៅបរទេស ក៏ប៉ុន្តែចាប់តាំងពីពេលចាកចេញទៅ គឺមិនអាចទាក់ទង សុភាពបានទេ ហើយក៏ពុំមានដំណឹងពី សុភាព ថានៅរស់ ឬក៏ស្លាប់ដោយសារមូលហេតុអ្វីមួយដែរ។ ប្រសិនបើបាត់ដំណឹងនេះ លើសពី ១ឆ្នាំ ភរិយា របស់ សុភាព អាចដាក់ពាក្យបណ្តឹងលែងលះបាន។

---

[៧៣] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៩

[៧៤] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៨

- បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍-ពិពាហ៍។

**ឧទាហរណ៍៖** ក្រោយពីបានរៀបការជាមួយគ្នារយៈពេល ២ ឆ្នាំ ចិន្តា នឹង ដានី បានសម្រេចចិត្តរស់នៅបែកគ្នា ដោយសារមានការអាក់អន់ស្រពន់ចិត្តនិងគ្នាបន្តិចបន្តួច។ ប្រសិនបើអ្នកទាំងពីររស់នៅបែកគ្នាយ៉ាងដូចច្នេះលើសពី១ឆ្នាំ ភាគីម្ខាងអាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន។

- ក្នុងករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក ហើយគ្មានសង្ឃឹមថា នឹងអាចបដិទាន (សង ឬស្តារអោយដូចដើម) ឡើងវិញបាន។ នៅត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីគ្រាន់តែកំណត់លក្ខណៈទូលាយពីមូលហេតុនៃការលែងលះ ដោយទុកអោយចៅក្រមជាអ្នកវាយតម្លៃកំណត់ថា តើករណីណាខ្លះដែលអោយយើងជឿជាក់ថា អាពាហ៍ពិពាហ៍បានបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។ ក្នុងករណីបែបនេះ ចៅក្រមនឹងពិចារណាដល់ស្ថានភាពនានាដែលកើតមាន ដូចជាសកម្មភាពអាកប្បកិរិយារបស់សហព័ទ្ធ នៅក្នុងអំឡុងពេលមានចំណង់អាពាហ៍ពិពាហ៍ ឆន្ទៈរបស់ភាគីក្នុងការបន្តចំណងអាពាហ៍ពិពាហ៍ ស្ថានភាព សុខភាពភាពសេដ្ឋកិច្ចជាដើម។

**ឧទាហរណ៍៖** នៅក្នុងករណីនេះអាចមានច្រើន ដោយរួមបញ្ចូលទាំងការប្រើអំពើហិង្សានៅលើសហព័ទ្ធ ហិង្សាផ្លូវកាយ ផ្លូវចិត្ត ជាដើម ផងដែរ។

ក្នុងករណីនេះ តុលាការអាចច្រានចោលការទាមទារនៃការលែងលះ បើទោះបីជាមានមូលហេតុនៃការលែងលះ ដូចកំណត់ខាងលើក៏ដោយ ៖[៧៥]

១- ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលអោយការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូន ក្រលំបាក់យ៉ាងខ្លាំង ឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការច្រានចោលការទាមទារលែងលះគ្នាដោយពិចារណាលើស្ថានភាពទាំងឡាយបាន។

២- ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនទាមទារអោយលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ នឹងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយឆន្ទានុសិទ្ធិបាន។

**ឧទាហរណ៍** ៖ភារី នឹង ករុណា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅឆ្នាំ ២០០០ ហើយមានកូនជាមួយគ្នាចំនួន ២ នាក់។ លុះដល់ឆ្នាំ ២០០៥ ដោយសារតែការអាក់អន់ស្រពន់ចិត្តនឹងគ្នាបន្តិចបន្តួច ករុណា បានចាកចេញពីផ្ទះ។ បន្ទប់មកឆ្នាំ ២០០៦ ករុណា បានជាប់នឹងនារីម្នាក់ផ្សេង ហើយក៏បានរួមរស់ជាមួយនឹងនារីម្នាក់នោះ។ រហូតដល់ឆ្នាំ ២០១៣ នេះ ករុណា បានដាកពាក្យបណ្តឹងលែងលះពី ភារី និង ករុណា បានរស់នៅបែកគ្នាអស់រយៈពេល ៨ឆ្នាំ ក៏ពិតមែន តែតុលាការអាចច្រានចោលការទាមទារលែងលះពីសំណាក់ ករុណា បាន

[៧៥] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៨ កថាខណ្ឌទី២ និង កថាខណ្ឌទី៣

ប្រសិនបើតុលាការយល់ឃើញថា មានមូលហេតុដូចមានចែងក្នុងកថាខណ្ឌទី២ ឬកថាខណ្ឌទី ៣ នៃមាត្រា ៩៧៨ ខាងលើ ឧទាហរណ៍ ភារី មិនមានការងារធ្វើ ហើយកូនទាំងពីររបស់នាងនៅជាអនីតិជននៅឡើយ ចំណែកឯទ្រព្យសម្បត្តិទៀតសោត ក៏មិនសូវមានច្រើន ដែលមិនអាចអោយ ភារី ផ្គត់ផ្គង់ជីវភាពគ្រួសារបាន ក្រោយពេលលែងលះ។

## ៣.២. នីតិវិធីនៃការលែងលះ

### ៣.២.១. នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀងលែងលះ

ប្រសិនបើគូភាគីបានព្រមព្រៀងលែងលះគ្នា ភាគីត្រូវដាក់ពាក្យសុំទៅតុលាការរបស់ប្តី ឬប្រពន្ធ។[៧៦]

ពាក្យសុំខាងលើអាចធ្វើបានជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន។[៧៧] ដើម្បីដាក់ពាក្យសុំដោយផ្ទាល់ម៉ាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើ នៅចំពោះមុខក្រឡាបញ្ជី ហើយក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ហើយកំណត់ហេតុនេះត្រូវចាត់ទុកថាជាពាក្យសុំ។ លិខិតពាក្រសុំត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

-ឈ្មោះ និងអាសយដ្ឋានរបស់អ្នកពាក្យសុំ និងឈ្មោះអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

នៅក្នុងការដាក់ពាក្យសុំនេះ អ្នកដាក់ពាក្យសុំត្រូវបង់ប្រាក់ពន្ធនៃការដាក់ពាក្យសុំចំនួន**៥,០០០ ប្រាំពាន់រៀល**។[៧៨]

### ៣.៣.២. នីតិវិធីនៃការលែងលះក្នុងករណីមានពាក្យបណ្តឹងសុំលែងលះ

#### ក. តុលាការមានសមត្ថកិច្ច

ចំពោះបណ្តឹងលែងលះគ្នា និងបណ្តឹងអោយបញ្ជាក់ពីអត្ថិភាព(ភាពមាន) ឬនត្ថិភាព(ភាពគ្មាន) នៃបុគ្គភាព ត្រូវស្ថិតនៅក្រោមសម្ថតកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសម្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ(...)។[៧៩]

ហេតុនេះ តុលាការមានសម្ថកិច្ចក្នុងរឿងក្តីលែងលះអាចជាតុលាការខាងលំនៅឋានរបស់ដើមចោទក៏បាន ឬជាតុលាការខាងលំនៅឋានរបស់ចុងចំលើយក៏បាន។

**ឧទាហរណ៍** ៖ បុរស ក និង នារី ខ ជាប្តីប្រពន្ធនឹងគ្នា។ អ្នកទាំងពីរមានលំនៅឋានក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នារយៈពេល ២ ឆ្នាំកន្លងផុតទៅ បុរស ក បានចុះចេញពីផ្ទះទៅរស់នៅជាមួយនឹងឪពុកម្តាយរបស់គាត់នៅឯខេត្តពោធិ៍សាត់ទៅវិញ ក្រោយពីមានទំនាស់ជាមួយប្រពន្ធ។ ឧបមាថា

[៧៦] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧០១/០១៣, ១០ កក្កដា ២០១០ មាត្រា៤ កថាខណ្ឌទី១

[៧៧] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧០១/០១៣, ១០ កក្កដា ២០១០ មាត្រា២៦ កថាខណ្ឌទី១

[៧៨] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧០១/០១៣, ១០ កក្កដា ២០១០ មាត្រា២២ កថាខណ្ឌទី១

[៧៩] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា១០ កថាខណ្ឌទី១

នារី ខ មានបំណងចង់ប្តឹងលែងលះ ដូច្នេះ នារី ខ អាចដាក់ពាក្យបណ្តឹងលែងលះនៅសាលាដំបូងរាជធានីភ្នំពេញក៏បាន ឬនៅសាលាដំបូងខេត្តពោធិ៍សាត់ក៏បាន។

**ខ. បណ្តឹងលែងលះ**

ពាក្យបណ្តឹងលែងលះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវសរសេរនៅចំណុចដូចខាងក្រោម ៖

- ឈ្មោះ និង អាសយដ្ឋាន របស់ភាគី និងឈ្មោះ អាស័យដ្ឋាន របស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារ នៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ និងអង្គហេតុ ចាំបាច់ដើម្បីបញ្ជាក់ការទាមទារ។[៩០]

សម្រាប់ការដាក់ពាក្យបណ្តឹងខាងលើនេះ ដើមចោទត្រូវបង់ពន្ធដាក់ពាក្យបណ្តឹងចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។

**គ. ការផ្សះផ្សា**

តុលាការអាចសាកល្បងធ្វើការផ្សះផ្សារ ទោះបីជាបណ្តឹងស្ថិតក្នុងក្នុងដំណាក់កាលណាក៏ដោយ ទោះបីជាគូភាគីទាមទារយ៉ាងលែងលះយ៉ាងខ្លាំងក៏ដោយ។[៩១]

**ឃ. នីតិវិធីត្រៀមសម្រាប់ធ្វើការទាញហេតុផលផ្ទាល់ម៉ាត់**

ក្នុងដំណាក់កាលសម្រាប់ត្រៀមការទាញហេតុផ្ទាល់មាត់ តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគីបំភ្លឺនៅចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និងរៀបចំនៅភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះដើម្បីអាចធ្វើជាការវិនិច្ឆ័យរឿងក្តី នៅក្នុងនីតីវិធីនៃការទាញហេតុផលផ្ទាល់ម៉ាត់ឱ្យបានយ៉ាងល្អិតល្អន់។[៩២]

ជាគោលការណ៍ គូភាគីជាអ្នកស្នើសុំទៅតុលាការពិនិត្យភស្តុតាង និយាយម្យ៉ាងវិញទៀតថា គូភាគីជាអ្នកស្វះស្វែងរកភស្តុតាងផ្សេងៗមកដាក់ជូនតុលាការពិនិត្យដើម្បីជាផលប្រយោជន៍របស់ខ្លួន។ ស្របគ្នាដែរ តុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ហើយជាពិសេសតុលាការអាចធ្វើការយកអង្គហេតុដែលមិនបានអះអាងដោយគូភាគី មកធ្វើជាមូលដ្ឋាននៃសាលក្រមបាន។[៩៣]

**ង. សេចក្តីសម្រេចក្នុងរឿងលែងលះ**

ក្រោយពីធ្វើការវិនិច្ឆ័យរួចហើយ តុលាការនឹងធ្វើការសម្រេចសេចក្តីដោយចេញជា **សាលក្រម**។

តាមធម្មតា សាលក្រមដែលសម្រេចអំពីការលែងលះត្រូវបញ្ជូនទៅអោយគីភាគី ក្នុងអំឡុងពេល ២ សប្តាហ៍គិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម។[៩៤] គូភាគីអាចប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះបានក្នុងអំឡុងពេល ០១ខែគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម។[៩៥]

---

[៩០] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា៧៥ កថាខណ្ឌទី២
[៩១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨៤ កថាខណ្ឌទី១
[៩២] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា១០៣
[៩៣] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៦ មិថុនា ២០១០ មាត្រា១៤
[៩៤] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា១៩០ កថាខណ្ឌទី១
[៩៥] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា២៦៤ កថាខណ្ឌទី១

ម៉្យាងទៀតតុលាការមិនអាចចេញ សាលក្រមកំបាំងមុខបានឡើយ ពោលគឺសាលក្រមដែលចេញដោយតុលាការ គឺជាសាលក្រមធម្មតា ដែលមិនអាចអនុញ្ញាតអោយមានការបណ្តឹងទាស់បានទេ។[៨៦]

### ៣.៣. អនុភាពនៃការលែងលះ

ការលែងលះមានអនុភាពផ្តាច់ចំណងអាពាហ៍ពិពាហ៍ រវាងសហព័ទ្ធនៅពេលដែលសេចក្តីសម្រេចអំពីការលែងលះបានចូលជាស្ថាពរ។ សេចក្តីអំពីការលែងលះនឹងចូលជាស្ថាពរ នៅពេលដែលអំឡុងពេលនៃបណ្តឹងឧបាស្រ័យបានកន្លងផុត។ បើសេចក្តីសម្រេចនេះជាសាលក្រម អំឡុងពេលប្តឹង ឧទ្ធរណ៍ គឺ០១ខែ គិតចាប់ពីថ្ងៃដែលបានទទួលលិខិតសាលក្រម។ នៅក្នុងករណីដែលសេចក្តីសម្រេចនេះជា ដីការសម្រេច គឺត្រូវប្តឹងជំទាស់ក្នុងអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីដីកាសម្រេចនេះ។[៨៧] ដូច្នេះ នៅពេលដែលផុតអំឡុងពេលដូចបានបញ្ជាក់ជូនខាងលើនេះ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរ។

#### ៣.៣.១. អនុភាពនៃការលែងលះ ចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ

ការលែងលះនាំអោយសហព័ទ្ធរួចផុតពីកាតព្វកិច្ចទាំងឡាយ ដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារអនុញ្ញាតអោយសហព័ទ្ធម្ខាង ទាមទារអាហារកិច្ចពីសហព័ទ្ធម្ខាងទៀតបានកាលបើមានលក្ខខណ្ឌសមស្របដូចខាងក្រោម[៨៨] ៖

- អតីតសហព័ទ្ធ ដែលអ្នកស្នើសុំនោះគ្មានកំហុសក្នុងការលែងលះគ្នា។
- អតីតសហព័ទ្ធមានការខ្វះខាត បានសេចក្តីថា ភាគីគ្មានកំហុសពុំមានទ្រព្យសម្បត្តិ ឬ មុខរបរជាក់លាក់សម្រាប់ចិញ្ចឹមជីវិតខ្លួន។ គួរកត់សម្គាល់ថា ការខ្វះខាតនេះ មិនសំដៅតែទៅលើការខ្វះខាតម្ហូបអាហារសម្រាប់បរិភោគប៉ុណ្ណោះទេ គឺសំដៅទៅលើអ្វីដែលជាធាតុចាំបាច់ សម្រាប់អោយជនដែលមានសិទ្ធិទទួលអាហារកិច្ច អាចរស់នៅដោយសមស្រប ដូចជាអាចមានជម្រក សម្លៀកបំពាក់ លទ្ធភាពទិញថ្នាំសង្កូវ ជាដើម។

ជាធម្មតា អតីតសហព័ទ្ធដែលត្រូវផ្តល់អាហារកិច្ច ត្រូវមានលទ្ធភាពផ្តល់អាហារកិច្ចនោះ។ ក្នុងករណីនេះចៅក្រមពិនិត្យទៅលើប្រាក់បៀវត្ស លទ្ធភាពនៃការរកប្រាក់ចំណូល អាយុ សុខភាពរបស់ជននោះដើម្បីកំណត់ពីអាហារកិច្ចដែលត្រូវបង់។ ក៏ប៉ុន្តែប្រសិនបើជនដែលត្រូវទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត ជននោះលែងមានសិទ្ធិទទួលអាហារកិច្ចនោះទៀតហើយ។

ចំណែក ប្តី ឬ ប្រពន្ធដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនរៀបអាពាហ៍ពិពាហ៍បាន ឬអាចប្រើនាមត្រកូលដែលបាននៅពេលលែងលះគ្នាក៏បាន។[៨៩]

---

[៨៦] សាស្ត្រាចារ្យ ចាំង ស៊ីណាត "នីតិគ្រួសារ" ឆ្នាំ២០១៣ ទំព័រទី១៧១

[៨៧] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដេលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៤០ កថាខណ្ឌទី១

[៨៨] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩ មាត្រា៧៦ និង មាត្រា៧៧

[៨៩] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨១

**ឧទាហរណ៍៖** ព្រំ បញ្ញា បានរៀបការជាមួយនឹងនារីម្នាក់ឈ្មោះ ផាន់ បូផា។ក្នុងករណីនេះ ផាន់ បូផា អាច ប្រើនាមត្រកូលរបស់ប្ដីនាងបាន ដោយប្ដូរទៅជា ព្រំ បូផា ដដែលកបាន ឬ ប្ដូរទៅប្រើឈ្មោះ ផាន់ បូផា វិញក៏ បាន។

**៣.៣.២. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ**

ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ ត្រូវធ្វើទៅតាមគោលការណ៍យល់ព្រមរបស់គូភាគី ទាំងសងខាង។ ផ្ទុយទៅវិញបើពុំអាចពិភាក្សាគ្នាបានទេ គឺត្រូវតែធ្វើការបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយផ្អែកទៅតាមចំណុចនីមួយៗ ដូចខាងក្រោម[៩០] ៖

- សហព័ទ្ធម្នាក់ៗត្រូវទទួលបាននៅទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។
- បន្ថែមពីលើទ្រព្យដោយឡែកសហព័ទ្ធម្នាក់ៗត្រូវទទួលបាន នៅ ១ ភាគ ២ នៃទ្រព្យរួម។

**ឧទាហរណ៍៖** ចិន្តា និង សុភាព បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅ ឆ្នាំ ២០០៥។ មុនពេលរៀប អាពាហ៍ពិពាហ៍ ចិន្តាបានទិញរថយន្តមួយគ្រឿង សម្រាប់ប្រកបរតាក់ស៊ី។ ក្រោយរៀអាពាហ៍ពិពាហ៍ចិន្តា នៅតែប្រើប្រាស់រថយន្តនោះដដែល បើម្បីបម្រើជីវភាពគ្រួសារ ដោយទទួលបាននៅចំណូលគួសម ចំណែកឯសុភាព ជាប្រពន្ធវិញ ជាអ្នកធ្វើកិច្ចការផ្ទះ និងមើលថែទាំកូន។ តាមរយៈប្រាក់ចំណូលនេះ ចិន្តា បានទិញដីមួយកន្លែងនៅឆ្នាំ ២០០៨។ នៅឆ្នាំ ២០១៣ នេះ ចិន្តា និង សុភាព បានលែងលះគ្នា។ ដូច្នេះ ចិន្តា មានសិទ្ធិយកម៉ូតូដែលជាទ្រព្យសម្បត្តិដោយឡែករបស់គាត់បាន ចំណែកឯដីភូមិវិញ ដែលជាទ្រព្យរួម គឺត្រូវបែងចែកស្មើគ្នារវាង ចិន្តា និង សុភាព។

ក៏ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទារ របស់ប្ដី ឬ ប្រពន្ធណាមួយ តុលាការក៏អាចធ្វើការបែងចែកទ្រព្យសម្បត្តិរួម ដោយធ្វើការពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ៖ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សារ ឬកាបង្កើនទ្រព្យ អំឡុងពេលរៀបអាពាហ៍ពិពាហ៍ កម្រិតជីភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍ ។[៩១]

**ឧទាហរណ៍៖** កញ្ញា សារឿន គឺ ជាប្ដីប្រពន្ធនឹងគ្នា ហើយបានសម្រេចចិត្តលែងលះពីគ្នា នៅឆ្នាំ ២០១៣ នេះ។ នៅក្នុងចំណងរៀបអាពាហ៍ពិពាហ៍ទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរ មាន ៖ ម៉ូតូ មួយគ្រឿង (តម្លៃប្រហែល ៣លានរៀល) ដែល សារឿន យកទៅប្រប្រាស់ដើម្បីរត់ម៉ូតូឌុប មានគោមួយក្បាលតម្លៃ ២លានរៀល) និង ប្រាក់ចំនួន ៣លានរៀល។ អ្នកទាំងពីរមានកូនពីរនាក់ជាអនតិជន។ ឧបមាថា អ្នកទាំងពីរបានព្រងព្រៀងគ្នាថា ឱ្យ កញ្ញា ជាម្ដាយជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ ក្រោយពេលលែងលះ។ នៅក្នុងករណីនេះដោយគិតអំពីផលប្រយោជន៍របស់កូន តុលាការអាចប្រគល់ម៉ូតូតម្លៃប្រហែល ៣លានរៀល ឱ្យ ទៅសារឿន និងគោមួយក្បាលតម្លៃ ២លានរៀលនិងប្រាក់៣ លានរៀលឱ្យ ទៅ កញ្ញា ជាប្រពន្ធ។ ក្នុងសម្ថកម្មនេះ ឃើញថា ទ្រព្យសម្បត្តិរួមរបស់ប្ដី

[៩០] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨០ កថាខណ្ឌទី១ និងកថាខណ្ឌទី២

[៩១] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨០ កថាខណ្ឌទី២ ចំណុចខ

ប្រពន្ធត្រូវបានបែងចែកទៅអោយកញ្ញាជាប្រពន្ធច្រើជាង សារឿន ដោយខុសពីគោលការណ៍ដែលចែងថា ទ្រព្យសម្បត្តិរួមត្រូវបានបែងចែកពាក់កណ្ដាលម្នាក់រវាងសហព័ទ្ធ។ជាក់ស្ដែង ក្រមរដ្ឋប្បវេណីអនុញ្ញាតអោយធ្វើការបែងចែកបែបនេះដើម្បីជាផលប្រយោជន៍របស់កូន។

សូមធ្វើការកត់សម្គាល់ថា ការលែងលះអាចមកពីមូលហេតុបណ្ដាលមកពីការប្រើអំពើហិង្សាផ្សេងៗ។ តាមច្បាប់ ការប្រើអំពើហិង្សារវាងប្ដីប្រពន្ធគឺជាអំពើអនីត្យានុកូល ដែលឈានទៅដល់ការសម្រេចអំពីសំណងនៃការខូចខាតផងដែរ។ ក្នុងអត្ថន័យនេះ ការទាមទារលែងលះ និងការទាមទារសំណងនៃការខូចខាតដូចខាងលើនេះ អាចធ្វើក្នុងបណ្ដឹងតែមួយបាន។[៩២]

ផ្សេងពីនេះទៀត តុលាការក៏អាចសម្រេចអោយសហព័ទ្ធណាម្នាក់សងតម្លៃនៃទ្រព្យសម្បត្តិដោយឡែកដែលភាគីម្ខាងទៀតបានបំផ្លាញក្នុងអំឡុងពេលមានចំណងរៀបអាពាហ៍ពិពាហ៍បានដែរ។

**ឧទាហរណ៍៖** ឈ្មោះ ក និង ឈ្មោះ ខ ជាប្ដី ប្រពន្ធនិងគ្នា។ឈ្មោះ ក បានយកខ្សែដៃមាស របស់ ឈ្មោះ ខ ជាប្រពន្ធ (ខ្សែដៃដែលម្ដាយរបស់ឈ្មោះ ខ បានផ្ដល់ជាអំណោយឱ្យ ខ) ទៅលក់ដើម្បីយកប្រាក់ទៅលេងល្បែងដោយមិនអោយមិនអោយ ឈ្មោះ ខ ដឹងឡើយ។ នៅពេលលែងលះ តុលាការអាចសម្រេចអោយឈ្មោះ ក សងតម្លៃនៃខ្សែដៃ ឱ្យ ខវិញ ព្រោះថាខ្សែដៃនោះជាទ្រព្យដោយឡែករបស់ឈ្មោះ ខ។

### ៣.៣.៣. អនុភាពនៃការលែងលះចំពោះកូន

នៅក្នុងករណីមានការលែងលះ តុលាការត្រូវតែកំណត់ពីអ្នកមានអំណាចមេបា ដោយឆន្ទានុសិទ្ធិ ពោលគឺទោះបីជាមិនមានពាក្យសុំពីភាគីក៏ដោយ។[៩៣]

ជាគោលការណ៍ ការកំណត់ត្រូយតែធ្វើឡើងតាមការពិភាក្សារបស់សហព័ទ្ធ។ ប៉ុន្តែប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាទៅលើផលប្រយោជន៍ របស់កូន។[៩៤]

**ឧទាហរណ៍៖** ឈ្មោះ ក បានប្ដឹងលែងលះពីឈ្មោះ ខ។ អ្នកទាំងពីមានកូនម្នាក់ដែលមានអាយុ ៨ឆ្នាំប៉ុណ្ណោះ។ អ្នកទាំងពីរទាមទារសិទ្ធិគ្រប់គ្រង ចិញ្ចឹមកូនរៀងៗខ្លួន។ ឈ្មោះ ក មានមុខរបរជាកសិករ ចំណែកឯឈ្មោះខ ជាប្រពន្ធពុំមានប្រាក់ចំណូលអ្វីទេ។ ក៏ប៉ុន្តែ ឈ្មោះ ក ចូលចិត្តផឹកស្រា ស្រែកឡូឡា ជេរគេ ជេរឯង។ ក្នុងករណីនេះ ទោះបីជាឈ្មោះ ក មានមុខរបរ មានប្រាក់ ចំណូល កដោយ ចរិតលក្ខណះរបស់ឈ្មោះ ក ដែលចូលចិត្តផឹកស្រា ស្រែកឡូឡា ជេរគេ ជេរឯង អាចធ្វើអោយមានផលអវិជ្ជមានយ៉ាងខ្លាំង ដល់កូនដែករស់នៅជាមួយ។ ហេតុដូច្នេះ តុលាការអាចប្រគល់អំណាចមេបាលើកូនទៅឱ្យ ឈ្មោះ ខ វិញ។

ម៉្យាងវិញទៀត ប្រសិនបើមានការលែងលះ នៅពេលដែលកូនកើត ម្ដាយគឺជាអ្នកមានអំណាច។ ប៉ុន្តែក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាលើកូនបាន តាមរយៈការពិភាក្សារវាង

[៩២] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា១១

[៩៣] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២

[៩៤] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៧ កថាខណ្ឌទី១ និង កថាខណ្ឌទី៣

ឪពុកម្ដាយ។[៩៥] ផ្ទុយទៅវិញ ប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ តុលាការជាអ្នកសម្រេច នៅពេលដែលមានពាក្យសុំរបស់ឪពុកដោយផ្អែកតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដី រដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

ចំពោះភាគីដែលមិនមានអំណាចមេបាលើកូន គាត់មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។[៩៦] ជាគោលការណ៍ ការកំណត់ពីបញ្ហានេះត្រូវធ្វើឡើងដោយផ្អែកតាមការសិក្សារបស់ឪពុកម្ដាយ ហើយនៅក្នុងករណីដែលមិនអាចពិភាក្សាគ្នាបានទេ តុលាការជាអ្នកកំណត់ តាមការទាមទាររបស់ឪពុក ឬម្ដាយណាម្ខាង។ ពាក់ព័ន្ធនឹងការសម្រេចសេចក្ដីពីការចូលជួប និងប្រាស្រ័យទាក់ទង ក្រមរដ្ឋប្បវេណីតម្រូវអោយតុលាការអាចពិចារណាទៅលើផលប្រយោជន៍កូនជាអាទិភាព។ ក្នុងន័យនេះ តុលាការអាចពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជាទាក់ទងរវាងកូន និងឪពុកម្ដាយនៅពេលរស់នៅជាមួយគ្នា អាយុ ស្ថានភាពសុខភាពរបស់កូន បំណងរបស់កូន បំណងភាគីសងខាង ព្រមទាំងស្ថានភាពផ្លូវចិត្តរបស់ភាគីសងខាងជាដើម។ សម្រាប់សោហ៊ុយចាំបាច់ ដើម្បីសគ្រប់គ្រងថែរក្សាកូន ក្រមរដ្ឋប្បវេណីបានតម្រូវអោយតុលាការពិចារណាទៅលើស្ថានភាពនៃជីវភាពនិងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយទាំងសងខាង។ ជាទូទៅ ការតម្រូវអោយភាគីម្ខាងបង់សោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន គឺធ្វើឡើងដោយកំណត់ទៅតាមខែនីមួយៗ ហើយតុលាការនឹងសម្រេចថា ត្រូវបង់សោហ៊ុយនេះចាប់ពីពេលណា រហូតដល់ពេលណាជាកំណត់ជាក់លាក់។

**ឧទាហរណ៍៖** សំភី និង រស្មី បានលែងលះគ្នា។ តុលាការបានសម្រេចប្រគល់កូន ឈ្មោះ ដារ៉ា ដែលមានអាយុទើបតែ ៥ ឆ្នាំ ទៅអោយ រស្មី ជាម្ដាយមានអំណាចមេបាលើ ដារ៉ា។ ចំណែកឯ សំភី ជាឪពុកដែលពុំមានអំណាចមេបាលើ ដារ៉ា ទេ។ ទន្ទឹមនឹងនេះ តុលាការបានសម្រេចអោយ សំភី ចូលជួបប្រាស្រ័យទាក់ទងជាមួយនឹង ដារ៉ា ម្ដងក្នុង១សប្ដាហ៍ ដោយកំណត់ដោយយកថ្ងៃអាទិត្យចាប់ពីម៉ោង ១៤៖០០ រហូតដល់ម៉ោង ១៧: ០០ នៅលំនៅឋានរបស់ រស្មី។ ត្រង់ចំណុចនេះគឺជាសិទ្ធិចូលជួប និងប្រាស្រ័យទាកទងរបស់ សំភី។ ក្រៅពីនេះ តុលាការបានសម្រេចអោយ សំភី បង់ប្រាក់ដើម្បីអោយអោយ រស្មី ចិញ្ចឹមបីបាច់ថែរក្សា ដារ៉ា ចំនួន ១លានរៀលក្នុងមួយខែដោយគិតចាប់ពីពេលសេចក្ដីសម្រេចលែងលះចូលជាស្ថាពរ រហូតដល់កូនមាននីតិភាព។ នេះគឺជាសេចក្ដីសម្រេចអំពីសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន ឬក៏ពេលខ្លះគេប្រើពាក្យថា អាហារកាតព្វកិច្ច។

ទាក់ទងនឹងការសម្រេចសេចក្ដីពីការកំណត់អ្នកមានអំណាចមេបា ឬការចាត់ចែងទាក់ទងនឹងបីបាច់រក្សាកូនដូចបានរៀបរាប់ខាងលើនេះ តុលាការត្រូវពិចារណាថ្លឹងថ្លែងទៅលើយោបល់របស់កូន សមស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូននោះ។[៩៧]

---

[៩៥] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៧ កថាខណ្ឌទី២

[៩៦] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៤០ កថាខណ្ឌទី១

[៩៧] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ កថាខណ្ឌទី៤

ទោះបីជាតុលាការបានសម្រេចសេចក្តីពីការកំណត់អ្នកមានអំណាចមេបា ការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ព្រមទាំងសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូនរួចហើយក៏ដោយ ក៏សេចក្តីសម្រេចទាំងនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរបានដែរ។[៥៨]

**ឧទាហរណ៍៖** លក្ខិណា បានលែងលះគ្នាពី សារ៉ាយ ហើយនាងត្រូវបានតុលាការសម្រេចប្រគល់អំណាចមេបា លើកូនម្នាក់ដែលជាអនីតិជន។ មូលហេតុនៃការសម្រេចយ៉ាងដូចច្នេះ គឺមកពី សារ៉ាយ តែងតែផឹកស្រាស្រវឹងជាប្រចាំ។ ឧបមាថា សារ៉ាយ បានកែប្រែខ្លួន ដោយឈប់ផឹកស្រាបង្ករឿងរ៉ាវដល់អ្នកដ៏ទៃទៀតហើយ ចំណែកឯ លក្ខិណា មានការខ្វះខាតយ៉ាងខ្លាំងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនហើយពេលខ្លះ លក្ខិណា បានអោយកូនសុំទានយកប្រាក់មកផ្គត់ផ្គង់ជីវភាពទៀតផង។ ក្នុងស្ថានភាពបែបនេះ បើសិនជា សារ៉ាយ ស្នើសុំឱ្យតុលាការផ្លាស់ប្តូរអំណាចមេបាលើកូន ពោលគឺ ទាមទារអោយ លក្ខិណា ប្រគល់កូនអោយ សារ៉ាយ មានឱកាសច្រើននឹងទទួលបានអំណាចមេបាលើកូនវិញ។

ដូចគ្នាដែរ ក្នុងសម្មតិកម្មខាងលើ ដែលតុលាការសម្រេចអោយ សំភី ជាឪពុកបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ១លានរៀល ក្នុងមួយខែ ក៏ប៉ុន្តែក្រោយមក សំភី បានបាត់បង់ការងារដែលមិនអាចរកចំណូលបានច្រើនដូចពីមុន។ ក្នុងករណីបែបនេះ សំភី អាចសុំដាក់ពាក្យទៅតុលាការអោយបន្ថយចំនួនសោហ៊ុយនេះបាន (ឧទាហរណ៍ ដូចជាសម្រេចអោយបន្ថយសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន មកត្រឹមតែ ៤សែនរៀល ក្នុងមួយខែវិញ)។

លើសពីនេះទៅទៀត ប្រសិនភាគីដែលមានករណីកិច្ចត្រូវបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ឬអាហារកិច្ច តាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការ ហើយបែជាមិនព្រមគោរពតាមសេចក្តីសម្រេចនេះ នឹងនាំអោយមានទណ្ឌកម្មពីរប្រភេទគឺ៖

- **ទណ្ឌកម្មរដ្ឋប្បវេណី៖** ម្ចាស់បំណុល (ជនដែលមានសិទ្ធិទាមទារ អាហារកិច្ច) អាចដាក់ពាក្យសុំដើម្បីអោយមានការ អនុវត្តករណីកិច្ចរបស់ខ្លួនតាមក្រមនីតិវិធីរដ្ឋប្បវេណី ដូចជា ការរឹបអូសទ្រព្យសម្បត្តិជាដើម។
- **ទណ្ឌកម្មព្រហ្មទណ្ឌ៖** ការមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ដោយមិនព្រមបង់ក្នុងរយៈពេល ២ខែ យ៉ាងតិចនូវអាហារកាតព្វកិច្ចដល់សហព័ទ្ធ ឬអតីតសហព័ទ្ធរបស់ខ្លួនដល់កូនជាអនីតិជន ដល់បច្ចាញាតិ ឬបុព្វញាតិផ្សេងទៀតរបស់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី ១ សែនរៀល ទៅ ២ លានរៀល (មាត្រា ៣២៤ នៃក្រមព្រហ្មទណ្ឌ) សរុបសេចក្តីមក អំពើនេះត្រូវបានចាត់ទុកថាជាបទល្មើសដែលមានឈ្មោះថា **បទបោះបង់គ្រួសារ។**

---
[៥៨] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៩ និង មាត្រា១០៤០ កថាខណ្ឌទី៥

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទ “ អាពាហ៍ពិពាហ៍ និង ការលែងលះ ” រួចមក ក្រុមរបស់យើងខ្ញុំយល់ឃើញថា ចំណងអាពាហ៍ពិពាហ៍មួយអាចកើតឡើងបានលុះត្រាតែភាគីទាំងសងខាង គោរពទៅតាមនីតិវិធីដែលច្បាប់បានចែង ក៏ដូចជាលក្ខខណ្ឌនានាដែលច្បាប់តម្រូវឱ្យភាគីនីមួយៗអនុវត្តតាម។ ជាងនេះទៅទៀត ពួកគាត់ត្រូវតែចុះសំបុត្រអាពាហ៍ពិពាហ៍ជាដាច់ខាង បើពុំនោះទេអាពាហ៍ពិពាហ៍របស់ពួកគាត់ ពុំមានចំណងគតិយុត្តអ្វីឡើយ។

ផ្ទុយទៅវិញ ប្រសិនបើចំណងអាពាហ៍ពិពាហ៍ដែលស្របច្បាប់របស់ពួកគាត់មានភាពរង្គោះរង្គើ ឬ ជួប ប្រទះនូវបញ្ហាមួយចំនួនដែលនាំឱ្យឈានដល់ដំណាក់កាលដែលមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ទោះបី ជាពួកគាត់ធ្លាប់ទទួលបាននូវការផ្សះផ្សា ដែលពេលខ្លះការផ្សះផ្សានោះទទួលបានជោគជ័យ ហើយបញ្ហាមួយ ចំនួនមិនអាចធ្វើការផ្សះផ្សាបាន ដែលមូលហេតុទាំងនេះហើយដែលធ្វើឱ្យចំណងអាពាហ៍ពិពាហ៍របស់ពួកគាត់ ឈានទៅដល់ការលែងលះ។

ក្នុងករណីដែលពួកគាត់ចង់លែងលះគ្នា សហព័ទ្ធទាំងពីរត្រូវតែដាក់ពាក្យសុំលែងលះទៅតុលាការ និង ត្រូវឆ្លងកាត់នូវនីតិវិធីតាមផ្លូវតុលាការជាច្រើនដំណាក់កាលទៀត ទើបពួកគាត់អាចធ្វើការលែងលះគ្នាបាន។ ដោយយោងទៅតាមបញ្ញត្តិមាត្រាដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានការពារនូវផលប្រយោជន៍របស់សហព័ទ្ធទាំងសងខាង បន្ទាប់ពីពួកគាត់បានលែងលះគ្នាហើយនោះ មិនថា ជា ភាគីប្តី ឬ ប្រពន្ធ ព្រមទាំងកូនផងដែរ ត្រូវទទួលបាននូវការការពារពីច្បាប់។ នៅពេលដែលការលែងលះមាន អានុភាពហើយ នោះសហព័ទ្ធទាំងពីរត្រូវតែធ្វើការព្រមព្រៀងគ្នានូវការបែងចែកទ្រព្យសម្បត្តិ ការផ្តល់នូវអាហារ កាតព្វកិច្ចដល់កូន និង ដល់អតីតសហព័ទ្ធណាមួយដែលមានការខ្វះខាតក្រោយការលែងលះ ការប្រគល់ អំណាចមេបាដោយអោយកូនទៅរស់នៅជាមួយសហព័ទ្ធណាមួយ និង សហព័ទ្ធដែលមានអំណាចមេបាត្រូវផ្តល់ ឱកាសឱ្យសហព័ទ្ធដែលមិនមានអំណាចមេបាបានជួបប្រាស្រ័យទាក់ទងជាមួយកូនផងដែរ។

សរុបសេចក្តីមក បុគ្គលគ្រប់រូបមុននឹងសម្រេចចិត្តចាប់ដៃគ្នាបង្កើតនូវចំណងអាពាហ៍ពិពាហ៍ដើម្បីបង្កើត ជាក្រុមគ្រួសារមួយនៅក្នុងសង្គម ត្រូវតែធ្វើការត្រិះរិះពិចារណាឱ្យបានម៉ត់ចត់ គ្រប់ជ្រុងដោយថាខ្លួនអាចមាន សមត្ថភាពគ្រប់គ្រាន់ក្នុងការដើរតួជាស្វាមី ជាភរិយា ជាឪពុក ជាម្តាយ ដ៏ល្អបានហើយឬនៅ។ ម៉្យាងវិញទៀត ដើម្បីជៀសវាងនូវការបែកបាក់ក្រុមគ្រួសាររបស់សហព័ទ្ធដែលការបែកបាក់នោះធ្វើឱ្យបាត់បង់នូវផលប្រយោជន៍ របស់សហព័ទ្ធ ជាពិសេសនោះ ចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរនឹងពុំមានសេចក្តីសុខឡើយ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសរសេរ និង រៀបចំនូវសារណាបញ្ចប់ការសិក្សានេះរួចមកឃើញថា ប្រជាជនមួយចំនួនមិនមានការយល់ដឹងអំពី អាពាហ៍ពិពាហ៍ និងការលែងលះនៅឡើយ ដោយពួកគាត់ពុំបានទទួលនូវការផ្សព្វផ្សាយអំពីឯកសារច្បាប់ដែលពាក់ព័ន្ធ ដើម្បីធ្វើការរៀបអាពាហ៍ពិពាហ៍ និងការលែងលះគ្នាជាដើម។ ជាពិសេសប្រជាជនដែលរស់នៅតំបន់ជនបទដាច់ស្រយាល ពុំបានយល់ដឹងអំពីនីតិវិធីដែលនាំឱ្យមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ ដោយពួកគាត់អនុវត្តតាមទំនៀមទម្លាប់ប្រពៃណីដែលមានតាំងពីដូនតាមកម្លេះ ដោយពួកគាត់គ្រាន់តែរៀបចំប្រារព្ធនូវអាពាហ៍ពិពាហ៍ ដើម្បីជាការបង្ហាញថា កូនកំលោះ កូនក្រមុំ ជាស្វាមីភរិយានឹងគ្នាហើយ ដោយពុំបានបំពេញទៅតាមផ្លូវច្បាប់ដូចជាគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍អ្វីឡើយ។ មួយវិញទៀត នៅពេលដែលវិវាទកើតឡើងរវាងប្ដី និង ប្រពន្ធ មិនដឹងថា តើត្រូវទៅប្ដឹងទៅសមត្ថកិច្ចណាមួយឱ្យជួយដោះស្រាយ ដើម្បីទទួលបាននូវអានុភាពនៅក្រោយពេលលែងលះ។

ដោយកង្វះខាតមួយចំនួននេះហើយ ទើបក្រុមរបស់យើងខ្ញុំ សូមចូលរួមនូវការផ្ដល់ជាមតិយោបល់មួយចំនួនក្នុងគោលដៅដើម្បីធ្វើការកែតម្រូវនូវចំណុចទាំងនោះដូចជា៖

- រដ្ឋាភិបាល ត្រូវផ្ដល់ការផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យប្រជាជនបានយល់ច្បាស់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ និង នីតិវិធីនៃការលែងលះ ដើម្បីជាភាពងាយស្រួលដល់ពួកគាត់ ហើយក៏ជាភាពងាយស្រួលដល់ពួកគាត់ ហើយក៏ជាចំណេះដឹងបន្ថែមទៀតសម្រាប់ពួកគាត់ប្រើប្រាស់នៅពេលណាដែលគាត់ជួបប្រទះបញ្ហាទាំងនោះ ហើយក៏ជាវិធីមួយដើម្បីជួយកាត់បន្ថយនូវការលែងលះគ្នាផងដែរ។
- សហព័ទ្ធទាំងពីរ ត្រូវតែស្មោះស្ម័គ្រមួយនឹងមួយ ដោយពុំមានចិត្តវៀចវេរ ដើម្បីរក្សានូវចំណងអាពាហ៍ពិពាហ៍កុំឱ្យឈានដល់ការលែងលះ ដែលជាមូលហេតុធ្វើឱ្យគ្រួសារដែលធ្លាប់តែមានសុភមង្គល ប្រែទៅជាគ្រួសារដែលបែកបាក់ទៅវិញ។
- រាល់កំហុសតិចតួចដែលសហព័ទ្ធណាម្ខាងបានប្រព្រឹត្ត ត្រូវតែចេះអត់អោនអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក ដើម្បីបញ្ចៀសនូវការបែកបាក់។

# ឯកសារយោង

# ឯកសារយោង

## សៀវភៅច្បាប់

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩
- ច្បាប់ ស្តីពីឯកពន្ធភាព នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- ច្បាប់ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១
- ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០
- ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០

## ឯកសារផ្សេងៗ

- សៀវភៅស្តីពី "នីតិគ្រួសារ" ដោយលោកស្រី ចាំង ស៊ីណាត។
- កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន របស់ក្រសួងមហាផ្ទៃ ដោយនាយកដ្ឋានអត្រានុកូលដ្ឋាន

## អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, លេខ ១៨៣ អនក្រ.បក, ០៣ វិច្ឆិកា ២០០៨
- អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០។

## គេហទំព័រ

- https://vannarachin.wordpress.com
- https://www.postkhmer.com/

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

១ **ឧបសម្ព័ន្ធទី១** : នីតិវិធីនៃការដាក់ពាក្យអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

- ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍
- ពាក្យសុំបញ្ជាក់ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ
- លិខិតបញ្ជាក់ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ
- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍
- បញ្ជីអាពាហ៍ពិពាហ៍
- បញ្ជីអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សំបុត្រអាពាហ៍ពិពាហ៍
- សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

២ **ឧបសម្ព័ន្ធទី២** : នីតិវិធីនៃការដាក់ពាក្យលែងលះនៃអាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀង

- ដីកាកោះចុងចម្លើយ
- ដីកាកោះដើមចោទ
- កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូង
- ដីកាសម្រេច

៣ **ឧបសម្ព័ន្ធទី៣** : នីតិវិធីនៃការដាក់ពាក្យលែងលះនៃអាពាហ៍ពិពាហ៍ដោយសហព័ទ្ធម្ខាង

- ពាក្យបណ្តឹងលែងលះ
- ដីកាកោះចុងចម្លើយ
- ដីកាកោះដើមចោទ
- ដីកាបញ្ជូន
- កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
- កំណត់ហេតុស្តីពីនីតិវិធីសាកសួរសាម៉ីភាគី
- សាលក្រម
- លិខិតបញ្ជាក់សាលក្រមស្ថាពរ
- រូបមន្តអនុវត្តសាលក្រម

# ឧបសម្ព័ន្ធទី១
# នីតិវិធីនៃការដាក់ពាក្យ
# អគ្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ------------------------សញ្ជាតិ---------- កើតថ្ងៃទី------ ខែ-------ឆ្នាំ-------- មុខរបរបច្ចុប្បន្ន-----------------------------------------ស្ថានភាពផ្ទាល់ខ្លួន---------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ--------- ផ្លូវលេខ---------- ក្រុម---------- ភូមិ------------ ឃុំ សង្កាត់ ---------------- ក្រុង ស្រុក ខណ្ឌ----------------- រាជធានី ខេត្ត ------------------។ ឪពុកឈ្មោះ--------------------------អាយុ-------ឆ្នាំ (រស់ ស្លាប់) ម្តាយឈ្មោះ-----------------------អាយុ-------ឆ្នាំ (រស់ ស្លាប់)។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់........................................**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំរៀបអាពាហ៍ពិពាហ៍។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ----------------------ភេទ------ សញ្ជាតិ-----------កើតថ្ងៃទី------ ខែ-------ឆ្នាំ--------------------------------មុខរបរ------------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុម--------- ភូមិ--------------ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------- រាជធានី ខេត្ត ------------------ប្រទេស ------------------។

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់------------------------------ មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ។

ធ្វើនៅ-------------ថ្ងៃទី------- ខែ----------- ឆ្នាំ-------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃស្តាំសាមីខ្លួន**

- -----------------------------
- -----------------------------
- -----------------------------

ឈ្មោះ-----------

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំបញ្ជាក់

**ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ-------------------- ភេទ------- សញ្ជាតិ------- កើតនៅថ្ងៃ-----------ទី------ ខែ-------ឆ្នាំ------- នៅភូមិ------------------- ឃុំ សង្កាត់---------------------ក្រុង ស្រុក ខណ្ឌ-------------- រាជធានី ខេត្ត--------------------- មុខរបរបច្ចុប្បន្ន----------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ-------- ក្រុម------ ភូមិ----------- ឃុំ សង្កាត់------------ ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត --------------- ។

**គោរពជូន**

**មេឃុំ ចៅសង្កាត់**------------------------

**<u>កម្មវត្ថុ</u>** ៖ សំណើសុំលិខិតបញ្ជាក់ភាព----------------------------- ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមជម្រាបលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាជ្រាបថា បច្ចុប្បន្ន ខ្ញុំបាទ នាងខ្ញុំ មានស្ថានភាពផ្ទាល់ខ្លួន---------------------- ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ-------------- ភេទ--------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------ ផ្លូវលេខ---------ក្រុម---------- ភូមិ------------------------ ឃុំ សង្កាត់--------------------- ក្រុង ស្រុក ខណ្ឌ------------------------ រាជធានី ខេត្ត ---------------------ប្រទេស------------- ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាចេញលិខិតបញ្ជាក់ឱ្យខ្ញុំបាទ នាងខ្ញុំ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន ដោយអនុគ្រោះ ។

ដើម្បីជាសក្ខីភាពនៃការអះអាងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមផ្ដិតស្នាមមេដៃស្ដាំ ទុកជាភស្តុតាង ។

ធ្វើនៅ -----------ថ្ងៃទី-------- ខែ-------- ឆ្នាំ---------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃសាមីខ្លួន**

- --------------------------
- --------------------------
- --------------------------

ឈ្មោះ ------------

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

4x6

រាជធានី ខេត្ត ----------------

ក្រុង ស្រុក ខណ្ឌ ----------------

ឃុំ សង្កាត់ ----------------

លេខ ----------------

ថ្ងៃទី------ ខែ---------- ឆ្នាំ------

## លិខិតបញ្ជាក់

## ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ

យោងពាក្យសុំបញ្ជាក់ភាព------------- ចុះថ្ងៃទី------ ខែ---------- ឆ្នាំ------- របស់------------------------។

**យើងមេឃុំ ចៅសង្កាត់**-----------------------

សូមបញ្ជាក់ថា ឈ្មោះ----------------------- ភេទ------- កើតនៅថ្ងៃ------ ទី------- ខែ----------ឆ្នាំ-------- នៅភូមិ------------ ឃុំ សង្កាត់--------------- ក្រុង ស្រុក ខណ្ឌ-----------------រាជធានី ខេត្ត------------------ ប្រទេស--------------មុខរបរបច្ចុប្បន្ន---------------------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ-------- ក្រុម------- ភូមិ--------------ឃុំ សង្កាត់-----------------ក្រុង ស្រុក ខណ្ឌ-------------------- រាជធានី ខេត្ត-----------------ប្រទេស--------------មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន ពិតជា------------------ ប្រាកដមែន។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ក្នុងការសុំរៀបអាពាហ៍ពិពាហ៍។

(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ)

**មេឃុំ ចៅសង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** -------------------

**ក្រុង ស្រុក ខណ្ឌ** -------------------

**ឃុំ សង្កាត់** -------------------

**លេខ** -------------------

# បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្តឹងជំទាស់ | | |
| នាមត្រកូល និងនាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និងនាមខ្លួនម្តាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី.............. ខែ......................... ឆ្នាំ................. ។

ធ្វើនៅ........................ ថ្ងៃទី........... ខែ................. ឆ្នាំ............

**មន្ត្រីអត្រានុកូលដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ---- *អ៊ូ ទូនស្រី* ---- សញ្ជាតិ-- *ខ្មែរ* --កើតថ្ងៃទី--១៧-- ខែ--មករា-- ឆ្នាំ-- *១៩៧៥* -
មុខរបរបច្ចុប្បន្ន---------------- *គ្រូពេទ្យ* ----------------------ស្ថានភាពផ្ទាល់ខ្លួន------ *នៅលីវ* -------------
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ---------- ក្រុម--------- ភូមិ---------- *ភ្លីចាស់* ---------
ឃុំ សង្កាត់------- *ពាក់ខែង* ------- ស្រុក ខណ្ឌ------- *ជ្រោយចង្វារ* ------ ខេត្ត រាជធានី------- *ភ្នំពេញ* ------- ។
ឪពុកឈ្មោះ------ *អ៊ូ សែម* ------ អាយុ---៦០---ឆ្នាំ (ស្លាប់ រស់) ម្តាយឈ្មោះ------ *ទូន ផល្លា* ------ អាយុ---
*៥៥* ---ឆ្នាំ (ស្លាប់ រស់) ។

**គោរពជូន**
**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់------ *ពាក់ខែង* ------**

**<u>កម្មវត្ថុ</u>** ÷ សំណើសុំរៀបអាពាហ៍ពិពាហ៍ ។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ----- *សាយ សំអាន* ----- ភេទ--- *ប្រុស* -- សញ្ជាតិ--- *ខ្មែរ* -- កើតថ្ងៃទី--២៥-- ខែ--សីហា-- ឆ្នាំ--- *១៩៧៣* -- មុខរបរ------------ *សាស្ត្រាចារ្យ* ----- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------ផ្លូវលេខ---------ក្រុម------ភូមិ------ *ពាក់ខែង* -------ឃុំ សង្កាត---- *ព្រែកលៀប* -- ស្រុក ខណ្ឌ------ *ជ្រោយចង្វារ* ------- ខេត្ត រាជធានី------- *ភ្នំពេញ* ------ ប្រទេស------កម្ពុជា----- ។

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់--- *ពាក់ខែង* ----- មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី *០២* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃសាមីខ្លួន**

– ----លិខិតបញ្ជាក់ភាពនៅលីវ *០១ច្បាប់* ----
– ----សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត *០១ច្បាប់* ----
– ---សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ--

*អ៊ូ ទូនស្រី*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ---*សាយ សំអាន*-- សញ្ជាតិ--*ខ្មែរ*--កើតថ្ងៃទី---២៥---ខែ--សីហា--ឆ្នាំកំណើត--១៩៧៣-- មុខរបរបច្ចុប្បន្ន-------------*សាស្ត្រាចារ្យ*------------------------ ស្ថានភាពផ្ទាល់ខ្លួន----*នៅលីវ*---ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ--------- ផ្លូវលេខ---------- ក្រុម--------- ភូមិ---------*បាក់ខែង*---------ឃុំ សង្កាត់-------*ព្រែកលៀប*------ ស្រុក ខណ្ឌ-------*ជ្រោយចង្វារ*------ ខេត្ត រាជធានី------*ភ្នំពេញ*------ ។ ឪពុកឈ្មោះ------*សាយ សំអឿន*----- អាយុ---*៦៩*---ឆ្នាំ (ស្លាប់ រស់) ម្តាយឈ្មោះ------*សែម បុប្ផា*----- អាយុ---*៦៧*---ឆ្នាំ (ស្លាប់ រស់) ។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់**...... *បាក់ខែង* .......

**<u>កម្មវត្ថុ</u>** ÷ សំណើសុំរៀបអាពាហ៍ពិពាហ៍ ។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ---------*អ៊ូ ទូនស្រី*------------ភេទ---*ស្រី*--- សញ្ជាតិ---*ខ្មែរ*--- កើតថ្ងៃទី--១៧-- ខែ--មករា-- ឆ្នាំ--*១៩៧៩*-- មុខរបរ--------គ្រូពេទ្យ--------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------- ផ្លូវលេខ----- ក្រុម---- ភូមិ---------ក្តីចាស់-----ឃុំ សង្កាត់-----បាក់ខែង-------ស្រុក ខណ្ឌ-------ជ្រោយចង្វារ------- ខេត្ត រាជធានី-------ភ្នំពេញ-------ប្រទេស---កម្ពុជា--- ។

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់---*បាក់ខែង*---- មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី *០២* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃសាមីខ្លួន**

- ---លិខិតបញ្ជាក់ភាពនៅលីវ *០១ច្បាប់*---
- ---សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត *០១ច្បាប់*---
- ---សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ---

*សាយ សំអាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ~~ខេត្ត~~** ---- *ភ្នំពេញ* -------
**~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ** ---- *ជ្រោយចង្វារ* -----
**~~ឃុំ~~ សង្កាត់** ---- *បាក់ខែង* ------
**លេខ** ---- *០៩ ប.ខ* -----

# បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | *សាយ សំអាន* | *អ៊ូ នួនស្រី* |
| ជាអក្សរឡាតាំង | SAY SAM ANN | OU NUON SREY |
| សញ្ជាតិ | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរបច្ចុប្បន្ន | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| រយៈពេលប្ដឹងជំទាស់ | *១០ថ្ងៃ គិតពីថ្ងៃបិទផ្សាយ* | |
| នាមត្រកូល និងនាមខ្លួនឪពុក | *សាយ សំរឿន* | *អ៊ូ សែម* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| មុខរបរបច្ចុប្បន្ន | *កសិករ* | *ជាងសំណង់* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| នាមត្រកូល និងនាមខ្លួនម្ដាយ | *សែម បុប្ផា* | *នួន ផល្លា* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |
| មុខរបរបច្ចុប្បន្ន | *ជាងកាត់ដេរ* | *លក់ដូរ* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី *០៣* ខែ *កុម្ភៈ* ឆ្នាំ *២០១៥* ។

ធ្វើនៅ.... *បាក់ខែង* ....ថ្ងៃទី *០២* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

**មន្ត្រីអត្រានុកូលដ្ឋាន**
***ចៅសង្កាត់***
*ផៃ សូនី*

**រាជធានី ~~ខេត្ត~~** (១)..... *ភ្នំពេញ* ..........
**~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ** (២).... *ជ្រោយចង្វារ* ........
**~~ឃុំ~~ សង្កាត់** (៣)...... *បាក់ខែង* ........

**លេខ** (៤)............... *០៩* ............................
**សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)...*០១/២០១៥*..
**ឆ្នាំ** (៦)......... *២០១៥*..................................

## បញ្ជីអាពាហ៍ពិពាហ៍

| **អំពីប្ដី ប្រពន្ធ** | | **ប្ដី** | | **ប្រពន្ធ** | |
|---|---|---|---|---|---|
| នាមត្រកូល (៧) | | *សាយ* | | *អ៊ូ* | |
| នាមខ្លួន (៨) | | *សំអាន* | | *នួនស្រី* | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | | OU | |
| | នាមខ្លួន | SAM ANN | | NUON SREY | |
| សញ្ជាតិ (១០) | | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៥* | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *សាស្ត្រាចារ្យ* | | *គ្រូពេទ្យ* | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (១៥) | | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៦) | | *មួយ* | | *មួយ* | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៧) | | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៨) | | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | | | |
| លេខ និងថ្ងៃ ខែឆ្នាំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (១៩) | | *០៩ ប.ខ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥* | | | |
| **អំពីឪពុក ម្ដាយ** | | **ខាងប្ដី** | | **ខាងប្រពន្ធ** | |
| នាមត្រកូល និង នាមខ្លួនឪពុក (២០) | | *សាយ សំអឿន* | (២១) សញ្ជាតិ *ខ្មែរ* | *អ៊ូ សែម* | (២១) សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២២) | | SAY SAM OEUN | (២៣) រស់ ឬ ស្លាប់ | OU SEM | (២៣) រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* | |
| មុខរបរបច្ចុប្បន្ន (២៥) | | *កសិករ* | | *ជាងសំណង់* | |
| ទីលំនៅបច្ចុប្បន្ន (២៦) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២៧) | | *សែម បុប្ផា* | (២៨) សញ្ជាតិ *ខ្មែរ* | *នួន ផល្លា* | (២៨) សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២៩) | | SEM BOPHA | (៣០) រស់ ឬ ស្លាប់ | NUON PHALLA | (៣០) រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣១) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* | |
| មុខរបរបច្ចុប្បន្ន (៣២) | | *ជាងកាត់ដេរ* | | *លក់ដូរ* | |
| ទីលំនៅបច្ចុប្បន្ន (៣៣) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| **អំពីសាក្សី** | | **សាក្សី** | | **សាក្សី** | |
| នាមត្រកូល និង នាមខ្លួន (៣៤) | | *សោម ឲុយ* | (៣៥) ភេទ *ប្រុស* | *សេង ភក្តី* | (៣៥) ភេទ *ស្រី* |
| សញ្ជាតិ (៣៦) | | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | | *ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧២* | | *ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧០* | |
| មុខរបរបច្ចុប្បន្ន (៣៨) | | *កសិករ* | | *គ្រូបង្រៀន* | |
| ទីលំនៅបច្ចុប្បន្ន (៣៩) | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (៤០) | | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤២) ធ្វើនៅ..... *បាក់ខែង* ............ ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(៤១) **ស្នាមមេដៃស្ដាំ**

ប្ដី ប្រពន្ធ សាក្សី សាក្សី

*សាយ សំអាន* *អ៊ូ នួន ស្រី* *សោម ឲុយ* *សេង ភក្តី*

(៤៣) **មន្ត្រីអត្រានុកូលដ្ឋាន**
***ចៅសង្កាត់***
(៤៤) *ហត្ថលេខា និងត្រា*
*នៃ សុទី*

**រាជធានី ខេត្ត** (១)....................................
**ក្រុង ស្រុក ខណ្ឌ** (២)...............................
**ឃុំ សង្កាត់** (៣)......................................

**លេខ** (៤)...................................................
**សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)............
**ឆ្នាំ** (៦)........................................................

## បញ្ជីអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់

| **អំពីប្តី ប្រពន្ធ** | | **ប្តី** | | **ប្រពន្ធ** | |
|---|---|---|---|---|---|
| នាមត្រកូល (៧) | | | | | |
| នាមខ្លួន (៨) | | | | | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | | | | |
| | នាមខ្លួន | | | | |
| សញ្ជាតិ (១០) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | | | | |
| ទីកន្លែងកំណើត (១២) | | | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | | | | |
| ទីលំនៅឯបរទេស (១៥) | | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៦) | | | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតអោយស្នាក់នៅកម្ពុជាលេខ ថ្ងៃខែ ឆ្នាំ(១៧) | | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៨) | | | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៩) | | | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (២០) | | | | | |
| លេខ និង ថ្ងៃ ខែ ឆ្នាំ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (២១) | | | | | |
| **អំពីឪពុក ម្តាយ** | | **ខាងប្តី** | | **ខាងប្រពន្ធ** | |
| នាមត្រកូល និង នាមខ្លួនឪពុក (២២) | | | (២៣) រស់ ឬ ស្លាប់ | | (២៣) រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (២៤) | | | | | |
| សញ្ជាតិ (២៥) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៦) | | | | | |
| មុខរបរបច្ចុប្បន្ន (២៧) | | | | | |
| ទីលំនៅបច្ចុប្បន្ន (២៨) | | | | | |
| នាមត្រកូល និង នាមខ្លួនម្តាយ (២៩) | | | (៣០) រស់ ឬ ស្លាប់ | | (៣០) រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (៣១) | | | | | |
| សញ្ជាតិ (៣២) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៣) | | | | | |
| មុខរបរបច្ចុប្បន្ន (៣៤) | | | | | |
| ទីលំនៅបច្ចុប្បន្ន (៣៥) | | | | | |
| **អំពីសាក្សី** | | **សាក្សី** | | **សាក្សី** | |
| នាមត្រកូល និង នាមខ្លួន (៣៦) | | | (៣៧) ភេទ | | (៣៧) ភេទ |
| ជាអក្សរឡាតាំង (៣៨) | | | | | |
| សញ្ជាតិ (៣៩) | | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៤០) | | | | | |
| មុខរបរបច្ចុប្បន្ន (៤១) | | | | | |
| ទីលំនៅបច្ចុប្បន្ន (៤២) | | | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៤៣) | | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យអ្នកដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៥) ធ្វើនៅ.................... ថ្ងៃទី.......... ខែ................ ឆ្នាំ...............

(៤៤) **ស្នាមមេដៃស្តាំ**

ប្តី ប្រពន្ធ សាក្សី សាក្សី

(៤៦) **មន្ត្រីអត្រានុកូលដ្ឋាន**

(៤៧) ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ~~ខេត្ត~~ (១) ----- *ភ្នំពេញ* -----

~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ (២) ----- *ជ្រោយចង្វារ* -----

~~ឃុំ~~ សង្កាត់ (៣) ----- *បាក់ខែង* ------

លេខ (៤)-------*០៥*--------------------------

សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)-*០១/២០១៥*

ឆ្នាំ (៦)-------- *២០១៥* -----------------------

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល (៧) | | *សាយ* | *អ៊ូ* |
| នាមខ្លួន (៨) | | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | *SAY* | *OU* |
| | នាមខ្លួន | *SAM ANN* | *NUON SREY* |
| សញ្ជាតិ (១០) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | |
| **អំពីឪពុក ម្តាយ** | | **ខាងប្តី** | **ខាងប្រពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៨) | | *SAY SAM OEUN* | *OU SEM* |
| សញ្ជាតិ (១៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្តាយ (២១) | | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២២) | | *SEM BOPHA* | *NUON PHALLA* |
| សញ្ជាតិ (២៣) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៥) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(២៦) **មន្ត្រីអត្រានុកូលដ្ឋាន**

***ចៅសង្កាត់***

(២៧) *ហត្ថលេខា និងត្រា*

*ផៃ សុទី*

# សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាឃុំ សង្កាត់)

| លេខរៀង | ថ្ងៃខែឆ្នាំ ចេញ សេចក្តីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្តី ប្រពន្ធ | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬ បញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬ បញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬ បញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| ០១ | ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ | ចម្លងសំបុត្រ អាពាហ៍ពិពាហ៍ | ០១/ ២០១៥ | បាក់ខែង | ០៩ | ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ | សាយ សំអាន<br>អ៊ុ នួនស្រី | ខ្មែរ<br>ខ្មែរ | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣<br>ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩ | សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | ថ្ងៃសុក្រ ទី២១ ខែ កុម្ភៈ ឆ្នាំ២០១៥ | សាយ សំអាន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | សាមីខ្លួន | | ផៃ សូនី | ចៅសង្កាត់ | ០៥ សន្លឹក | |
| | | | | | | | ប្តី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្តី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

## សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាក្រុង ស្រុក ខណ្ឌ)

| លេខរៀង | ថ្ងៃខែឆ្នាំចេញសេចក្តីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្តី ប្រពន្ធ | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| ០១ | ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ | ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ០១/២០០៥ | ព្រែកគយ | ១២ | ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ | ទេព សឿង<br>ភួង វណ្ណា | ខ្មែរ<br>ខ្មែរ | ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨<br>ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣ | ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល | ថ្ងៃសុក្រ ទី១៥ ខែសីហា ឆ្នាំ២០០៥ | ទេព សឿង | ភូមិសំប៉ាន់លើ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា | សាមីខ្លួន | | គុង គីមយ៉ន | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | ០៦ សន្លឹក | |
| | | | | | | | ប្តី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្តី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជធានី ~~ខេត្ត~~** (១) ----- *ភ្នំពេញ*-----

**~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ** (២) ---- *ជ្រោយចង្វារ*--

**~~ឃុំ~~ សង្កាត់** (៣) ----- *បាក់ខែង* ----

## សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

| ចម្លងសំបុត្រអាពាហ៍ពិពាហ៍ចេញពី | (៤) សៀវភៅអាពាហ៍ពិពាហ៍<br>លេខ ៖--- *០១/២០១៥*------ | (៥) សំបុត្រអាពាហ៍ពិពាហ៍<br>លេខ *០៩* ចុះថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥* |
|---|---|---|
| អំពីប្តី ប្រពន្ធ | ប្តី | ប្រពន្ធ |
| នាមត្រកូល (៦) | *សាយ* | *អ៊ូ* |
| នាមខ្លួន (៧) | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៨) នាមត្រកូល | SAY | OU |
| ជាអក្សរឡាតាំង (៨) នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (៩) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១០) | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត (១១)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១២) | *សាស្ត្រចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | |
| អំពីឪពុក ម្តាយ | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៧) | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៨) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្តាយ (២០) | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២១) | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២២) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៤) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**-----
***ចៅសង្កាត់***
(២៦) *ហត្ថលេខា និងត្រា*
*ផៃ សួនី*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** (១) ----- *កណ្តាល* -----
**ក្រុង ស្រុក ខណ្ឌ** (២) ----- *ស្អាង* --------
**ឃុំ សង្កាត់** (៣) -----*ព្រែកគយ*--------

## សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

| ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ លេខ ៖ *០១/២០០៥* | (៥) សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ១២ ចុះថ្ងៃទី *១៥* ខែ *សីហា* ឆ្នាំ *២០០៥* |
|---|---|---|---|
| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
| នាមត្រកូល (៦) | | *ទេព* | *ភួង* |
| នាមខ្លួន (៧) | | *សឿង* | *វណ្ណា* |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | TEP | PHUONG |
| | នាមខ្លួន | SOEUNG | VANNA |
| សញ្ជាតិ (៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨* | *ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣* |
| ទីកន្លែងកំណើត (១១) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិកណ្តាល ឃុំព្រែកឡៅ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិសំបាំទលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១២) | | *គ្រូបង្រៀន* | *ជាងកាត់ដេរ* |
| ទីលំនៅពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៣) | | *ភូមិទួលសូភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិទួលសូភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៤) | | *ថ្ងៃ សុក្រ ទី ១៥ ខែ សីហា ឆ្នាំ ២០០៥* | |
| ទីកន្លែងចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៥) | | *ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល* | |
| អំពីឪពុក ម្តាយ | | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | | *ទេព សួង* | *កៅ សៀម* |
| ជាអក្សរឡាតាំង (១៧) | | TEP SUONG | KAO SEAM |
| សញ្ជាតិ (១៨) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩២៣* | *ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩២២* |
| នាមត្រកូល និង នាមខ្លួនម្តាយ (២០) | | *ប្រាក់ សម្បត្តិ* | *សុខ សន* |
| ជាអក្សរឡាតាំង (២១) | | PRAK SAMBATH | SOK SAN |
| សញ្ជាតិ (២២) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩២៥* | *ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩២៦* |

លេខ (ក)..... *០៥ ស.ប.អ* ............
យើង (ខ).... *អភិបាលស្រុកស្អាង* .........................
បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា
របស់លោក (គ)......*គុង្គ គីមយ៉ន*....... ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន (ឃ)...... *ស្រុកស្អាង*..........ពិតប្រាកដមែន ។
(ង) ធ្វើនៅ...ស្អាង.... ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤
(ច) *ហត្ថលេខា និងត្រា*
*ខឹម ច័ន្ទគិរី*

(២៤) ធ្វើនៅ....ស្អាង ..... ថ្ងៃទី *២៤* ខែ *មករា* ឆ្នាំ *២០១៤*
(២៥) **មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**----
*ហត្ថលេខា*
*គុង្គ គីមយ៉ន*

# ឧបសម្ព័ន្ធទី២

# នីតិវិធីនៃការដាក់ពាក្យលែងលះនៃ
# អាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ដីកាកោះ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

| | |
|---|---|
| បង្គាប់មកចុងចម្លើយឈ្មោះ ................ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ធិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។ | |
| សញ្ញាណនៃរឿងក្ដី (លេខ និងភាគី) | សំណុំរឿងក្ដីរដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ................ ចុងចម្លើយ: ................ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់) | ១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល ☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់) | |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្ដីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៩០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៩ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>ធ្វើនៅរតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម** | |

**បញ្ជាក់**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។
-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាកោះ

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី

<table>
<tr><td colspan="2">បង្គាប់មកឈ្មោះ ................ ជាដើមចោទ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៦៤/២០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០២០<br>ដើមចោទឈ្មោះ ................ ចុងចម្លើយ: ................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៤៩៩$ (បីពាន់បួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៩ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>រតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

*សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង*
*លេខ.........................*

## កំណាត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូង

*បានឃើញមាត្រា១១៣ ដល់មាត្រា១២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស់ឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។*

*សញ្ញាណរឿងក្តី*
*ប្តឹងសុំតុលាការអនុវត្តដោយបង្ខំដូចខាងក្រោម*

*១. សុំលែងលះរវាងពីប្តីឈ្មោះ ..................... និងប្រពន្ធឈ្មោះ ...................... ។*

*២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ ...................... ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ...................... ។*

*លោក ................. ប្រធាននិងចៅក្រមសាលាដំបូងខេត្តរតនគិរី*
*លោក ..................... ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី*

***អ្នកដាក់ពាក្យសុំឈ្មោះ*** ...................... *ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ភាគីម្ខាងទៀតឈ្មោះ*** .................. *ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ឆ្នាំពីរពាន់មួយម្ភៃ ខែឧសភា ថ្ងៃទីប្រាំពីរ វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក*** *នៅសាលាដំបូងខេត្តរតនគិរី បានធ្វើនីតិវិធីផ្សះផ្សារដល់គូភាគីដើម្បីឲ្យបានរស់នៅជាប្តីប្រពន្ធនិងគ្នាវិញ ប៉ុន្តែគូភាគីនៅតែមិនអាចរស់នៅជាមួយគ្នាបាន ហេតុនេះតុលាការបញ្ឈប់នីតិវិធីផ្សះផ្សារ ដោយបន្តនីតិវិធីបញ្ជាក់ដំបូងរវាងអ្នកដាក់ពាក្យសុំឈ្មោះ ................. ជាមួយនិងភាគីម្ខាងទៀតឈ្មោះ ............. ។*

*-អ្នកដាក់ពាក្យសុំឈ្មោះ ............................... បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅសាលាសង្កាត់បឹងកន្សែង។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍នាងខ្ញុំមានកូនចំនួន១នាក់ ។ នាងខ្ញុំសុំសិទ្ធគ្រប់គ្រង ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុល នាងខ្ញុំនិងប្តីបានព្រមព្រៀងគ្នារួចរាល់*

*អស់ហើយ សុំឲ្យលោកចៅក្រម ទទួលស្គាល់ការព្រមព្រៀងនេះផង មានក្នុងកំណត់ហេតុ ផ្សះផ្សាសម្របសម្រួលលេខ ២៤/០១,០៤,២០១៩ ។*

*មកដល់ដំណាក់កាលនេះ នាងខ្ញុំអស់មនោសញ្ចេតនានិងគ្នាហើយ នាងខ្ញុំបានធ្វើកិច្ចព្រមព្រៀងលែងលះ ជាមួយភាគីប្ដី បន្ទាប់មកបានដាក់ពាក្យសុំឲ្យតុលាការសម្រេចលែងលះតាមការព្រមព្រៀង និងសុំសិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់។*

*-ភាគីម្ខាងទៀតឈ្មោះ ................. បានធ្វើសេចក្ដីថ្លែងការណ៍តបថាះ ខ្ញុំបាទឯកភាពតាមសេចក្ដីថ្លែងការណ៍របស់ភាគីអ្នកដាក់ពាក្យសុំ ដោយយល់ព្រមលែងលះពីប្រពន្ធឈ្មោះ ........................ និងយល់ព្រមប្រគល់កូនចំនួន១នាក់ឲ្យទៅអ្នកដាក់ពាក្យសុំ។ ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុលរូបខ្ញុំបាទនិងប្រពន្ធបានព្រមព្រៀងគ្នារួចរាល់អស់ហើយ។*

*រីឯប្រាក់អាហារកិច្ចសុំបង់ជូនក្នុងមួយខែៗ ចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) រហូតដល់កូនធំពេញវ័យ ។*

*-អ្នកដាក់ពាក្យសុំឈ្មោះ ........................ បានធ្វើសេចក្ដីថ្លែងការណ៍ថាះ នាងខ្ញុំឯកភាព ចំពោះសេចក្ដីថ្លែងការណ៍របស់ភាគីប្ដី ដោយមិនមានសំណូមពរអ្វីទៀតនោះឡើយ។*

***យើងបានបញ្ចប់សេចក្ដីបញ្ជាក់ដំបូង នៅវេលាម៉ោងដប់មួយ ព្រឹកថ្ងៃខែឆ្នាំដដែល។***

***បានអានកំណត់ហេតុនៃនីតិវិធីនៃសេចក្ដីបញ្ជាក់ដំបូងជូនភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ធ្វើយថាត្រឹមត្រូវសូមផ្ដិតមេដៃទុកជាកស្ដុតាង ។***

| **អ្នកដាក់ពាក្យសុំ** | **ភាគីម្ខាងទៀត** | **ក្រឡាបញ្ជី** | **ចៅក្រម** |
|---|---|---|---|
| ...................... | ...................... | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណីមិនមែន
បណ្តឹងលេខ..................................
ដីកាសម្រេចលេខ: .............. /២០

## ដីកាសម្រេច

យើង ................. ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

អមដោយលោក ................... ជាក្រឡាបញ្ជី

-បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២៧ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦។

-បានបញ្ចប់នីតិវិធីបញ្ជាក់ដំបូងនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ៦៤ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។

**រវាង**

អ្នកដាក់ពាក្យសុំឈ្មោះ .................... ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

**នឹង**

ភាគីម្ខាងទៀតឈ្មោះ ............... ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

កម្មវត្ថុនៃបណ្តឹង

១. សុំលែងលះរវាងពីប្តីឈ្មោះ ............... និងប្រពន្ធឈ្មោះ ................... ។

២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ .......... ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ................... ។

បានឃើញកំណត់ហេតុស្តីពីសេចក្តីបញ្ជាក់ដំបូងចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ រវាងអ្នកដាក់ពាក្យសុំឈ្មោះ ..................... និងភាគីម្ខាងទៀតឈ្មោះ .................. ដោយភាគីទាំងពីរ ស្នើសុំឱ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំរបស់ខ្លួនដោយលែងលះតាមការព្រមព្រៀង។

## យល់ឃើញថា

១-ពាក្យសុំចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អ្នកដាក់ពាក្យសុំឈ្មោះ ...................... និងភាគីម្ខាងទៀតឈ្មោះ ................ ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២- នៅតំណាក់កាលនៃនីតិវិធីបញ្ជាក់ដំបូង តុលាការបានព្យាយាមធ្វើការផ្សះផ្សារួចហើយ ប៉ុន្តែគូភាគីនៅតែមិនព្រមសះជានឹងគ្នាវិញទេ ដោយគូភាគីនៅតែស្នើសុំឱ្យតុលាការ សម្រេចលែងលះឲ្យខ្លួនដដែល។ គប្បីតុលាការលើកយកការស្នើសុំរបស់ភាគីទាំងពីរមកពិចារណា។

៣-គូភាគីបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៣៧ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ នៅសាលាសង្កាត់ បឹងកន្សែង ក្រុងបានលុង បញ្ជាក់ថា គូភាគីគឺពិតជាមានអាពាហ៍ពិពាហ៍ស្របច្បាប់ប្រាកដមែន។ ដូចនេះដើម្បីចៀសវាងបញ្ហាផ្សេងៗកើតឡើងជាយថាហេតុ គប្បីតុលាការសម្រេចឲ្យលែងលះរវាងគូភាគីតាមការព្រមព្រៀង។

៤-នៅក្នុងនីតិវិធីបញ្ជាក់ដំបូង ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោមៈ

ក-លែងលះជាប្តី-ប្រពន្ធ

ខ-ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់ឈ្មោះ .................... ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................. ជាម្តាយអ្នកគ្រប់គ្រង។

៥- តាមបញ្ញត្តិមាត្រា៤៧ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីកាតព្វកិច្ចរបស់មាតាបិតា ក្នុងការរួមគ្នាចិញ្ចឹមបីបាច់ ថែរក្សាកូនឲ្យក្លាយទៅជាពលរដ្ឋល្អក្នុងសង្គម និងមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី (ការសម្រេចអំពីអ្នកមានអំណាចមេបា) គប្បីគូភាគី រួមគ្នាបំពេញកាតព្វកិច្ចរបស់ខ្លួនតាមបញ្ញត្តិច្បាប់។

៦-ដោយសម្ព័ន្ធភាពជីវិតអាពាហ៍ពិពាហ៍របស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានធ្វើឲ្យសហព័ទ្ធម្ខាងៗទទួលរងសម្ពាធផ្លូវចិត្តធ្វើឲ្យផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ។ គប្បីតុលាការលើកយកការស្នើសុំ និងការព្រមព្រៀងគ្នារបស់ភាគីតាមនីតិវិធីបញ្ជាក់ដំបូង មកសម្រេចដោយយោងតាមបញ្ញត្តិមាត្រា៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៧-ភាគីនៃអាពាហ៍ពិពាហ៍ មានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ គប្បីតុលាការទទួលយកមកពិចារណា និងសម្រេចតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

៨-ទ្រព្យសម្បត្តិរួមនិងប្រាក់បំណុល នៅក្នុងកំណត់ហេតុនៃនីតិវិធី សេចក្តីបញ្ជាក់ដំបូង ភាគីអ្នកដាក់ពាក្យសុំឈ្មោះ ...................... និងភាគីម្ខាងទៀតឈ្មោះ .................... បានបញ្ជាក់ថាខ្លួនបានព្រមព្រៀងគ្នារួចរាល់អស់ហើយ ចំណុចនេះមិនគប្បីតុលាការលើកមកធ្វើការពិចារណានោះឡើយ ។

៩-នៅក្នុងដំណាក់កាលនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានឯកភាពគ្នាក្នុងការបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូន ក្នុងមួយខែៗចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) គប្បីតុលាការសម្រេចតាមការព្រមព្រៀង ។

ជាការសន្និដ្ឋាន គប្បីសម្រេចលែងលះរវាងអ្នកដាក់ពាក្យសុំឈ្មោះ ..................... និងភាគីម្ខាងទៀតឈ្មោះ .................. តាមពាក្យសុំលែងលះតាមការព្រមព្រៀងរបស់ភាគី ទៅតាមបញ្ញត្តិមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

**ហេតុដូច្នេះសម្រេច**

ក/-ឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. និងភាគីម្ខាងទៀតឈ្មោះ ................ ផ្តាច់សមគ្គសង្វាសតាមការព្រមព្រៀងរបស់គូភាគី មាត្រា ៧៧៨ និងមាត្រា ៧៧៩ នៃក្រមរដ្ឋប្បវេណី។

ខ/-ប្រគល់សិទ្ធិចិញ្ចឹម បីបាច់ ថែរក្សាកូនចំនួនមួយនាក់ឈ្មោះ .................. ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................... ជាម្តាយជាអ្នកមានអំណាចមេបាតាមមាត្រា ៤៧ រដ្ឋធម្មនុញ្ញ និង មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

គ/-ភាគីដែលមិនបានគ្រប់គ្រង ថែរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូនបានគ្រប់ពេលវេលាតាមមាត្រា ១០៣៨ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។ ភាគីដែលគ្រប់គ្រងថែរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលឲ្យភាគីម្ខាងទៀតបានបំពេញកិច្ចការនេះ។

ឃ/-បង្គាប់មកឈ្មោះ ................. បង់ប្រាក់អាហារកិច្ចចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) សម្រាប់ចិញ្ចឹមកូនរហូតដល់ធំពេញវ័យជូនទៅអ្នកស្រី ជឿន ច័ន្ទលីដា ក្នុងមួយខែៗ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ ។

ង/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំដែលបានបង់រួច។

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

..............................

---

**បានឃើញនិងឯកភាព**

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ប្រធានសាលាដំបូង**

បានចម្លងតាមច្បាប់ដើម

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធទី៣

## នីតិវិធីនៃការដាក់ពាក្យលៃលកនៃ

## អាពាហ៍ពិពាហ៍ដោយសហព័ទ្ធម្ខាង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹងលែងលះ

**ដើមចោទ៖** ឈ្មោះ ...................... ភេទស្រី អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្នភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី លេខទូរស័ព្ទ ០៩៧ ៦៩ ៣២ ០០៦។

**ចុងចម្លើយ៖** ឈ្មោះ .................. ភេទប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរធ្វើចំការ មានទីលំនៅបច្ចុប្បន្នជា ទណ្ឌិត (នៅក្នុងពន្ធនាគារខេត្តរតនគិរី) ។

**សូមគោរពជូន**
**លោក ប្រធាន សាលាដំបូងខេត្តរតនគីរី**

**សូមទានជ្រាប!**

**តាមរយៈ៖** លោកប្រធានលេខាធិការដ្ឋានសាលាដំបូងខេត្តរតនគិរី

**កម្មវត្ថុ ៖** សុំប្ដឹងឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម

-លែងលះប្ដីឈ្មោះ .....................

-សុំសិទ្ធគ្រប់គ្រងកូន ប្រុស ស្រី ចំនួន ០២ នាក់

អង្គហេតុ មូលហេតុចាំបាច់បញ្ជាក់អំពីការទាមទារ

តបតាមអង្គហេតុ មូលហេតុ និងកម្មវត្ថុខាងលើនាងខ្ញុំសូមគោរពជម្រាបជូនលោក **ប្រធាន** មេត្តាជ្រាបថា៖ នាងខ្ញុំបានរួមរស់ជាមួយ និងភាគីប្ដី ក្នុងឆ្នាំ ២០១៧ តាមប្រពៃណី ដោយមិនមានការបញ្ជាក់ និងចុះសំបុត្រអាពាហ៍ពិពាហ៍អ្វីឡើយ មានតែប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ តែប៉ុណ្ណោះ។

រយះពេលរួមរស់និងគ្នាក្នុងគ្រួសារ មិនមានការគោរពសិទ្ធគ្នាជាប្ដីប្រពន្ធ និងចុងក្រោយនេះភាគីប្ដីបានប្រើប្រាស់គ្រឿងញៀន ត្រូវបានតុលាការផ្ដន្ទាទោសតាមផ្លូវច្បាប់ ។

ដើម្បីជៀសវាងបញ្ហាផ្សេងៗដែលកើតមានក្នុងគ្រួសារតទៅទៀត នាងខ្ញុំសុំដាក់ពាក្យបណ្ដឹងមកលោក ប្រធាន សុំចេញសាលក្រមតាមកម្មវត្ថុខាងលើ ដើម្បីបានបញ្ចប់បញ្ហាគ្រួសារដោយសន្តិវិធីតាមច្បាប់ ។

## ភស្តុតាងបញ្ជាក់

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

-សៀវភៅគ្រួសារ

-សៀវភៅស្នាក់នៅ

-សំបុត្របញ្ជាក់កំណើត កូនស្រីឈ្មោះ .......................

-សំបុត្របញ្ជាក់កំណើត កូនប្រុសឈ្មោះ ........................

-អត្តសញ្ញាណប័ណ្ណ ០១ សន្លឹក

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមលោក **ប្រធាន** មេត្តាទទួលពាក្យបណ្តឹងរបស់នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូមលោក **ប្រធាន** មេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ៕

ថ្ងៃ សុក្រ ៧ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅរតនគិរី,ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២០
**ស្នាមមេដៃស្តាំ**

..........................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

<table>
<tr><td colspan="2">បង្គាប់មកចុងចម្លើយឈ្មោះ .......... ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។ មានលេខទូរស័ព្ទ៖ ០៣១ ៦៦៦៦ ៥២៨</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ...................... ចុងចម្លើយ: ......................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក<br>បន្ទប់ស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល ☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៥០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br><br>ថ្ងៃ.............................. ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤<br>ធ្វើនៅរតនគិរី, ថ្ងៃទី............ ខែ មិថុនា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

| | |
|---|---|
| បង្គាប់មកដើមចោទឈ្មោះ ............. ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគរ។ មានលេខទូរស័ព្ទ៖ ០៩៧ ៧៦០ ៩៤ ៩៣ | |
| សញ្ញាណនៃរឿងក្តី (លេខ និងភាគី) | សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ................. ចុងចម្លើយ: ....................... |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក<br>បន្ទប់ស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់) | ១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់) | |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៤៩៩$ (បីពាន់បួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃ.............................. ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤<br>ធ្វើនៅរតនគិរី, ថ្ងៃទី...............ខែមិថុនា ឆ្នាំ២០២០<br>**ចៅក្រម** | |

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាបញ្ជូន

**សាលាដំបូងខេត្តរតនគិរី**

លេខ ................./២០

## ផ្ញើជូន
## លោក អធិការនៃអធិការដ្ឋាននគរបាលស្រុកអូរយ៉ាដាវ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | គោលដៅ |
|---|---|---|---|
| ០១ | -ដីកាកោះ ដើមបណ្ដឹង<br>ឈ្មោះ ........................ | ០២ ច្បាប់ | ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្តន៍។ |
| ០២ | -ដីកាកោះ ចុងចម្លើយ<br>ឈ្មោះ ........................ | ០២ ច្បាប់ | |
| | | | |
| | សរុបចំនួន | ០៤ច្បាប់ | |

ថ្ងៃ............................ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរី,ថ្ងៃទី............ ខែមិថុនា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

**បានទទួល**

ធ្វើនៅរតនគិរី,ថ្ងៃទី................ខែឧសភា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី
លេខ..............................

## កំណត់ហេតុស្តីពីនីតិវិធីត្រៀម
## សម្រាប់ការទាយហេតុផល

បានឃើញមាត្រា១០៩,១១០,១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស់ឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

## សញ្ញាណរឿងក្តី

ប្តឹងសុំឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម៖

១. សុំផ្តាច់ នីតិសង្វាសឈប់រួមរស់ជាមួយគ្នា រំលាយសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងក្រុមហ៊ុន និងទទួលខុសត្រូវលើបំណុលទាំងអស់ ។

៤. ប្រគល់ដីលំនៅដ្ឋានចំនួន ០២កន្លែង និងរថយន្តចំនួន ០១គ្រឿង ជូនទៅភាគីប្តី ។

លោក .................... ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

លោក ........................ ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

ដើមបណ្តឹងឈ្មោះ ................. ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មុខរបរ អាជីវករគ្រប់គ្រងរថយន្តដឹកអ្នកដំណើរ លេខទូរស័ព្ទ ០៩៧ ៧៦០ ៤៥ ៩៣ មានមេធាវីតំណាងដោយអណត្តិ ........................ ។

**ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងប្រាំបួន និងសូន្យ១នាទីព្រឹក** នៅសាលាដំបូងខេត្តរតនគិរី

**ស.ឆ** ដើមបណ្តឹងឈ្មោះ .................... បានឆ្លើយបញ្ជាក់ថា នាងខ្ញុំសុំអោយ លោកចៅក្រម ចេញសេចក្តីសម្រេច តាមពាក្យបណ្តឹងរបស់នាងខ្ញុំ ចុះថ្ងៃទី៣១.០៥.២០២០ ក្នុងការលែងលះ បែងចែកទ្រព្យរួម សងបំណុល និងសិទ្ធិគ្រប់គ្រងកូន ដោយមូលហេតុ នាងខ្ញុំនឹងប្តី រស់នៅមិនចុះសម្រុងនឹងគ្នា ទើបសម្រេចចិត្តលែងលះគ្នាតាមផ្លូវច្បាប់ ហើយក្នុងពេលនេះ ប្តីនាងខ្ញុំក៏បានព្រមព្រៀងតាមពាក្យបណ្តឹងនេះដែរ ។

**ស.ឆ** មេធាវី លោក ........... បានឆ្លើយបញ្ជាក់ថា កូនក្តីរបស់ខ្ញុំបាទពិតជារស់នៅមិនចុះសម្រុងជាមួយនឹងភាគីប្តី ហើយមានបញ្ហាក្នុងគ្រួសារគ្រប់បែបយ៉ាង ទើបមកពឹងពាក់រូបខ្ញុំបាទជាមេធាវី ដាក់ពាក្យបណ្តឹងមកតុលាការ ដោយសុំលែងលះ បែងចែកទ្រព្យរួម សងបំណុល និងសិទ្ធិគ្រប់គ្រងកូន ហើយភាគីប្តីក៏បានព្រមព្រៀងគ្នា ហេតុនេះសុំឲ្យលោកចៅក្រម សម្រេចសេចក្តីតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក បានអានអោយដើមបណ្តឹង មេធាវី ស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **ដើមបណ្តឹង** **មេធាវី**

........................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី
លេខ.........................

## កំណត់ហេតុស្ដីពីនីតិវិធីត្រៀម
## សម្រាប់ការទាយហេតុផល

បានឃើញមាត្រា១០៩,១១០,១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

## សញ្ញាណរឿងក្ដី

ប្ដឹងសុំឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម៖

១. សុំផ្ដាច់ នីតិសង្វាសឈប់រួមរស់ជាមួយគ្នា រំលាយសំបុត្រអាពាហ៍ពិពាហ៍ ០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងក្រុមហ៊ុន និងទទួលខុសត្រូវលើបំណុលទាំងអស់ ។

៤. ប្រគល់ដីលំនៅដ្ឋានចំនួន ០២កន្លែង និងរថយន្តចំនួន ០១គ្រឿង ជូនទៅភាគីប្ដី ។

លោក .................... ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

លោក ........................ ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

ចុងចម្លើយឈ្មោះ ...................... ភេទ ប្រុស អាយុ ៤១ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មុខរបរ មន្ត្រីកងរាជអាវុធហត្ថ លេខទូស័ព្ទ ០៣១ ៦៦៦ ៦៥ ២៨ ។

**ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងដប់ និងសូន្យៗនាទីព្រឹក** នៅសាលាដំបូងខេត្តរតនគិរី

**ស.ឆ** ចុងចម្លើយ បានឆ្លើយបញ្ជាក់ថា ខ្លួនឯកភាពតាមការលើកឡើងរបស់ដើមបណ្ដឹង និងការបញ្ជាក់របស់លោកមេធាវី ដើម្បីបានបញ្ចប់បញ្ហាគ្រួសារតាមច្បាប់ដោយសន្តិវិធី ។

**ស.ឆ** ចំពោះទ្រព្យសម្បត្តិរួម ប្រាក់បំណុល ឯកភាពតាមពាក្យបណ្ដឹង ចំពោះកូនមានចំនួន ០២នាក់ ឯកភាពប្រគល់ជូនភាគីប្រពន្ធតាមការស្នើសុំ តែខ្លួនសុំសិទ្ធិទំនាក់ទំនង និងសួរសុខទុក្ខកូន ហេតុនេះ សុំលោក ចៅក្រម ចេញសេចក្ដីសម្រេចតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៃនីតិវិធីសេចក្ដីបញ្ជាក់ដំបូងនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក បានអានអោយចុងចម្លើយស្ដាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្ដិតមេដៃទុកជាភស្ដុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **ចុងចម្លើយ**

---------------------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
**មន្ទីរស៊ើបសួរ ទី១**

## កំណត់ហេតុស្ដីពីនីតិវិធីសាកសួរសាម៉ីភាគី

(មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

| | |
|---|---|
| សញ្ញាណរឿងក្ដី | បណ្ដឹងលេខ ...... ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២០<br>បណ្ដឹងលែងលះជានីតិសង្វាស |
| កាលបរិច្ឆេទ | ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២០<br>វេលាម៉ោងប្រាំបួន និងសូន្យៗនាទីព្រឹក |
| កន្លែងបើក/បិទ | **សាលាដំបូងខេត្តរតនគិរី** |
| ចៅក្រម | លោក ......................... |
| ក្រឡាបញ្ជី | លោក ......................... |
| ភាគីដែលបានបង្ហាញខ្លួន | -ដើមបណ្ដឹងឈ្មោះ .................... ភេទស្រី អាយុ ៣៧ ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។<br>-ចុងចម្លើយឈ្មោះ ........................ ភេទប្រុស អាយុ ៤១ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។ |

### សេចក្ដីថ្លែងការណ៍របស់ភាគីមានដូចខាងក្រោម៖

**ស.ឆ ៖** ភាគីដើមបណ្ដឹង បានឆ្លើយបញ្ជាក់ថា ខ្លួនសុំឲ្យ លោកចៅក្រម ចេញសាលក្រម មានខ្លឹមសារដូចខាងក្រោម៖

១. សុំផ្ដាច់នីតិសង្វាសពីភាគីប្ដី និងរំលាយសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

- ឈ្មោះ ......................... ភេទ ស្រី អាយុ ១៤ឆ្នាំ
- ឈ្មោះ ......................... ភេទ ប្រុស អាយុ ១១ឆ្នាំ

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិមាន

- គ្រប់គ្រងក្រុមហ៊ុន និងរថយន្តដឹកអ្នកដំណើរគ្រប់សាខាទាំងអស់ ឈ្មោះ រតនសម្បត្តិ
- ប្រព័ន្ធលេខទូរស័ព្ទគ្រប់លេខទាំងអស់ប្រើប្រាស់ក្នុងក្រុមហ៊ុនសព្វថ្ងៃ
- ទទួលរ៉ាប់រងសងបំណុលធនាគារ អេស៊ីលីដា ចំនួន ៤៥ម៉ឺនដុល្លារអាមេរិក

- បំណុលបុគ្គលផ្សេងៗមានចំនួន ៣៥ម៉ឺនដុល្លារអាមេរិក
- សុំសិទ្ធិគ្រប់គ្រងដីចំនួន ០២កន្លែង
  ១. ដីស្ថិតនៅយាយទូលចេក មានទំហំ ៤០មx៤០ម ស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី
  ២. ដីផ្លូវទៅយក្ខឡោម មានទំហំ ១២មx២៥ម ស្ថិតនៅភូមិភ្នំ សង្កាត់យក្ខឡោម ក្រុងបានលុង ខេត្តរតនគិរី ។

ដោយមូលហេតុថានាងខ្ញុំ និងប្តី រស់នៅមិនចុះសម្រុងនឹងគ្នា ទើបនាងខ្ញុំសម្រេចចិត្ត ពឹងសុំឲ្យ លោកមេធាវី ដាក់ពាក្យបណ្តឹងមកតុលាការដើម្បីបញ្ចប់ការលែងលះ បែងចែកទ្រព្យ សងបំណុល និងសិទ្ធិគ្រប់គ្រងកូន តាមផ្លូវច្បាប់ ។

**ស.ឆ** ក្នុងការលែងលះនេះ នាងខ្ញុំសុំប្រគល់ទ្រព្យសម្បត្តិជូនភាគីប្តីដូចខាងក្រោមៈ

- រថយន្ត ០១គ្រឿង ម៉ាក TOYOTA REALLY ពណ៌ស ផលិតឆ្នាំ២០២០ ផ្លាកលេខ : ភ្នំពេញ BH.9973 ។
- ផ្ទះល្វែង ០១ល្វែង ស្ថិតនៅ **បុរី លឹម ប៊ុណ្ណា** ភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

**ស.ឆ** ចុងចម្លើយ បានឆ្លើយបញ្ជាក់ថា ខ្លួនយល់ព្រមលែងលះ និងទទួលយកទ្រព្យសម្បត្តិពីដើមបណ្តឹង ដែលបានផ្តល់ជូន និងផ្តល់សិទ្ធិអំណាចមេបាលើកូន ជូនភាគីប្រពន្ធ តែខ្លួនសុំសិទ្ធិទំនាក់ទំនងសួរសុខទុក្ខ ។ ហេតុនេះសុំ លោកចៅក្រម ចេញសេចក្តីសម្រេចតាមផ្លូវច្បាប់ ដោយខ្ញុំបាទយល់ព្រមទទួលយកគ្រប់បែបយ៉ាង ។

**ស.ឆ** មេធាវី របស់ដើមបណ្តឹង បានឆ្លើយបញ្ជាក់ថា ខ្លួនសុំអោយលោកចៅក្រមចេញសេចក្តីសម្រេចជូនកូនក្តីរបស់ខ្ញុំបាទ តាមការលើកឡើងខាងលើ ដោយហេតុថា ភាគីប្តីប្រពន្ធ មានគោលបំណង និងឆន្ទៈ លែងលះគ្នាយ៉ាងពិតប្រាកដ ។ ម្យ៉ាងវិញទៀត កូនក្តីរបស់ខ្ញុំបាទ និងចុងចម្លើយ បានឯកភាពគ្នាលើការបែងចែកទ្រព្យ សងបំណុល សិទ្ធិគ្រប់គ្រងកូន រួចរាល់អស់ហើយ ហេតុនេះ សុំ លោកចៅក្រម សម្រេចតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុស្តីពីនីតិវិធីសាកសួរសាម៉ីភាគី ដោយមានការឯកភាពគ្រប់ចំណុច ។

ឈប់សួរ អានឲ្យសាម៉ីភាគី និងមេធាវី ស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **មេធាវី** **ដើមបណ្តឹង** **ចុងចម្លើយ**

.................... ....................

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ .........

ចុះថ្ងៃទី ខែ ឆ្នាំ

**សាលក្រមលេខ:**

ចុះថ្ងៃទី ខែ ឆ្នាំ

*តាងនាមប្រជារាស្ត្រខ្មែរ*

**សាលាដំបូងខេត្តកណ្តាល**

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់

នៅថ្ងៃទី ខែ ឆ្នាំ

ដោយមានសមាសភាព:

-លោក **ជួន ចន្ថា** ចៅក្រម

-លោក **ឃី អៀង** ក្រឡាបញ្ជី

-ដើមចោទឈ្មោះ ................................. ភេទ ........ កើតនៅឆ្នាំ .......... ជនជាតិខ្មែរ មុខរបរកសិបុគ្គលិកក្រុមហ៊ុន អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

-មានលោក ............ ជាមេធាវីតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ ............ ភេទ .... កីតនៅឆ្នាំ ........ ជនជាតិខ្មែរ មុខរប មេផ្ទះ អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

១-*<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:</u>*

១-សុំលែងលះពីប្រពន្ធឈ្មោះ .......... ។

២-សុំសិទ្ធិគ្រប់គ្រងកូនៈ

២.១.ឈ្មោះ .................... ភេទ .... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

២.២.ឈ្មោះ .......................... ភេទ .... កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-បែងចែកទ្រព្យសម្បត្តិរួមមាន:ដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............. ឃុំ ............ ស្រុក ............ ខេត្ត ............ ជាពីរចំណែកស្មើគ្នា។

៤-*<u>ការពន្យល់ត្រួសៗអំពីរឿងក្តី:</u>*

ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ ២០០៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ....... ចុះថ្ងៃទី ....... ខែ ....... ឆ្នាំ ......... នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ................. ។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍អ្នកទាំងពីររស់នៅជាមួយគ្នាមានកូនចំនួន ០២នាក់ មានឈ្មោះ ..................... ភេទ .... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ ........................ ភេទ ........ កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

ប៉ុន្តែក្រោយពេលដែល មានកូន ០២ នាក់ អ្នកទាំងពីរតែងតែមានភាពរកាំរកូសជាមួយគ្នាជាញឹកញាប់ ការរស់នៅមិនចុះសម្រុងគ្នា និងបានបែកលំនៅសង្វាសអស់មួយរយៈមកហើយ ជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្ដី ប្រពន្ធតទៅមុខទៀត។ ហើយក៏បានសម្រេចចិត្តដាក់ពាក្យបណ្ដឹងមកតុលាការ ។

៣-*<u>ការអះអាងរបស់ភាគី</u>*:

-ដើមចោទឈ្មោះ ...... បានអះអាងថា: ខ្លួនប្ដឹងសុំឲ្យតុលាការចេញសាលក្រម ដូចការទាមទារខាងលើ ដោយហេតុថា ខ្លួនបានរៀបការជាមួយឈ្មោះ ...... កាលពីថ្ងៃទី ខែ ឆ្នាំ និងបានទៅចុះ សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ។ ការរួមរស់នៅជាមួយគ្នាមានកូនចំនួន ០២ នាក់ គឺឈ្មោះ ...... ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ ...... ភេទប្រុស កើតថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៤។ ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ...... ឃុំ ...... ស្រុក ...... ខេត្ត ...... ដែលមានលិខិតលក់ទិញចុះថ្ងៃទី ០៩.០២.២០១២ និងបានឃេញនងបញ្ជាក់លេខ:០១៩/១២ ចុះថ្ងៃទី ខែ ឆ្នាំ របស់មេឃុំអូរបាក់រទេះ និងផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ...... ...... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ...... ដែលកំពុងបង់រំលោះនៅធនាគារបានចំនួន ១០ខែ ស្មើទឹកប្រាក់ចំនួន ...... ដុល្លាអាមេរិក និងមានគ្រឿងអលង្កាសរុបស្មើទឹកប្រាក់ចំនួន ...... ដុល្លាអាមេរិក សូមបញ្ជាក់ថា ពួកខ្លួនពុំមានជំពាក់បំណុលគេទេ ហើយដីខាងលើក៏ពុំមានជាប់ពាក់ព័ន្ធនឹងការធានាបំណុលគេដែរ ។

-ចុងចម្លើយឈ្មោះ ...... បានចូលមកធ្វើសេចក្ដីថ្លែងការណ៍តបថា: ខ្លួនឯកភាពក្នុងការលែងលះ សុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ សុំប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងពីតនាក់ក្នុងមួយខែចំនួន ៣០០$(បីរយ) ក្នុងករណីកូនទាំងពីរនាក់រស់នៅជាមួយខ្លួន និងទទួលស្គាល់ថាមានទ្រព្យសម្បត្តិរួមដូចការលើកឡើងរបស់ដើមចោទប្រាកដមែន។

ក្រោយការផ្សះផ្សាសម្រុះសម្រួលរួចមកគូរភាគីបានឯកភាពគ្នាដូចខាងក្រោម៖

-ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ...... ឃុំអូរ ...... ស្រុក ...... ខេត្ត ...... ដែលមានលិខិតលក់ទិញចុះថ្ងៃទី ...... និងបានឃើញនិងបញ្ជាក់លេខ: ...... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ...... របស់មេឃុំ ...... នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្ដោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ...... ...... ចុះថ្ងៃទី ... ខែ ...... ឆ្នាំ ...... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់រាហារកិច្ចចិញ្ចឹមកូន។

-កូនទីមួយឈ្មោះ ...... ភេទប្រុស និងកូនទីពីរឈ្មោះ ...... ភេទប្រុស ទុកសិទ្ធិឲ្យកូនគាត់ស្រេចចិត្តដោយខ្លួនគាត់។

-មេធាវីការពារសិទ្ធិដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-មេធាវីការពារសិទ្ធិចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-*ចំណុចវិវាទ:* ការលែងលះ និងសិទ្ធិគ្រប់គ្រងកូន។

៥-*ចំណុចគ្មានវិវាទ*: ឯកភាពលើការបែងចែកទ្រព្យសម្បត្តិរួម។

## សំអាងហេតុ

១-តាមការអះអាងរបស់គូភាគីឃើញថា ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកាលពីថ្ងៃទី ..... ខែ ....... ឆ្នាំ ....... និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ....... នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ............... ។ ដូច្នេះឃើញថាដើមចោទ និងចុងចម្លើយ បានបំពេញករណីយកិច្ចជាប្តីប្រពន្ធស្របច្បាប់ ចំពោះការទាមទារសុំលែងលះនេះតុលាការអាចពិចារណាសម្រេចបាន។ តុលាការបានសាកល្បងធ្វើការផ្សះផ្សាគូភាគីរួចហើយ ប៉ុន្តែគូភាគីនៅតែទាមទារលែងលះគ្នា ដោយសារអស់មនោសញ្ចេតនា អាណិតស្រលាញ់គ្នាជាប្តីប្រពន្ធទៀតហើយ ។

២-នៅក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីមានកូនចំនួន ០២នាក់មាន ៖

.ឈ្មោះ ............... ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

.ឈ្មោះ .................... ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-ទ្រព្យសម្បត្តិរួមមាន៖

-ទ្រព្យសម្បត្តិរួមចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ .......... ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............ ឃុំ ............ ស្រុក ............ ខេត្ត ............ ដែលមានលិខិតលក់ទិញចុះថ្ងៃទី ........................... និងបានឃើញនិងបញ្ជាក់លេខ: .......... ចុះថ្ងៃទី ..... ខែ ... ឆ្នាំ របស់មេឃុំ ........................... នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .................................. ....... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ..... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់អាហារកិច្ចចិញ្ចឹមកូន។

គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-កូនទីមួយឈ្មោះ ..................... ភេទប្រុស បានសុំរស់នៅជាមួយម្តាយ និងកូនទីពីរឈ្មោះ ..... ............ ភេទប្រុស បានសុំរស់នៅជាមួយឪពុក គប្បីតុលាការសម្រេចតាមការណ៍ស្នើសុំ។

យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នាមានសិទ្ធិ

ចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន" ។

៥-ចំពោះប្រាក់ប្រដាប់ក្ដីតុលាការតម្កល់ឲ្យដើមចោទ និងចុងចម្លើយ ទទួលបន្ទុកម្នាក់ពាក់កណ្ដាល (មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី )។

## សេចក្ដីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ ............ លែងលះពីចុងចម្លើយឈ្មោះ ........ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

២-ប្រគល់សិទ្ធិអំណាចមេបាឲ្យទៅ៖

២.១.ដើមចោទឈ្មោះ ............ លើកូនឈ្មោះ ............ ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

២.២.ចុងចម្លើយឈ្មោះ ........ លើកូនឈ្មោះ ............ ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

ទុកសិទ្ធិឲ្យភាគីដែលមិនបានទទួលសិទ្ធិអំណាចមេបាទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូន និងផ្ដល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៣-ប្រគល់ទ្រព្យសម្បត្តិរួមមាន៖

៣.១-ដីទំហំ ........ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ........ ឃុំ ........ ស្រុក ........ ខេត្ត ........ ដែលមានលិខិតលក់ទិញចុះថ្ងៃទី ............ និងបានឃើញនិងបញ្ជាក់លេខ: ........ ចុះថ្ងៃទី ... ខែ ឆ្នាំ ... របស់មេឃុំ ........ ប្រគល់ឲ្យកូនទាំងពីរនាក់គ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូរភាគីគ្រប់គ្រងដីនោះជាបណ្ដោះអាសន្ន។

៣.២-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

៣.៣-ផ្ទះមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ............ ........ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ។

-ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និង ត្រា **ជួន ខណ្ណា:**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

ធ្វើនៅខេត្តកណ្ដាល,ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
លេខ: ...... /២០២០

# លិខិតបញ្ជាក់សាលក្រមស្ថាពរ

យើង **ឃី អៀង** ក្រឡាបញ្ជីនៃសាលដំបូងខេត្តកណ្តាល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ...... ចុះថ្ងៃទី ...... ខែ ... ឆ្នាំ ......... របស់សាលាដំបូងខេត្តកណ្តាល។

បានឃើញ សាលក្រមលេខ: ......... ចុះថ្ងៃថ្ងៃទី ... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្តាល ។

បានឃើញ ពាក្យសុំបញ្ជាក់ការចូលជាសាលក្រមស្ថាពរនៃសាលក្រម ចុះថ្ងៃទី ......... ខែ ...... ឆ្នាំ ......... របស់មេធាវីឈ្មោះ ..................... ជាមេធាវីតំណាងដោយអាណត្តិរបស់ឲ្យចុងចម្លើយ។

សូមបញ្ជាក់ថា សាលក្រមលេខ: ......... ចុះថ្ងៃទី ... ខែ ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្តាល បានចូលជាស្ថាពរពីថ្ងៃទី ...... ខែ ... ឆ្នាំ ......... តទៅហើយដោយភាគីពុំបានប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

យើងចេញលិខិតបញ្ជាក់នេះ ដើម្បីអនុញ្ញាតឲ្យដាក់រូបមន្តអនុវត្តលើសាលក្រមនេះសម្រាប់ភាគីសុំយកទៅអនុវត្តតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣
ខេត្តកណ្តាល , ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០
**ក្រឡាបញ្ជី**

ឃី . អៀង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

លេខ: /២០២០

## រូបមន្តអនុវត្តសាលក្រម

យើង **ឃី អៀង** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល ។

បានឃើញ មាត្រា ៣៥៤,៣៥៥ និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ លិខិតបញ្ជាក់សាលក្រមស្ថាពរលេខ: ចុះថ្ងៃទី ... ខែ ........ ឆ្នាំ របស់ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល ។

បានឃើញ ពាក្យសុំចុះថ្ងៃទី ... ខែ ........ ឆ្នាំ ........ របស់អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយឈ្មោះ .................... ។

### សូមបញ្ជាក់ពីខ្លឹមសារអនុវត្តដូចខាងក្រោម:

-ម្ចាស់បំណុល នៃការអនុវត្តឈ្មោះ .................... ភេទ ..... កើតនៅឆ្នាំ ........ អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី) ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

-កូនបំណុលនៃការអនុវត្តឈ្មោះ ........... ភេទ ... កើតនៅឆ្នាំ ........ អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

-អនុវត្តតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ: ...... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...... របស់សាលាដំបូងខេត្តកណ្តាល ដែលបានចូលជាស្ថាពរពីថ្ងៃទី ... ខែ ... ឆ្នាំ ........ គ្រប់ចំណុចទាំងមូលនៃសាលក្រម។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលក្រម ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍ អនុវត្តសាលក្រមនេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។*

ថ្ងៃព្រហស្បតិ៍ ០១ ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ខេត្តកណ្តាល ,ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

ឃី . អៀង